ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល

មគ្គទេសក៍កំណែទម្រង់
គុណានុភាពនៃសាលាបឋមសិក្សាវត្តបូពិ



ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព

សាលាភូមិន្ទរដ្ឋបាល
២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល

មគ្គទេសក៍កំណែទម្រង់
គុណានុភាពនៃសាលាបឋមសិក្សាវត្តបូ



ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព

សាលាភូមិន្ទរដ្ឋបាល

២០២០

អារម្ភកថា

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រគន្លឹះមួយ គឺបន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមាន “**អភិបាលកិច្ចល្អ**” ជាស្នូលនៃយុទ្ធសាស្ត្រ។

ក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ “**អភិបាលកិច្ចល្អ**” ត្រូវបានកំណត់ថាជាគោលដៅនៃការកែទម្រង់រដ្ឋបាលសាធារណៈ ដោយផ្តោតលើការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័នសាធារណៈ ជាពិសេសគឺការពង្រឹងសមត្ថភាពលើភាពជាអ្នកដឹកនាំរបស់ថ្នាក់ដឹកនាំអង្គភាពក្នុងរដ្ឋបាលសាធារណៈ ដើម្បីប្រសិទ្ធភាពស្ថាប័នសាធារណៈ។

ស្ថិតនៅក្នុងទស្សនវិស័យនេះ សាលាភូមិន្ទរដ្ឋបាល បានផ្តួចផ្តើមឱ្យមានការសិក្សាស្រាវជ្រាវសាកល្បងលើគម្រោងស្រាវជ្រាវមួយពាក់ព័ន្ធប្រសិទ្ធភាព នៃការគ្រប់គ្រងសាលាបឋមសិក្សាវត្តបូព៌ ដោយមានគោលបំណងចំនួន ២ គឺ÷

ទី១. សិក្សាស្រាវជ្រាវ ដើម្បីស្វែងយល់ពីសាវតារ បុព្វហេតុ សមិទ្ធផល និងទស្សន-វិស័យរបស់សាលាបឋមសិក្សានេះ ដោយគ្របដណ្តប់លើគ្រប់ទិដ្ឋភាព ទាំងវិធីសាស្ត្រ ទាំងខ្លឹមសារ នៃការដឹកនាំនិងគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលា និងភាគីពាក់ព័ន្ធ រួមមានទិដ្ឋភាពនៃការដឹកនាំ គ្រប់គ្រង ជំនឿ វប្បធម៌ អប់រំ ច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រ។

ទី២. ផ្សព្វផ្សាយនូវលទ្ធផលនៃការស្រាវជ្រាវ រួមមានសៀវភៅ និងភាពយន្តឯកសារ ក៏ដូចជាចំណេះដឹង និងបទពិសោធន៍ ជូនសាធារណជន។

តាមរយៈបេសកកម្មដែលបានដាក់ចេញនេះ គណៈកម្មការរៀបចំចងក្រងនិងបោះពុម្ពសៀវភៅករណីសិក្សាលើប្រធានបទស្តីពី “ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព” បានសម្រេចចេញជាស្នាដៃចំនួន ២ គឺ វីដេអូខ្លីស្តីពី “**ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព**” ករណីសិក្សា “**មគ្គទេសក៍កំណែទម្រង់ គុណានុភាពនៃសាលាបឋមសិក្សាវត្តបូព៌**” និងសៀវភៅ “**មគ្គទេសក៍កំណែទម្រង់ គុណានុភាពនៃសាលាបឋមសិក្សាវត្តបូព៌**”។ សៀវភៅនេះត្រូវបានរៀបចំចងក្រងឡើង ដោយរំលេចឱ្យឃើញនូវសាវតាររបស់សាលា, គុណតម្លៃស្នូលរបស់សាលា, វិធីសាស្ត្រដឹកនាំនិងគ្រប់គ្រងសាលាប្រកបដោយប្រសិទ្ធភាពរបស់គណៈគ្រប់គ្រងសាលា និងទស្សនវិស័យដឹកនាំរបស់គណៈ-

គ្រប់គ្រងសាលា ដោយមានកិច្ចសហការរវាងតួអង្គគន្លឹះពាក់ព័ន្ធទាំងអស់ ដើម្បីសម្រេចនូវចក្ខុវិស័យនិងបេសកកម្មរបស់សាលា។

ក្នុងន័យនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងកន្លងមក របស់សាលាភូមិន្ទរដ្ឋបាល ដែលមានឯកឧត្តម **យក់ ប៊ុនណា** រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ និងជានាយកសាលាភូមិន្ទរដ្ឋបាល ដែលបានផ្តួចផ្តើមគំនិតនិងដឹកនាំគម្រោងស្រាវជ្រាវនេះឱ្យសម្រេចបានលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈ។

ជាមួយគ្នានេះ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល និងក្រុមការងារ ព្រមទាំងលោកនាយក **ពឹង គិមឆេង** ថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រងសាលាបឋមសិក្សាវត្តឫពិដែលបានដឹកនាំសម្របសម្រួល និងសហការរហូតសម្រេចបាននូវសមិទ្ធផលជាស្នាដៃនេះឡើង។

សៀវភៅនេះ គប្បីទុកជា “**ឯកសារយោង**” ដែលត្រូវធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់តាមរយៈការអនុវត្តបណ្តើរ ដកពិសោធន៍បណ្តើរ ស្របតាមអភិក្រម “**រៀនបណ្តើរ ធ្វើបណ្តើរ**” សំដៅឈានទៅដល់ឧត្តមានុវត្តន៍ជាតិ និងអន្តរជាតិ។

ខ្ញុំជឿជាក់ថា សៀវភៅ “**មគ្គទេសក៍កំណែទម្រង់ គុណានុភាពនៃសាលាបឋមសិក្សាវត្តឫពិ**” នឹងក្លាយជាឯកសារជំនួយស្មារតីសម្រាប់តម្រង់ទិសការដឹកនាំនិងការគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលាគ្រប់កម្រិត ក៍ដូចជាសម្រាប់ថ្នាក់ដឹកនាំអង្គភាពសាធារណៈក្នុងរដ្ឋបាលសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ថ្ងៃ ចន្ទ ១៤កោះ ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៩

រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

កិត្តិបណ្ឌិត ពេជ្ជ ប៊ុនឆិន

សេចក្តីផ្តើម

សាលាបឋមសិក្សាវត្តបូព៌ គឺជាគ្រឹះស្ថានសិក្សាអប់រំសាធារណៈស្ថិតនៅក្នុងខេត្តសៀមរាប ដែលបានឆ្លងកាត់ការវិវត្តជាបន្តបន្ទាប់អស់រយៈពេលជាច្រើនឆ្នាំ ដើម្បីពង្រឹងគុណភាពសិក្សាអប់រំនិងការផ្តល់សេវាអប់រំ ក្នុងកម្រិតបឋមសិក្សា។ ស្ថិតក្រោមការដឹកនាំនិងគ្រប់គ្រងរបស់លោកនាយក**ពិន គិមឆេន** សាលាបឋមសិក្សាវត្តបូព៌ បានធ្វើកំណែទម្រង់ការដឹកនាំ និងការគ្រប់គ្រងរបស់ខ្លួនជាបន្តបន្ទាប់ រហូតទទួលបានការចូលរួមយ៉ាងសកម្មពីលោកគ្រូ អ្នកគ្រូ សិស្ស និងសហគមន៍ ដែលជាតួអង្គគន្លឹះយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍនិងកំណែទម្រង់សាលាបឋមសិក្សាវត្តបូព៌។ តាមរយៈលទ្ធផលល្អប្រសើរនៃការសិក្សាអប់រំនិងសីលធម៌វិន័យល្អប្រពៃរបស់សិស្សានុសិស្ស បានស្តែងឱ្យឃើញយ៉ាងប្រត្យក្ស នូវការកំណត់យល់ ការទទួលយក និងការប្តេជ្ញាប្រតិបត្តិតាមជាឆ្លុងមួយ របស់គណៈគ្រប់គ្រងសាលានិងគ្រូបង្រៀន នូវគុណតម្លៃស្នូលរបស់សាលាផ្ទាល់ តាមរយៈការបង្កើនគុណតម្លៃរបស់គ្រូបង្រៀន ដោយឈរលើគុណភាពបង្រៀន សមត្ថភាពបង្រៀន និងក្រមសីលធម៌វិជ្ជាជីវៈ។

សៀវភៅ “**មគ្គទេសក៍កំណែទម្រង់ គុណានុភាពនៃសាលាបឋមសិក្សាវត្តបូព៌**” ត្រូវបានរៀបចំចងក្រងឡើង ដោយរំលេចឱ្យឃើញនូវរបៀបដឹកនាំ និងគ្រប់គ្រងសាលាប្រកបដោយប្រសិទ្ធភាព រវាងតួអង្គគន្លឹះពាក់ព័ន្ធទាំងអស់ ក្នុងបុព្វហេតុនៃការសិក្សាអប់រំប្រកបដោយគុណភាព មានសីលធម៌ និងវិន័យ ដោយផ្សារភ្ជាប់នឹងការកសាងសមត្ថភាពនៃគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាអប់រំសាធារណៈ ក្នុងគោលបំណងបណ្តុះស្មារតីដល់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូឱ្យមានទស្សនវិស័យ លើការអភិវឌ្ឍអង្គភាពរបស់ខ្លួនឱ្យមានភាពរីកចម្រើន ពង្រឹងសមត្ថភាពនិងចែករំលែកបទពិសោធន៍ការងារ ក្នុងការគ្រប់គ្រងអង្គភាព ដោយផ្លាស់ប្តូរពីអ្នកធ្វើតាម ឱ្យទៅជាអ្នកចេះបង្កើតគំនិតថ្មីដោយខ្លួនឯងប្រកបដោយនវានុវត្តន៍។

ហេតុនេះ រាល់ខ្លឹមសារនិងគំនិតទស្សនៈ ដែលបានលើកឡើងក្នុង សៀវភៅ“**មគ្គទេសក៍កំណែទម្រង់ គុណានុភាពនៃសាលាបឋមសិក្សាវត្តបូព៌**” គឺជាទស្សនៈនៃការដឹកនាំផ្ទាល់របស់សាលាបឋមសិក្សាវត្តបូព៌ ដោយគណៈកម្មការរៀបចំចងក្រងនិងបោះពុម្ពសៀវភៅ ករណីសិក្សាលើប្រធានបទស្តីពី “**ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព**”

គ្រាន់តែប្រមូលគំនិតទស្សនៈនៃការដឹកនាំនិងគ្រប់គ្រងទាំងនោះ មករៀបចំជាប្លង់គំនិត និងចងក្រងតាក់តែងឡើង ដើម្បីឱ្យងាយស្រួលយល់ប៉ុណ្ណោះ ដែលពុំប៉ះពាល់ដល់ខ្លឹមសារនិងទស្សនៈនៃការដឹកនាំនិងគ្រប់គ្រងផ្នាល់របស់សាលាបឋមសិក្សាវត្តបូពិឡើយ។

សៀវភៅ “**មគ្គទេសក៍កំណែទម្រង់ គុណានុភាពនៃសាលាបឋមសិក្សាវត្តបូពិ**” ត្រូវបានរៀបចំចងក្រងឡើង ទៅតាមដំណាក់កាលជាបន្តបន្ទាប់ ដូចខាងក្រោម÷

- ការប្រមូលឯកសារទាំងអស់ រួមទាំងអត្ថបទនានាដែលបានចុះផ្សាយ វីដេអូសម្ភាសវីដេអូឯកសារ
- ការធ្វើវិចារណកម្មខ្លឹមសារអត្ថបទ ដើម្បីរៀបចំជាមាតិកានុក្រមបឋម
- ការរៀបចំជាមាតិកានុក្រមបឋម
- ការរៀបចំខ្លឹមសារតាមមាតិកានុក្រមបឋម
- ការកែសម្រួលមាតិកានុក្រមបឋម
- ការបំពេញបន្ថែមខ្លឹមសារតាមមាតិកានុក្រម តាមរយៈការប្រមូលឯកសារបន្ថែម និងការសម្ភាសផ្ទាល់
- ការថតរូបទៅតាមខ្លឹមសារមាតិកា
- ការរៀបចំជាឯកសារពេញលេញ
- ការដាក់ឯកសារពិគ្រោះយោបល់ជាមួយគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន
- ការពិនិត្យផ្ទៀងផ្ទាត់កម្រិតជំនាញបច្ចេកទេស
- ការពិនិត្យផ្ទៀងផ្ទាត់កម្រិតថ្នាក់ដឹកនាំក្រុមការងារ
- ការអនុម័តនិងសម្រេចឱ្យបោះពុម្ពដោយឯកឧត្តមនាយកសាលាភូមិន្ទរដ្ឋបាល
- ការពិនិត្យផ្ទៀងផ្ទាត់បញ្ចប់និងបញ្ជូនទៅរោងពុម្ព។

សៀវភៅ “**មគ្គទេសក៍កំណែទម្រង់ គុណានុភាពនៃសាលាបឋមសិក្សាវត្តបូពិ**” ត្រូវបានរៀបចំចងក្រងឡើង ដោយមានរចនាសម្ព័ន្ធប្លង់ ដូចខាងក្រោម÷

- អារម្ភកថា
- សេចក្តីផ្តើម
- មាតិកានុក្រមសង្ខេប
- តួសេចក្តី នៃសៀវភៅ ចែកចេញជា ៣ មាតិកា ដូចខាងក្រោម÷
  - មាតិកាទី១. សាវតារ និងចក្ខុវិស័យ

- មាតិកាទី២. សម្មាភិបាល
- មាតិកាទី៣. ទស្សនវិស័យ

- សេចក្តីសន្និដ្ឋាន
- ឧបសម្ព័ន្ធ
- មាតិកានុក្រមពិស្តារ។

ខ្លឹមសារទាំងស្រុង នៃសៀវភៅ “**មគ្គទេសក៍កំណែទម្រង់ គុណានុគារភាពនៃសាលាបឋមសិក្សាវត្តបូព៌**” ត្រូវបានបង្ហាញតាមលំដាប់លំដោយ ដូចតទៅ÷

មាតិកានុក្រមសង្ខេប

អារម្ភកថា I
សេចក្តីផ្តើម III
មាតិកាទី១. សាវតារ និងចក្ខុវិស័យ ១
ជំពូកទី១. មុនការដឹកនាំរបស់លោកនាយក ពឹង គិមឆេន ឆ្នាំ១៩៩៤ ..... ១
ផ្នែកទី១. មុនឆ្នាំ១៩៧៩ ..... ១
ផ្នែកទី២. ក្រោយឆ្នាំ១៩៧៩ ..... ១
ជំពូកទី២. ចាប់ពីការដឹកនាំរបស់លោកនាយក ពឹង គិមឆេន ឆ្នាំ១៩៩៤ ដល់បច្ចុប្បន្ន ... ៣
ជំពូកទី៣. ចក្ខុវិស័យ និងយុទ្ធសាស្ត្រ ៧
ផ្នែកទី១. ចក្ខុវិស័យ ៧
ផ្នែកទី២. យុទ្ធសាស្ត្រ ៧
មាតិកាទី២. សម្ភារតិចាល ៩
ជំពូកទី១. សាលារៀន ៩
ផ្នែកទី១. ក្របខ័ណ្ឌស្ថាប័ន ៩
ផ្នែកទី២. គុណតម្លៃរបស់សាលារៀន ២០
ផ្នែកទី៣. ការគ្រប់គ្រងធនធានគ្រូបង្រៀន ២១
ផ្នែកទី៤. ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ២៤
ជំពូកទី២. សិស្សានុសិស្ស ២៩
ផ្នែកទី១. ការអប់រំសមាសភាគទាំង ៥ ..... ២៩
ផ្នែកទី២. សាសនា និងការអប់រំ ៣៤
ផ្នែកទី៣. គោលការណ៍ប្រតិបត្តិទាំង ៥ ..... ៣៤
ផ្នែកទី៤. មិត្តអប់រំមិត្ត ៣៨

ផ្នែកទី៥. ការត្រួតពិនិត្យវិន័យ..... ៣៨
ផ្នែកទី៦. ការលើកទឹកចិត្តសិស្សានុសិស្ស..... ៤២
ជំពូកទី៣. សហគមន៍..... ៤៥
ផ្នែកទី១. សហគមន៍ជាតិ..... ៤៥
ផ្នែកទី២. សហគមន៍អន្តរជាតិ..... ៤៨
មាតិកាទី៣. ធម្មនេតិសំយ..... ៥១
ជំពូកទី១. ភាពជាគំរូ..... ៥១
ជំពូកទី២. ការថែគ្រាប់ពូជ នៅភូមិសិក្សាបន្ទាប់..... ៥៣
ជំពូកទី៣. ការបន្តវេន..... ៥៥
សេចក្តីសន្និដ្ឋាន..... ៥៧
បញ្ជីខ្លួបសម្ព័ន្ធ..... ៥៩

មាតិកាទី១. សាវតារ និងចក្ខុវិស័យ

ជំពូកទី១. មុនការដឹកនាំរបស់លោកនាយក ពីធ គិមឆេន ឆ្នាំ១៩៩៤

ផ្នែកទី១. មុនឆ្នាំ១៩៧៩

នៅក្នុងឆ្នាំ១៩៥៧ សាលាបឋមសិក្សាវត្តបូពិ ត្រូវបានកសាងឡើងដំបូងគេបង្អស់ដោយព្រះសង្ឃមួយអង្គព្រះនាម **សុមិគុណ ហ៊ីង ម៉ៅ** (អតីតព្រះចៅអធិការវត្តរាជបូណិ) ដែលបានសាងសង់សាលារៀនមួយខ្នង មានបន្ទប់រៀនចំនួន ៣ ប៉ុណ្ណោះ ស្ថិតក្នុងវត្តរាជបូណិ ដោយបានដាក់ឈ្មោះថាសាលារៀន ហ៊ីង ម៉ៅ និងត្រូវបានប្រជាជនហៅតៗគ្នាថា **សាលាបឋមសិក្សាវត្តបូពិ** ដែលទីតាំងបច្ចុប្បន្ន ស្ថិតនៅក្នុងបរិវេណសាលាបឋមសិក្សាវត្តបូពិ ***(ទីតាំងបច្ចុប្បន្នរបស់សាលាបឋមវត្តបូពិ ក៏ជាអតីតទីតាំងរបស់វត្តរាជបូណិ ពីមុនផងដែរ)***។ អគារនេះ ធ្វើអំពីថ្ម មានកម្ពស់ ១ ជាន់ ប្រក់ក្បឿង ដែលបច្ចុប្បន្ន អគារនេះត្រូវបានវាយកម្ទេចចោលទាំងស្រុងអស់ហើយ ដើម្បីកសាងអគារសិក្សាថ្មីមាន ៣ ជាន់ ដ្បិតអគារចាស់នោះ មានសភាពចាស់ទ្រុឌទ្រោមខ្លាំង។

សម័យសាធារណៈរដ្ឋខ្មែរ (ឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥) សាលារៀននេះ នៅបន្តដំណើរការដដែល ដោយពុំមានសាងសង់អគារសិក្សាបន្ថែមទៀតឡើយ។ ដោយឡែកក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) សាលាបឋមសិក្សាវត្តបូពិ ត្រូវបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ស្ទើរតែខ្ទេចទាំងស្រុង ដោយសាលារៀននេះ ត្រូវបានប្រើប្រាស់ជាឃ្លាំងដាក់អាវុធ និងរបស់របរផ្សេងៗទៀត។

ផ្នែកទី២. ក្រោយឆ្នាំ១៩៧៩

សាលាបឋមសិក្សាវត្តបូពិ បានចាប់ដំណើរការឡើងវិញនៅខែកញ្ញា ឆ្នាំ១៩៨០ ដែលមានទីតាំងស្ថិតនៅក្នុងវត្តរាជបូណិសព្វថ្ងៃ (**បច្ចុប្បន្ន អតីតទីតាំងអគារសិក្សាចាស់នៃ**

សាលាបឋមសិក្សាវត្តបូព៌ ត្រូវបានសាងសង់ជាកុដិវិញ) ដោយប្រើប្រាស់កុដិរបស់ព្រះសង្ឃ ធ្វើជាអគារសិក្សា ដែលមាននាយិកាឈ្មោះ **ជុំ ត្រែង**។ ក្នុងពេលនោះ សាលារៀនមានអគារ ១ ខ្នង មាន ៣ បន្ទប់ ដោយ ២ បន្ទប់សម្រាប់ថ្នាក់ទី១ និង ១ បន្ទប់ទៀតសម្រាប់ថ្នាក់ទី២។

នៅឆ្នាំ**១៩៨៩** សាលាបឋមសិក្សាវត្តបូព៌ ត្រូវបានផ្លាស់ប្តូរទីតាំងពីវត្តរាជបូណ៌ មកទីតាំងសាលាបឋមសិក្សាវត្តបូព៌បច្ចុប្បន្ន ក្រោមការសម្របសម្រួលរបស់អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ដោយសារតែកំណើនសិស្សមានការកើនឡើងជាបន្តបន្ទាប់ធ្វើឱ្យអគារសិក្សាដែលមានស្រាប់នៅក្នុងវត្តរាជបូណ៌ពុំអាចទ្រទ្រង់បាន។ *(សូមមើលឧបសម្ព័ន្ធទី៩ ស្តីពីតារាងសង្ខេបស្តីពីស្ថានភាពសិក្សាអប់រំក្នុងសាលាបឋមសិក្សាវត្តបូព៌ ពីឆ្នាំ**១៩៥៧** ដល់ឆ្នាំ**២០១៨**។)*

ការបើកដំណើរការឡើងវិញរបស់សាលាបឋមសិក្សាវត្តបូព៌ អាចដំណើរការទៅបានដោយសារមានកិច្ចសហការយ៉ាងល្អប្រសើររវាងសហគមន៍ ព្រះសង្ឃ អាជ្ញាធរដែនដី គ្រូបង្រៀន និងសិស្ស ដែលបានរួមវិភាគទានទាំងកម្លាំង ថវិកា និងសម្ភារផ្សេងៗដើម្បីកសាងសាលារៀន ជាបន្តបន្ទាប់។

ជំពូកទី២. ចាប់ពីការដឹកនាំរបស់លោកនាយក ពឹង គិមឆេង ឆ្នាំ១៩៩៤ ដល់បច្ចុប្បន្ន

ចាប់ពីឆ្នាំ១៩៩៤ រហូតមកដល់បច្ចុប្បន្ន (ឆ្នាំ២០១៩) សាលាបឋមសិក្សាវត្តបូពិ ត្រូវបានដឹកនាំដោយនាយកមួយរូប ដែលធ្លាប់បានទទួលពានរង្វាន់សម្តេចតេជោសែន **នាយកល្អចំណាត់ថ្នាក់លេខ ១ នៅឆ្នាំ២០១៥** គឺលោកនាយក **ពឹង គិមឆេង** ដែលត្រូវបានតែងតាំងជាផ្លូវការ ដោយប្រកាសលេខ ៨០០ អយក.ប្រក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការតែងតាំងមន្ត្រីគ្រប់គ្រង។

សាលាបឋមសិក្សាវត្តបូពិ មានលេខកូដ ១៧១០០៤០១០១៩ ស្ថិតក្នុងភូមិវត្តបូពិ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ដែលត្រូវបានបើកជាសាលាបឋមសិក្សាពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា២០១៧-២០១៨ ដោយប្រកាសលេខ ៨២៦ អយក.ប្រក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបើកសាលាបឋមសិក្សាវត្តបូពិ ជាសាលាបឋមសិក្សាពេញលក្ខណៈ។

ក្នុងសម័យកាលលោកនាយក សាលាបឋមសិក្សាវត្តបូពិ ត្រូវបានដឹកនាំនិងគ្រប់គ្រងដោយគណៈគ្រប់គ្រង ៣ រូប គឺនាយក ១ រូប និងនាយករង ២ រូប ដែលត្រូវបានបែងចែកភារកិច្ច ដូចខាងក្រោម÷

- នាយក ទទួលបន្ទុកក្តាប់រួម និងមានភារកិច្ចបន្ថែមលើការងារចាត់តាំង និងទំនាក់-ទំនងសហគមន៍ជាតិ និងអន្តរជាតិ
- នាយករង ទទួលបន្ទុករដ្ឋបាល
- នាយិការង ទទួលបន្ទុកបច្ចេកទេស។

នៅឆ្នាំសិក្សា២០០១-២០០២ ដើម្បីធ្វើឱ្យការដឹកនាំ និងគ្រប់គ្រង កាន់តែមានប្រសិទ្ធភាព គណៈគ្រប់គ្រងក្រុមស្ម័យភាព ២ ក្រុម ត្រូវបានបង្កើតឡើង តាមបែបវិមជ្ឈការការងារ ដើម្បីជាជំនួយដល់គណៈគ្រប់គ្រងសាលា ក្នុងកិច្ចដំណើរការសិក្សាប្រចាំថ្ងៃ។

ស្ថិតក្រោមការដឹកនាំរបស់លោកនាយកសាលា សាលាបឋមសិក្សាវត្តបូពិ សម្រេច

បានសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់ ដូចខាងក្រោម÷

- ការរៀបចំឱ្យមានឡានដឹកសិស្សជាមធ្យោបាយធ្វើដំណើរ (បច្ចុប្បន្ន មានរថយន្ត ចំនួន១៩ គ្រឿង តាមតម្រាយផ្លូវផ្សេងពីគ្នា) ក្នុងគោលបំណង ជួយដល់សហគមន៍ និងជួយខ្លួនឯង។
  - **ជួយសហគមន៍** សំដៅ÷
    - ការកាត់បន្ថយភាពរវល់
    - កាត់បន្ថយការចំណាយលើមធ្យោបាយធ្វើដំណើរ
    - កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និង
    - កាត់បន្ថយសិស្សគេចសាលា។
  - **ជួយខ្លួនឯង** សំដៅ÷
    - គ្រូ÷ ជួយជីវភាពបុគ្គលិកឱ្យកាន់តែប្រសើរឡើង ដ្បិតអ្នកបើកឡានអាចជាគ្រូ ឬសាច់ញាតិគ្រូ
    - សាលារៀន÷ កាត់បន្ថយភាពកកស្ទះនៅសាលារៀន។
- ឆ្នាំសិក្សា**១៩៩៦-១៩៩៧**÷ សាលា បានរៀបចំឯកសណ្ឋានទាំងគ្រូ និងសិស្ស ដើម្បីលើកតម្កើងគោលការណ៍សមធម៌ក្នុងសាលារៀន។
- បង្កើតឱ្យមានសញ្ញាសម្គាល់សាលា ដែលបង្កប់អត្ថន័យ ដូចតទៅ÷
  - រូបត្រីកោណតូច តំណាងឱ្យកិច្ចសហការនៃយុទ្ធសាស្ត្រត្រីកោណ **(ភវស)** ក្នុងនោះ ត្រីកោណពណ៌ខៀវតំណាងសាលារៀន, ពណ៌លឿងតំណាងវត្ត, ពណ៌បៃតងតំណាងភូមិ និងពណ៌សតំណាងសិស្សានុសិស្សទាំងអស់
  - រូបបួនទ្រពីក្រោម តំណាងការរួមចំណែកលើកស្ទួយវិស័យអប់រំ។



❖ ទទួលបានពានរង្វាន់ជាតិ និងអន្តរជាតិ ដូចខាងក្រោម÷

- ***២០១៧÷ វិញ្ញាបនបត្រទទួលស្គាល់ (ការអនុវត្តស្តង់ដារសាលាស្អាត), រដ្ឋមន្ត្រីក្រសួងទេសចរណ៍***
- ***២០១៦÷ ប័ណ្ណសរសើរ, រដ្ឋមន្ត្រីក្រសួងព័ត៌មាន***
- ***២០១៦÷ ប្រកាសនីយបត្រកិត្តិយស កម្មវិធីមហោស្រពតន្ត្រី និងចម្រៀងកុមារ ២០១៦, រដ្ឋមន្ត្រីក្រសួងព័ត៌មាន***
- ***២០១៥÷ ពានរង្វាន់WAT BO PRIMARY SCHOOL, SIAM REAP CAMBODIA ASEAN ECO-SCHOOLS AWARD 2015 Primary School Category***
- ***២០១៤÷ ប័ណ្ណសរសើរ(សុខភាពអនាម័យ), ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល***
- ***២០១១÷ ទង់ជ័យលាភី ថ្នាក់លេខ១, រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា***
- ***២០០៩÷ ប័ណ្ណសរសើរ(ចំណាត់ថ្នាក់លេខ១), រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា***
- ***២០០៦÷ ទង់ជ័យលាភី ថ្នាក់លេខ២, រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា***
- ***២០០២÷ ប័ណ្ណសរសើរ(ចំណាត់ថ្នាក់លេខ១), រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។***

ជំពូកទី៣. ចក្ខុវិស័យ និងយុទ្ធសាស្ត្រ

ផ្នែកទី១. ចក្ខុវិស័យ

សាលាបឋមសិក្សាវត្តបូព៌ា មានចក្ខុវិស័យមុតស្រួចនិងច្បាស់លាស់ គឺ “**បណ្តុះគ្រាប់ពូជជាធនធានមនុស្សកម្រិតបឋមសិក្សា ប្រកបដោយគុណភាពខ្ពស់ មានឥរិយាបថថ្លៃថ្នូរ និងសុខុមាលភាពល្អប្រសើរ ដើម្បីចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិ ឱ្យមានការីកចំរើនដូចបណ្តាប្រទេសក្នុងតំបន់និងពិភពលោក**”។

ផ្នែកទី២. យុទ្ធសាស្ត្រ

ដើម្បីសម្រេចនូវចក្ខុវិស័យខាងលើ សាលាបឋមសិក្សាវត្តបូព៌ា មានយុទ្ធសាស្ត្រជាសសរស្តម្ភ ចំនួន ៣ គឺ÷

ទី១. សាលារៀន÷

- ការពង្រឹងនិងរក្សាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងបរិវេណសាលា
- ការពង្រឹងវិន័យ និងការអភិវឌ្ឍសមត្ថភាពគ្រូ។

ទី២. សិស្ស÷

- ពង្រឹងវិន័យ និងអប់រំសិស្សឱ្យមានឥរិយាបថថ្លៃថ្នូរ
- ថែទាំនិងត្រួតពិនិត្យតាមដានសុខុមាលភាពសិស្ស។

ទី៣. សហគមន៍÷

- កៀរគរការគាំទ្រពីសហគមន៍ជាតិនិងអន្តរជាតិ
- ពង្រឹងនិងពង្រីកកិច្ចសហការជាមួយសហគមន៍ជាតិនិងអន្តរជាតិ។

សសរស្តម្ភទាំង ៣ ខាងលើ នឹងបង្ហាញលម្អិត នៅក្នុងមាតិកាទី២ ស្តីពីសម្មាភិបាល។

មាតិកាទី២. សម្ភាតិចារ

ជំពូកទី១. សាលារៀន

ផ្នែកទី១. ក្របខ័ណ្ឌស្ថាប័ន

ក. រចនាសម្ព័ន្ធដឹកនាំ

សាលាបឋមសិក្សាវត្តបូពិ ដឹកនាំនិងគ្រប់គ្រងដោយនាយក ១ រូប អមដោយនាយករង ចំនួន ២ រូប និងលេខាធិការចំនួន ១ រូប។ ទន្ទឹមនេះ សាលាបឋមសិក្សាវត្តបូពិ បានបង្កើតគណៈកម្មការទ្រទ្រង់សាលា ដើម្បីធានាប្រសិទ្ធភាពនៃការដឹកនាំ និងការអភិវឌ្ឍសាលាប្រកបដោយភាពរលូន តម្លាភាព និងគណនេយ្យភាព។

នាយក មានមុខងារនិងភារកិច្ចដឹកនាំ គ្រប់គ្រង និងចាត់ចែងកិច្ចការទូទៅរបស់សាលា ព្រមទាំងទទួលបន្ទុកផ្តាល់លើការងារចាត់តាំងភារកិច្ចបុគ្គលិក គ្រូ សិស្ស និងការអនុញ្ញាតច្បាប់, ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, កិច្ចការទំនាក់ទំនងសាធារណៈទាំងកម្រិតក្នុងប្រទេស និងក្រៅប្រទេស និងការសំណេះសំណាលជុំវិញបញ្ហានានាពាក់ព័ន្ធការងារទំនាក់-ទំនងជាមួយនឹងសមាគមមាតាបិតា-អាណាព្យាបាលសិស្ស។

ភារកិច្ចរបស់នាយករង មាន ២ ផែនគឺ ការងាររដ្ឋបាល និងការងារបច្ចេកទេស។ តាមរយៈនេះ នាយករង ១ រូប ទទួលបន្ទុកកិច្ចការរដ្ឋបាលទូទៅ និងនាយិការង ១ រូប ទទួលបន្ទុកការងារបច្ចេកទេស។

នាយករង មានភារកិច្ច ដូចខាងក្រោម÷

➤ **ការគ្រប់គ្រងសិស្ស÷**

- ពិនិត្យលទ្ធផលសិក្សារបស់សិស្សរៀងរាល់ខែ
- គ្រប់គ្រងស្ថិតិសិស្ស និងថ្នាក់
- គ្រប់គ្រងបញ្ជីស្រង់អវត្តមានរបស់សិស្សជាប្រចាំ

- គ្រប់គ្រងវិន័យរបស់សិស្សដោយបង្កើតឧបករណ៍តាមដាន ដូចជាសៀវភៅទំនាក់-ទំនងមាតាបិតា អាជ្ញាធរ សហគមន៍, សៀវភៅតាមដានការសិក្សារបស់សិស្ស
- គ្រប់គ្រងលើប្រភេទសិស្សរៀនពូកែ មធ្យម ខ្សោយ តាមរយៈសៀវភៅតាមដានការសិក្សារបស់សិស្ស
- រៀបចំបញ្ជីជួយសិស្សខ្សោយប្រចាំខែ ឆមាស ឆ្នាំ
- រៀបចំរបាយការណ៍ផ្សេងៗដែលទាក់ទងនឹងការរៀនរបស់សិស្ស។

➢ សុខភាពសិស្ស÷

- បង្កើតគណៈកម្មាធិការក្រុមប្រឹក្សាកុមារអប់រំ ទប់ស្កាត់នឹងជំងឺអេដស៍ កាមរោគ និងគ្រឿងញៀន
- ជំរុញសកម្មភាពទប់ស្កាត់នឹងជំងឺអេដស៍ ការជួញដូរកុមារ និងគ្រឿងញៀន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាព សុខភាពសិស្សប្រចាំខែជូននាយកសាលា
- បំប៉នអំពីវិធីសាស្ត្រសង្គ្រោះបន្ទាន់ និងវិធីថែរក្សាសុខភាព វិធីព្យាបាលកម្រិតមូលដ្ឋាន
- តាមដានការប្រែប្រួលសុខភាពរបស់កុមារ និងធ្វើរបាយការណ៍ជូននាយកសាលា។

នាយិការង មានភារកិច្ច ដូចខាងក្រោម÷

➢ ការងារថវិកា÷

- រៀបចំផែនការចំណាយប្រចាំឆ្នាំរបស់សាលា
- គ្រប់គ្រងគម្រោងចំណូលនិងចំណាយថវិកាប្រចាំឆ្នាំ តាមបែបបទនិងនីតិវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់គ្រងបញ្ជិកាគណនេយ្យ និងឯកសារផ្សេងៗ ទាក់ទងទៅនឹងចំណូល និងចំណាយរបស់សាលា
- កត់ត្រាចំណូលនិងចំណាយថវិការបស់សាលាឱ្យបានត្រឹមត្រូវ
- គ្រប់គ្រងនិងបញ្ចេញសាច់ប្រាក់ចំណាយក្នុងអង្គភាព

- ចុះបញ្ជីចេញនិងចូលសាច់ប្រាក់ និងចុះហត្ថលេខាប្រគល់ទទួល
- ទទួលខុសត្រូវចំពោះមុខអង្គភាពលើការបាត់បង់សាច់ប្រាក់ (PAP, ប្រាក់អង្គភាព, អង្គការមនុស្សធម៌ និងចំណូលពីសប្បុរសជនផ្សេងៗ)
- ធ្វើរបាយការណ៍ទូទាត់ផ្ញើទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង តាមការណែនាំ និងទាន់ពេលវេលា។

➢ **ពិនិត្យវិន័យគ្រូនិងសិស្សក្នុងសាលា÷**

- ដើរតួនាទីស្តីទី ក្នុងករណីនាយកសាលាអវត្តមាន
- គ្រប់គ្រងសកម្មភាពរៀន និងបង្រៀន ទាំងពេលចូលរៀន ចេញលេង និងចេញទៅផ្ទះ
- តាមដានពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់គ្រូ សិស្សជាប្រចាំ និងរបៀបរៀបរយក្នុងសាលា។

➢ **ពិនិត្យបញ្ជីស្នាមការងាររដ្ឋបាលរបស់ថ្នាក់÷**

- ពិនិត្យលើផែនការសកម្មភាពរបស់ថ្នាក់
- ពិនិត្យកិច្ចតែងការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល (រៀងរាល់ថ្ងៃ)
- ពិនិត្យលើតារាងទាំង៩ និងបញ្ជីទាំង៨ គ្រប់កម្រិតថ្នាក់ (ពិនិត្យនៅដើមបវេសន-កាល និងរៀងរាល់ខែ)
- ពិនិត្យ និងកែលម្អសោភ័ណភាពថ្នាក់រៀន
- ពិនិត្យលើរបាយការណ៍ថ្នាក់ជាប្រចាំខែ។

➢ **ការងារគ្រប់គ្រងបច្ចេកទេសក្នុងសាលា÷**

- ធ្វើការពិភាក្សាប្តូរយោបល់ជាមួយប្រធានបច្ចេកទេស គ្រប់កម្រិតថ្នាក់អំពីបញ្ហាប្រឈម ដូចជា ការអនុវត្តកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន ខ្លឹមសារមេរៀននីមួយៗ
- បែងចែកកម្មវិធីសិក្សាប្រចាំខែ និងឆ្នាំ
- រៀបចំកាលវិភាគបង្រៀនគ្រប់កម្រិតថ្នាក់

- ដឹកនាំការប្រជុំក្រុមបច្ចេកទេសគ្រប់កម្រិតថ្នាក់
- ចុះធ្វើអធិការកិច្ចថ្នាក់រៀនពីទី១ ដល់ទី៦
- រៀបចំវិញ្ញាសាប្រឡងឆមាសទី១ និងទី២
- រៀបចំបែងចែកកម្លាំង ពេលវេលា និងកម្រិតថ្នាក់ក្នុងការប្រឡងឆមាសនីមួយៗ
- វាយតម្លៃគ្រូឆ្នើមប្រចាំខែ ឆមាស និងឆ្នាំ
- រៀបចំពិធីជូនរង្វាន់ដល់សិស្សពូកែនៅដំណាច់ឆ្នាំសិក្សា
- រៀបចំកំណត់ហេតុ និងវាយតម្លៃគ្រូដែលធ្វើកម្មសិក្សាចប់ ដើម្បីបញ្ចូលក្នុងក្របខ័ណ្ឌរដ្ឋ។

➢ ការងារបំប៉នសិស្សខ្សោយ នៅចុងឆ្នាំសិក្សា÷

- ណែនាំគ្រូបំប៉នបន្ថែមសិស្សខ្សោយ តាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ផ្តល់ព័តិមានផ្សេងៗ និងស្រាយបំភ្លឺចម្ងល់ អំពីវិធីសាស្ត្របង្រៀនសិស្សខ្សោយរាល់សប្តាហ៍
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលបំប៉នសិស្សខ្សោយ។

លេខាធិការ មានភារកិច្ចផ្នែករដ្ឋបាលនិងបុគ្គលិក ដូចខាងក្រោម÷

➢ ផ្នែករដ្ឋបាល÷

- គ្រប់គ្រង និងចុះហត្ថលេខាចេញ ចូល
- បញ្ជូនលិខិតចេញ ចូលទៅនាយក និងផ្នែកដែលមានការពាក់ព័ន្ធទាន់ពេលនិងប្រកបដោយភាពជាម្ចាស់
- ចងក្រង និងទុកដាក់ឯកសារ
- បូកសរុបរបាយការណ៍តាមការកំណត់
- រៀបចំផែនការការងាររបស់សាលាប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ
- គ្រប់គ្រង ប្រើប្រាស់ប្រព័ន្ធទាក់ទង ដូចជា÷ កុំព្យូទ័រ អង្គុលីលេខ អាយកូម

ជាដើម

- រៀបចំគ្រប់គ្រងសាលប្រជុំ និងកន្លែងធ្វើការនៅទីចាត់ការសាលារៀន
- ធ្វើលិខិតអញ្ជើញពេលប្រជុំនាយកតាមសាលា (កម្រងសាលាវត្តបូព៌ា)។


➢ **ផ្នែកបុគ្គលិក÷**

- គ្រប់គ្រងសំណុំឯកសាររបស់បុគ្គលិក និងមន្ត្រីរបស់សាលារៀន
- គ្រប់គ្រង និងតាមដានគោលដំហរការងារ វត្តមាន អវត្តមានបុគ្គលិក និងមន្ត្រីក្នុងសាលារៀនដោយសហការជាមួយផ្នែកគ្រប់គ្រងបច្ចេកទេស គរុកោសល្យ
- គ្រប់គ្រង និងតាមដានគ្រូឈើវ៉ាំរ៉ែ គ្រូបម្រើការងារក្រៅក្របខ័ណ្ឌ បោះបង់ពុំទាន់លុបឈ្មោះ លម្ហែមាតុភាព
- គ្រប់គ្រងស្ថិតក្របខ័ណ្ឌបុគ្គលិក
- ធ្វើលិខិតសរសើរ ព្រមាន ក្នុងនាមសាលា
- គ្រប់គ្រង និងស្នើលុបឈ្មោះមន្ត្រី បុគ្គលិកបោះបង់ចោលការងារ ស្លាប់
- ធ្វើសំណើដំឡើងឋានន្តរសក្តិ និងកាំបៀវត្សជូនគ្រូនៅក្នុងអង្គភាពទៅតាមបែបបទ និងការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- វាយតម្លៃស្មើតាំងស៊ប់
- ធ្វើផែនការតម្រូវការគ្រូ និងវិធានការដោះស្រាយតម្រូវការគ្រូ
- ជ្រើសរើសមន្ត្រី បុគ្គលិកឱ្យទៅបណ្តុះបណ្តាល និងបំប៉នតាមការណែនាំរបស់ថ្នាក់លើ
- ធ្វើលិខិតឧទ្ទេសនាម លិខិតប្រគល់ភារកិច្ចជូនមន្ត្រីបុគ្គលិកដែលមាននៅក្នុងអង្គភាព។

នៅក្នុងរចនាសម្ព័ន្ធដឹកនាំ គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សាវត្តបូពិ គឺជាគណៈកម្មការ តំណាងឱ្យសហគមន៍ក្នុងការសម្របសម្រួល និងអភិវឌ្ឍសាលារៀន។ គណៈកម្មការនេះ ដឹកនាំដោយប្រធានចំនួន ១ រូប, អនុប្រធាន ចំនួន ២ រូប, លេខាធិការ ចំនួន ១ រូប, លេខាធិការរង ចំនួន ១ រូប, ហិរញ្ញិក ចំនួន ១ រូប, សមាជិក ចំនួន ៦ រូប, និងទីប្រឹក្សា ចំនួន ២ រូប។ គណៈកម្មការទ្រទ្រង់សាលារៀន មានភារកិច្ច ដូចខាងក្រោម÷

- ចូលរួមរៀបចំផែនការអភិវឌ្ឍសាលារៀន
- ស្វែងរកថវិកា ដើម្បីទ្រទ្រង់ការអភិវឌ្ឍសាលារៀន
- បំផុសចលនាមហាជន ចូលរួមគាំទ្រសាលារៀន
- ចូលរួមគ្រប់កម្មវិធីរបស់សាលា តាមការអញ្ជើញរបស់គណៈគ្រប់គ្រងសាលា។

រចនាសម្ព័ន្ធដឹកនាំសាលាបឋមសិក្សាវត្តបូពិ



ខ. រចនាសម្ព័ន្ធគ្រប់គ្រង

រចនាសម្ព័ន្ធគ្រប់គ្រងសាលាបឋមសិក្សាវត្តបូពិ ត្រូវបានចែកចេញជា ២ ក្រុម គឺ ក្រុមស្វ័យភាពទី១ និងក្រុមស្វ័យភាពទី២។

ក្រុមស្វ័យភាពទាំង ២ ដែលត្រូវបានបង្កើតក្នុងរចនាសម្ព័ន្ធខាងលើ ត្រូវទទួលបន្ទុកលើការគ្រប់គ្រងនិងការសម្របសម្រួលការបង្រៀននិងការរៀនសូត្រ ព្រមទាំងការប្រព្រឹត្តទៅនៃជីវភាពប្រចាំថ្ងៃនៃការផ្តល់សេវាអប់រំរបស់សាលា។

ក្រុមស្ម័យភាពមានចំនួន ២ ក្រុម ដោយក្រុមស្ម័យភាពមួយ ទទួលបន្ទុកវេនពេលព្រឹក ហើយក្រុមស្ម័យភាពមួយទៀត ទទួលបន្ទុកលើវេនល្ងាច។ ក្រុមស្ម័យភាពនីមួយៗ ត្រូវបានរៀបចំបន្តជា ១០ ផ្នែក រួមមាន÷

➢ **ផ្នែកបច្ចេកវិទ្យាព័ត៌មាន** មានភារកិច្ច ដូចខាងក្រោម÷

- ធានាបន្ទប់កុំព្យូទ័រមានដំណើរការជាប្រក្រតី
- រៀបចំកន្លែងដាក់សម្ភារ និងឯកសារផ្សេងៗ នៅក្នុងបន្ទប់កុំព្យូទ័រ
- ធ្វើបញ្ជីបែងចែកម៉ោងចូលរៀនរបស់សិស្សតាមកម្រិតថ្នាក់
- បែងចែកកម្មវិធីសម្រាប់សិស្សចូលបន្ទប់កុំព្យូទ័រ
- ធានានិរន្តរភាពនិងជំរុញសកម្មភាពនៃការរៀន និងបង្រៀន
- បំប៉នអំពីវិធីសាស្ត្រដល់គ្រូជាប្រចាំ
- តាមដានការប្រែប្រួលរបស់សិស្ស គ្រូ និងធ្វើរបាយការណ៍ជូនគណៈគ្រប់គ្រង
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពរៀន និងបង្រៀនប្រចាំខែ ជូនគណៈគ្រប់គ្រងសាលា។

➢ **ផ្នែកបណ្ណាល័យ** មានភារកិច្ច ដូចខាងក្រោម÷

- ធានាបណ្ណាល័យមានដំណើរការជាប្រក្រតីដើម្បីជំរុញការអានរបស់សិស្ស គ្រូ សហគមន៍
- បង្កើនប្រភេទសៀវភៅ ឯកសារផ្សេងៗ ដោយទិញទស្សនាវដ្តី និងសារព័ត៌មានដើម្បីពង្រីកនូវចំណេះដឹងទូទៅ
- រៀបចំបណ្ណាល័យ មានកន្លែងសុកសៀវភៅ និងឯកសារ ព្រមទាំងកន្លែងអានតាមបទដ្ឋានបច្ចេកទេសការងារបណ្ណាល័យ
- ធ្វើបញ្ជីវិភាគសៀវភៅសិក្សា
- ធ្វើបញ្ជីសិស្សខ្ចីសៀវភៅតាមថ្នាក់
- ប្រមូល និងធ្វើបញ្ជីសារពើភណ្ឌសៀវភៅសិក្សាប្រចាំឆ្នាំ

- បែងចែកកម្មវិធីសម្រាប់សិស្សចូលអានតាមថ្នាក់
- សម្រង់ស្ថិតិ សិស្ស គ្រូ សហគមន៍ ចូលអានប្រចាំខែ
- ត្រួតពិនិត្យការប្រើប្រាស់សៀវភៅតាមថ្នាក់រៀនដើម្បីធ្វើការកែលម្អ ថែទាំ
- ចុះលេខក្នុងសៀវភៅ និងឯកសារ។

➢ **ផ្នែកសុខភាព** មានភារកិច្ច ដូចខាងក្រោម÷

- ធានាបន្ទប់បង្រៀនមានជាសុកភាពនិងដំណើរការជាប្រក្រតី
- រៀបចំបន្ទប់បង្រៀនឱ្យមានជាសុកភាព កន្លែងស្តុកសម្ភារ និងឯកសារផ្សេងៗ
- ធ្វើបញ្ជីតាមដានជំងឺតាមកម្រិតថ្នាក់
- បែងចែកកម្មវិធីសម្រាប់សិស្សចូលឆែកសុខភាពតាមថ្នាក់
- បង្កើតគណៈកម្មាធិការក្រុមប្រឹក្សាកុមារ អប់រំទប់ស្កាត់នឹងជំងឺអេដស៍ កាមរោគ និងគ្រឿងញៀន
- ជំរុញសកម្មភាពទប់ស្កាត់នឹងជំងឺអេដស៍ ជួញដូរកុមារ និងគ្រឿងញៀន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពសុខភាពសិក្សាប្រចាំខែជូនឯកឧត្តម
- បំប៉នអំពីវិធីសាស្ត្រសង្គ្រោះបន្ទាន់ និងវិធីថែរក្សាសុខភាព វិធីព្យាបាលកម្រិតមូលដ្ឋាន
- តាមដានការប្រែប្រួលសុខភាពរបស់កុមារ និងធ្វើរបាយការណ៍ជូនឯកឧត្តមសាលា។

➢ **ផ្នែកបច្ចេកទេស** មានភារកិច្ច ដូចខាងក្រោម÷

- ដឹកនាំប្រជុំបច្ចេកទេសពាក់ព័ន្ធវិធីសាស្ត្រនៃការបង្រៀនរបស់គ្រូ និងការរៀនសូត្ររបស់សិស្ស រៀងរាល់ថ្ងៃព្រហស្បតិ៍ នៃសប្តាហ៍នីមួយៗ
- ជំរុញគ្រូលើបច្ចេកទេសនៃការបង្រៀន ដូចជាកិច្ចតែងការបង្រៀន គម្រោងមេរៀន សម្ភារឧបទេស ជាដើម
- រៀបចំផែនការសិក្សា និងកាលវិភាគបង្រៀននៃឆ្នាំសិក្សានីមួយៗ
- ជាសេនាធិការលើការងារគាំទ្រទូទៅ ជូនគ្រប់ផ្នែកនៃក្រុមស្ម័យភាព

- ចុះធ្វើអធិការកិច្ចតាមថ្នាក់ ដើម្បីជួយគ្រូតាមកម្រិតថ្នាក់នីមួយៗ
- ពង្រឹងគ្រូធ្វើថ្នាក់និទស្សន៍គ្រប់កម្រិតថ្នាក់ក្នុងមួយខែម្តង នៅរៀងរាល់ថ្ងៃព្រហស្បតិ៍សប្តាហ៍ទី៤ នៃខែនីមួយៗ។

➢ **ផ្នែកថវិកា** មានភារកិច្ច ដូចខាងក្រោម÷

- គ្រប់គ្រងថវិកាអំណោយក្នុងនិងក្រៅប្រទេស និងថវិកាចំណូលផ្ទាល់ពីការគ្រប់គ្រងសាលា
- បញ្ជាចំណាយតាមការចាំបាច់ ដោយមានការអនុញ្ញាតពីនាយកសាលា
- គ្រប់គ្រងបញ្ជិកាគណនេយ្យ និងឯកសារផ្សេងៗដែលជាប់ទាក់ទងទៅនឹងការចំណាយ
- កត់ត្រាចំណូល និងចំណាយថវិការបស់សាលាឱ្យបានត្រឹមត្រូវ
- គ្រប់គ្រង និងបញ្ចេញសាច់ប្រាក់ចំណាយក្នុងអង្គភាព
- ចុះបញ្ជីចេញ និងចូលសាច់ប្រាក់ និងចុះហត្ថលេខាប្រគល់ទទួល
- ទទួលខុសត្រូវចំពោះមុខអង្គភាពលើការបាត់បង់សាច់ប្រាក់។

➢ **ផ្នែកបរិស្ថាន** មានភារកិច្ច ដូចខាងក្រោម÷

- បែងចែងតួនាទីនិងទីតាំង នៃការទទួលខុសត្រូវរបស់គ្រូប្រចាំថ្នាក់នីមួយៗ លើការសម្អាតបរិស្ថានក្នុងបរិវេណសាលា និងក្រៅសាលា
- ណែនាំពីវិធីសាស្ត្រនៃការគ្រប់គ្រង ការបែងចែកប្រភេទ និងការកាត់បន្ថយកាក-សំណល់សំរាម។

➢ **ផ្នែកកីឡា** មានភារកិច្ច ដូចខាងក្រោម÷

- រៀបចំកម្មវិធី ឬមេរៀនស្តីពីកីឡា
- រៀបចំផែនការ ឬកាលវិភាគសិក្សាម៉ោងកីឡា សម្រាប់ថ្នាក់នីមួយៗ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពរៀន និងបង្រៀនប្រចាំខែ ជូនគណៈគ្រប់គ្រងសាលា។

➢ **ផ្នែកសណ្ដាប់ធ្នាប់** មានភារកិច្ច ដូចខាងក្រោម÷


- រៀបចំសណ្ដាប់ធ្នាប់ទូទៅទាំងក្នុងសាលា និងក្រៅសាលាឱ្យបានរៀបរយ ដូចជាកន្លែងចតយានជំនិះ កន្លែងលក់ដូរ
- រៀបចំសណ្ដាប់ធ្នាប់ និងចរាចរណ៍ជុំវិញបរិវេណសាលា
- ត្រួតពិនិត្យការស្លៀកសម្លៀកបំពាក់របស់គ្រូ និងសិស្ស
- ធានាសណ្ដាប់ធ្នាប់ទូទៅសម្រាប់កម្មវិធីផ្សេងៗ ដែលសាលារៀបចំ
- ទប់ស្កាត់ក្រុមបងធំ បងតូច ក្នុងបរិវេណសាលា
- ទប់ស្កាត់ជម្លោះគ្រប់រូបភាពជុំវិញបរិវេណសាលា
- ដាក់បម្រាមហាមសិស្សប្រើប្រាស់ទូរសព្ទដៃគ្រប់ប្រភេទ
- ត្រួតពិនិត្យអាហារ និងភេសជ្ជៈដែលសាលាហាមឃាត់លក់ដូរ និងបរិភោគជាដើម។

➢ **ផ្នែកសិល្បៈនិងតន្ត្រី** មានភារកិច្ច ដូចខាងក្រោម÷

- រៀបចំកម្មវិធី ឬមេរៀនស្ដីពីសិល្បៈនិងតន្ត្រី
- រៀបចំផែនការ ឬកាលវិភាគសិក្សាម៉ោងសិល្បៈនិងតន្ត្រី សម្រាប់ថ្នាក់នីមួយៗ
- រៀបចំកម្មវិធីបង្ហាញតន្ត្រីប្រចាំឆ្នាំរបស់សាលារៀន
- បំប៉នអំពីវិធីសាស្ត្រដល់គ្រូជាប្រចាំ និងបែងចែកភារកិច្ចជូនគ្រូទទួលបន្ទុកផ្នែកតន្ត្រីនិងសិល្បៈ
- រៀបចំកន្លែងដាក់សម្ភារ និងឧបករណ៍ផ្សេងៗនៅក្នុងបន្ទប់ហាត់សិល្បៈ
- ធានានិរន្តរភាពនិងជំរុញសកម្មភាពនៃការរៀន និងបង្រៀន
- តាមដានការប្រែប្រួលរបស់សិស្ស គ្រូ និងធ្វើរបាយការណ៍ជូនគណៈគ្រប់គ្រង
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពរៀន និងបង្រៀនប្រចាំខែ ជូនគណៈគ្រប់គ្រងសាលា។

- **ផ្នែកនីប្រឹក្សាកុមារី ក្រុមប្រឹក្សាកុមារ និងកាយវិទ្ធិ** មានមុខងារនិងភារកិច្ច ដូចខាងក្រោម÷
  - ដឹកនាំ គ្រប់គ្រង តម្រង់ទិសការងារក្រុមប្រឹក្សាកុមារ និងសិស្សកាយវិទ្ធិ
  - រៀបចំផែនការសម្រាប់សិស្សកុមារីដែលឈានចូលវ័យជំទង់
  - ប្រឹក្សាយោបល់ជូនសិស្សកុមារីដែលឈានចូលវ័យជំទង់
  - ប្រឹក្សាយោបល់ជូនសិស្សកុមារីដែលមានជួបប្រទះបញ្ហា។

រចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រងសាលាបឋមសិក្សាឥតបូពិ



ផ្នែកទី២. គុណតម្លៃរបស់សាលារៀន

ក. វិញ្ញាណរបស់អ្នកដឹកនាំ

១ មិន និង ៥ មាន គឺជាវិញ្ញាណនៃអ្នកដឹកនាំ (អ្នកដឹកនាំទាំងឡាយមិនត្រូវមានភាពអាត្មានិយម និងត្រូវប្រតិបត្តិនូវការដឹកនាំប្រកបដោយឆន្ទៈ មានភាពអត់ធ្មត់ មានការព្យាយាម មានភាពស្មោះត្រង់ និងមានការលះបង់)។

ខ. លក្ខណសម្បត្តិរបស់អ្នកដឹកនាំ

អ្នកដឹកនាំ ត្រូវមានលក្ខណសម្បត្តិចំនួន ១០ គឺ ចំណេះដឹងពិត, ឥរិយាបថថ្លៃថ្នូរ, ស្មារតីលះបង់, ការសម្រេចចិត្តចំគោលដៅ, សម្រេចផលមុនទទួលផលក្រោយ, ធ្វើជាគំរូល្អ, ភាពជាម្ចាស់, ស្មោះត្រង់និងមិនពុករលួយកេងប្រវ័ញ្ច, យុត្តិធម៌គ្មានការស្រឡាញ់ និងបង្កើតបរិយាកាសរីករាយ។

គ. គោលការណ៍ប្រចាំជីវិតរបស់អ្នកដឹកនាំ

អ្នកដឹកនាំ ត្រូវប្រកាន់ខ្ជាប់និងប្រតិបត្តិនូវគោលការណ៍ប្រចាំជីវិត ចំនួន ៨ គឺព្យាយាមរៀនជាប្រចាំ, សម្រួចឆន្ទៈ, ត្រូវមានគំនិតថ្មី, ត្រូវច្នៃប្រឌិត, សិក្សាបរិយាកាសសង្គម, ធ្វើជាគំរូ, ចាត់ទុកខ្លួនឯងជាមនុស្សមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ និងស្វែងរកកិច្ចសហការទាំងក្នុងនិងក្រៅប្រទេស។

ឃ. លក្ខណសម្បត្តិនៃសេវាអប់រំ

អ្នកផ្តល់សេវាអប់រំ ជូនដល់អ្នកទទួលសេវា រួមមានសិស្សានុសិស្ស មាតាបិតា អាណាព្យាបាល និងសហគមន៍ ត្រូវមានលក្ខណសម្បត្តិចំនួន ៥ ប្រការ គឺផ្តល់ទំនុកចិត្តដល់អ្នកទទួលសេវា, បំពេញភារកិច្ចអស់ពីសមត្ថភាព, រក្សាសមធម៌ក្នុងការសិក្សា, ចៀសវាងការកេងប្រវ័ញ្ចនិងពុករលួយ និងប្រតិបត្តិក្រមសីលធម៌គ្រូបង្រៀន។

ផ្នែកទី៣. ការគ្រប់គ្រងធនធានគ្រូបង្រៀន

ក. ព័ត៌មានទូទៅ

ក្នុងឆ្នាំសិក្សា២០១៨-២០១៩ សាលាបឋមសិក្សាវត្តបូពិ មានគ្រូបង្រៀនសរុបចំនួន ១៣០ នាក់ ក្នុងនោះមាន លោកគ្រូចំនួន ៣១ នាក់ និងអ្នកគ្រូចំនួន ៩៩ នាក់ ដែលត្រូវបង្រៀនសិស្សានុសិស្ស សរុបប្រមាណ ៦៥០០ នាក់។

នៅក្នុងការងារដឹកនាំនិងគ្រប់គ្រងធនធានគ្រូបង្រៀន ទាមទារចាំបាច់នូវគ្រូបង្រៀនមានសាមគ្គីភាព មានវិន័យ មានការជឿជាក់លើការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលា។ ដូចនេះ ដើម្បីដឹកនាំ គ្រប់គ្រង និងធ្វើយ៉ាងណាឱ្យគ្រូបង្រៀនជឿជាក់ហើយចូលរួមលើការដឹកនាំនិងចក្ខុវិស័យរបស់សាលា នាយកសាលាត្រូវធ្វើឱ្យគ្រូបង្រៀនទាំងអស់ យល់អំពីអ្វីដែលជាចក្ខុវិស័យនិងបេសកកម្មរបស់សាលានោះ ដោយនាយកសាលាបានប្រើប្រាស់យុទ្ធសាស្ត្រ ឬប្រើប្រាស់អំណាច ចំនួន ២ គឺ÷

ទី១. អំណាចវឹង÷ អំណាចវឹងនៅទីនេះ សំដៅដល់អំណាចតួនាទី គឺអំណាចជាសមត្ថកិច្ច ដែលថ្នាក់លើបានប្រគល់ឱ្យថ្នាក់ក្រោមទៅតាមវិធានិងនីតិវិធីនៃច្បាប់ជាធរមាន។ ដូចនេះ នាយកសាលាមានអំណាចបញ្ជានិងដឹកនាំទៅលើធនធានគ្រូបង្រៀននៅក្នុងសាលាដោយស្របច្បាប់។

ទី២. អំណាចស្រទន់÷ អំណាចស្រទន់ សំដៅដល់សមត្ថភាពរបស់បុគ្គលផ្ទាល់ពោលគឺសមត្ថភាពចំណេះដឹង ឥរិយាបថ ភាពជាគំរូ ដែលអំណាចនេះ នាយកសាលាត្រូវមានជាមុន និងត្រូវធ្វើមុនគេ សម្រាប់ឱ្យអ្នកក្រោមឱវាទ ប្រតិបត្តិនិងយកគំរូតាម។ ក្នុងន័យនេះ គោលការណ៍ ១ មិន ៥ មាន ជាវិញ្ញាណនៃអ្នកដឹកនាំ និងលក្ខណសម្បត្តិនៃអ្នកដឹកនាំ ទាំង ១០ ប្រការ ជាដើម សុទ្ធសឹងជាគោលការណ៍ដឹកនាំ និងសម្រួចបុគ្គលិកលក្ខណសម្បត្តិនិងភាពជាអ្នកដឹកនាំ ដែលគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនត្រូវមាន។

ខ. ការលើកកម្ពស់គុណភាពម្ហូបគ្រូបង្រៀន

ការគ្រប់គ្រងធនធានគ្រូបង្រៀន នៅសាលាបឋមសិក្សាវត្តបូពិ បានឥម្ពល់ជាធំ នូវទស្សនៈ នៃការលើកកម្ពស់គុណភាពម្ហូនៃគ្រូបង្រៀន ដែលត្រូវបានអនុវត្តតាមរយៈបេសកកម្ម ចំនួន ៣ គឺ÷

ទី១. ការកសាងនិងអភិវឌ្ឍសមត្ថភាព÷ សាលាបឋមសិក្សាវត្តបូពិ បានកំណត់លទ្ធផលថា ជោគជ័យរបស់សាលាក៏ស្ថិតនៅលើជោគជ័យនៃបុគ្គលម្នាក់ៗ ដែលជាបុគ្គលិករបស់សាលាដែរ។ ក្នុងនោះ ការពង្រឹងនិងពង្រីកសមត្ថភាពរបស់គ្រូបង្រៀន ជាចំណុចអាទិភាព។ សាលា បានកំណត់នូវគោលដៅចំនួន ៣ សម្រាប់ការកសាងនិងអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន គឺ ÷

- **គ្រូបង្រៀនម្នាក់ៗ ត្រូវមានកម្រិតអប់រំ យ៉ាងទាបបំផុតបរិញ្ញាបត្រ÷** ដើម្បីសម្រេចគោលដៅនេះ នាយកសាលា បានស្វះស្វែងរកនូវដៃគូនានា សម្រាប់ចូលរួមសហការ ក្នុងនោះ មានសាកលវិទ្យាល័យមួយចំនួន បានចូលរួមសហការជាមួយសាលា ដោយបានបញ្ចុះតម្លៃសិក្សាមួយចំនួន ជូនដល់គ្រូបង្រៀនរបស់សាលា។
- **គ្រូបង្រៀនម្នាក់ៗ ត្រូវចេះភាសាអង់គ្លេសអាចប្រើប្រាស់បាន÷** គោលដៅនេះត្រូវបានកំណត់ចេញ ដើម្បីផ្សារភ្ជាប់សង្គមផ្ទៃក្នុងសាលាទៅនឹងបរិយាកាសខាងក្រៅរបស់សាលា ពោលគឺបរិយាកាសនិងភូមិសាស្ត្ររបស់សាលា ដែលស្ថិតនៅក្នុងខេត្តមានតម្រូវការចំណេះដឹងភាសាអង់គ្លេស សម្រាប់ប្រើប្រាស់ក្នុងខេត្តសៀមរាប ដែលជាតំបន់ទេសចរណ៍។
- **គ្រូបង្រៀនម្នាក់ៗ ត្រូវចេះប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍** (Information and Communications Technology “**ICT**”) ÷ នៅក្នុងសង្គមនៃជំនាន់បដិវត្តន៍ឧស្សាហកម្មទី៤ នេះ នាយកសាលា បានកំណត់ថា គ្រូបង្រៀនម្នាក់ៗ ត្រូវចេះប្រើប្រាស់ប្រព័ន្ធ ICT ដើម្បីប្រសិទ្ធភាព នៃការបំពេញការងារ

ឆ្លើយតបបានទៅនឹងដំណើរវិវត្តនៃសង្គម និងពិភពលោក។ ទន្ទឹមនេះ សាលាបានបញ្ជូនបុគ្គលិកទទួលបន្ទុកផ្នែកព័ត៌មានវិទ្យារបស់ខ្លួន ទៅទទួលការបណ្តុះបណ្តាលបន្ថែម ទាំងក្នុងនិងក្រៅប្រទេស ដូចជាប្រទេសឥណ្ឌូនេស៊ី ជាដើម។

ទី២. ការគោរពវិន័យ÷ គ្រូបង្រៀន នៅសាលាបឋមសិក្សាវត្តបូព៌ា ត្រូវផ្តល់ភាពជាគំរូដល់សិស្សានុសិស្ស។ ក្នុងន័យនេះ គ្រូបង្រៀនខ្លួនឯង ត្រូវមានវិន័យ ដោយមានចាប់ពីការគោរពពេលវេលា ឥរិយាបថ ពាក្យសំដី និងឯកសណ្ឋាន ជាដើម។

ទី៣. ការលើកទឹកចិត្ត÷ ការលើកទឹកចិត្តចំពោះគ្រូបង្រៀន មានចំនួន ៤ ទម្រង់គឺ÷

- **ទី១ "ការបណ្តុះបណ្តាល"** ÷ ដូចបានលើកឡើងក្នុងចំណុចទី១ គឺការលើកទឹកចិត្តតាមរយៈការបញ្ជូនទៅបណ្តុះបណ្តាលនៅក្នុងជំនាញផ្សេងៗ ទាំងក្នុងនិងក្រៅប្រទេស។
- **ទី២ "ការសរសើរ"** ÷ គ្រូបង្រៀនដែលមានស្នាដៃល្អ ទាំងក្នុងក្របខ័ណ្ឌសាលា ក្របខ័ណ្ឌខេត្ត និងក្របខ័ណ្ឌក្រសួង តែងតែទទួលបានការលើកទឹកចិត្តជាការសរសើររបស់នាយកសាលា ដោយផ្ទាល់មាត់នៅក្នុងកិច្ចប្រជុំផ្សេងៗ និងជាលាយលក្ខណ៍អក្សរជាដើម។ ទន្ទឹមនេះ គ្រូបង្រៀនឆ្នើម ក៏ទទួលបានការលើកទឹកចិត្តបន្ថែមពីក្រសួងអប់រំ យុវជន និងកីឡា តាមរយៈការដំឡើងកាំបៀវត្ស និងពានរង្វាន់គ្រូឆ្នើម ជាដើម។
- **ទី៣ "ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ"** ÷ ក្រៅពីប្រាក់បៀវត្សមន្ត្រីរាជការប្រចាំខែ គ្រូបង្រៀនសាលាបឋមសិក្សាវត្តបូព៌ា បានទទួលការឧបត្ថម្ភលើកទឹកចិត្តបន្ថែម ជាថវិកា ពីឪពុកម្តាយសិស្ស ជារបបប្រចាំសប្តាហ៍ គឺបើកនៅរៀងរាល់ថ្ងៃព្រហស្បតិ៍។ ទន្ទឹមនេះ ក៏មានន្ទរបបឧបត្ថម្ភផ្នែកសង្គមកិច្ចផងដែរ ជូនចំពោះបុគ្គលិកគ្រូបង្រៀនដែលមានតម្រូវការ ដូចជា ករណីគ្រូបង្រៀនមានផ្ទៃពោះជាដើម។
- **ទី៤"ការកម្សាន្ត"** ÷ សាលាបឋមសិក្សាវត្តបូព៌ា តែងរៀបចំឱ្យមានកម្មវិធីជប់លៀង

យ៉ាងតិច មួយឆ្នាំ ២ ដង។ ក្រៅពីនេះ មានកម្មវិធីលើកទឹកចិត្តសម្តែងកតញ្ញូ-តាធម៌ជូនគ្រូចូលនិវត្តន៍ និងនាយិកាចូលនិវត្តន៍ ជាដើម។ ជាងនេះទៅទៀត កម្មវិធីដំណើរកម្សាន្តប្រចាំឆ្នាំ ទៅតាមបណ្តាខេត្ត ឬក្រៅប្រទេស ក៏ត្រូវបានរៀបចំផងដែរ ដោយមានការឧបត្ថម្ភជាប្រចាំពីមូលនិធិពញ្ញាវិលី។

ផ្នែកទី៤. ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ

ក. របបប្រជុំ

របបប្រជុំ នៅក្នុងសាលាបឋមសិក្សាវត្តបូព៌ មាន ៣ ប្រភេទ គឺ កិច្ចប្រជុំបច្ចេកទេស, កិច្ចប្រជុំដើមសប្តាហ៍ និងកិច្ចប្រជុំវិសាមញ្ញ។

ទី១. កិច្ចប្រជុំបច្ចេកទេស គឺជាកិច្ចប្រជុំពិនិត្យពិភាក្សាលើបញ្ហាប្រឈម និងស្វែងរកដំណោះស្រាយកែលម្អវិធីសាស្ត្រនៃការបង្រៀន, ការរៀបចំនិងអនុវត្តកម្មវិធីសិក្សា, ខ្លឹមសារមេរៀន និងការរៀនសូត្ររបស់សិស្សានុសិស្ស។ កិច្ចប្រជុំបច្ចេកទេស មាន ២ ប្រភេទគឺ កិច្ចប្រជុំបច្ចេកទេសប្រចាំសាលាបឋមសិក្សាវត្តបូព៌ និងកិច្ចប្រជុំបច្ចេកទេសកម្រិតកម្រងសាលាវត្តបូព៌។

ចំពោះកិច្ចប្រជុំបច្ចេកទេសប្រចាំសាលាបឋមសិក្សាវត្តបូព៌ ប្រព្រឹត្តទៅរៀងរាល់ថ្ងៃព្រហស្បតិ៍ នៃសប្តាហ៍ទី១ សប្តាហ៍ទី២ និងសប្តាហ៍ទី៣ នៃខែនីមួយៗ ដែលដឹកនាំដោយនាយកសាលា ឬនាយករង ឬនាយិការង ដោយមានការចូលរួមពីសមាជិកក្រុមស្វ័យភាពនីមួយៗ។ ក្នុងករណីចាំបាច់ ប្រធានក្រុមបច្ចេកទេសនៃក្រុមស្វ័យភាព ឬប្រធានក្រុមស្វ័យភាព អាចធ្វើការដឹកនាំកិច្ចប្រជុំបច្ចេកទេសផ្ទាល់ ដោយមានការអនុញ្ញាតពីនាយកសាលា។ របៀបវារៈនៃកិច្ចប្រជុំប្រចាំសប្តាហ៍នីមួយៗ ត្រូវបានកំណត់ ដូចខាងក្រោម÷

- សប្តាហ៍ទីមួយ÷ ផ្តល់ដំបូន្មានគរុកោសល្យ ឬមាតិកានៃការបង្ហាញសម្ភារឧបទេស។
- សប្តាហ៍ទីពីរ÷ ប្រជុំកសាងសម្ភារឧបទេសតាមកម្រិតថ្នាក់នៃក្រុមបច្ចេកទេសនីមួយៗ។
- សប្តាហ៍ទីបី÷ ប្រជុំកសាងកិច្ចតែងការតាមសម្ភារឧបទេសដែលបានកសាង។

ចំពោះកិច្ចប្រជុំបច្ចេកទេសកម្រិតកម្រងសាលាវត្តបូព៌ គឺប្រព្រឹត្តឡើងនៅរៀងរាល់ថ្ងៃព្រហស្បតិ៍ នៃសប្តាហ៍ទីបួន នៃខែនីមួយៗ ក្នុងកម្រិតកម្រងសាលាវត្តបូព៌ រួមមានសាលាបឋមសិក្សាវត្តបូព៌ សាលាបឋមសិក្សាវត្តដំណាក់ សាលាបឋមសិក្សាវត្តស្វាយ សាលាបឋមសិក្សាជន្លង់ សាលាបឋមសិក្សាខ្នារ សាលាបឋមសិក្សាជ្រាវ និងសាលាបឋមសិក្សាតាពេជ្រ។ រៀងរាល់ដំណាច់ឆ្នាំសិក្សានីមួយៗ ប្រធានកម្រងសាលាវត្តបូព៌ នឹងដឹកនាំកិច្ចប្រជុំក្នុងកម្រិតកម្រង ដើម្បីរៀបចំផែនការនិងកាលវិភាគសម្រាប់ប្រជុំបច្ចេកទេស នៅឆ្នាំបន្ទាប់។ កិច្ចប្រជុំបច្ចេកទេសកម្រិតកម្រងសាលាវត្តបូព៌នេះ គឺត្រូវដឹកនាំដោយប្រធានកម្រង និងមានការចូលរួមពីគ្រប់សមាជិកទាំងអស់នៃកម្រងសាលាវត្តបូព៌ ដើម្បីពិនិត្យពិភាក្សាលើបច្ចេកទេសបង្រៀន និងការបង្ហាញថ្នាក់និទស្សន៍។

ទី២. កិច្ចប្រជុំដើមសប្តាហ៍ គឺជាកិច្ចប្រជុំសាមញ្ញ រៀបចំឡើងដើម្បីពិនិត្យពិភាក្សាលើបញ្ហាប្រឈម និងស្វែងរកដំណោះស្រាយ ពាក់ព័ន្ធការបង្រៀននិងការរៀនសូត្ររបស់សិស្ស ដែលបានប្រព្រឹត្តទៅរយៈពេល ១ សប្តាហ៍កន្លងទៅ។ កិច្ចប្រជុំនេះ រៀបចំឡើងរៀងរាល់សប្តាហ៍គឺ ថ្ងៃច័ន្ទ ម៉ោង ៦:១៥ នាទី ព្រឹក សម្រាប់ក្រុមស្ម័យភាពវេនព្រឹក និងម៉ោង ១២:៣០ នាទី រសៀល សម្រាប់ក្រុមស្ម័យភាពវេនរសៀល ពោលគឺកិច្ចប្រជុំនេះប្រព្រឹត្តឡើងមុនពេលចាប់ផ្តើមការបង្រៀននិងការសិក្សារបស់សិស្ស។ ប្រធានក្រុមស្ម័យភាពនីមួយៗ មានកាតព្វកិច្ចដឹកនាំកិច្ចប្រជុំដើមសប្តាហ៍ផ្ទាល់ ដោយមានការចូលរួមពីនាយកសាលា និង/ឬនាយករងតាមការចាំបាច់, គ្រប់ប្រធានផ្នែកនៃក្រុមស្ម័យភាព និងសមាជិកក្រុមស្ម័យភាពទាំងអស់ ព្រមទាំងក្រុមប្រឹក្សាកុមារប្រចាំសាលាផងដែរ។ ក្នុងករណីចាំបាច់ នាយកសាលា ឬនាយករង នឹងដឹកនាំកិច្ចប្រជុំដើមសប្តាហ៍ផ្ទាល់។

សមាជិកនៃកិច្ចប្រជុំ អាចលើកឡើងនូវគ្រប់បញ្ហា និងសំណើដំណោះស្រាយនានាពាក់ព័ន្ធកិច្ចដំណើរការនៃការបង្រៀននិងការរៀនសូត្ររបស់សិស្ស សំដៅធ្វើយ៉ាងណាឱ្យការបង្រៀននិងការរៀនសូត្ររបស់សិស្ស ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។ ប្រធានក្រុមស្ម័យភាព មានកាតព្វកិច្ចបូកសរុបលទ្ធផលនៃកិច្ចប្រជុំ និងដាក់ចេញជាយន្តការ

ដោះស្រាយនូវបញ្ហាប្រឈមនានា ដែលបានលើកឡើងដោយសមាជិក។ ទន្ទឹមនេះ រៀងរាល់ពេល មុននឹងបញ្ចប់កិច្ចប្រជុំដើមសប្តាហ៍នេះ នាយកសាលា ឬនាយករង នឹងចូលរួមបូកសរុបលទ្ធផលនៃកិច្ចប្រជុំ ដើម្បីបំពេញបន្ថែមរាល់ចំណុចខ្វះខាត។

កិច្ចប្រជុំដើមសប្តាហ៍នេះ គឺជាវិធីសាស្ត្រដឹកនាំនិងគ្រប់គ្រងបែបវិមជ្ឈការ ដែលគណៈគ្រប់គ្រងសាលា ផ្តល់សិទ្ធិអំណាចនិងការសម្រេចចិត្ត ជូនលោកគ្រូ អ្នកគ្រូផ្ទាល់និងមានការទទួលខុសត្រូវរៀងៗខ្លួន។

ទី៣. កិច្ចប្រជុំវិសាមញ្ញ ប្រព្រឹត្តទៅក្នុងករណីចាំបាច់ណាមួយ ដែលនាយកសាលាអាចកោះហៅសមាជិកចូលរួមកិច្ចប្រជុំជាបន្ទាន់បាន ដើម្បីពិនិត្យពិភាក្សាលើបញ្ហាប្រឈមនិងដាក់ចេញនូវយន្តការដោះស្រាយបន្ទាន់ ជាយថាហេតុ។

ខ. ការកសាងផែនការ

ការរៀបចំផែនការថវិការបស់សាលាបឋមសិក្សាវត្តបូពិ គឺអនុលោមតាមវិធាននិងនីតិវិធីជាធរមាន នៃការរៀបចំថវិកាជាតិ ដូចសាលាផ្សេងៗផងដែរ ក្រោមការដឹកនាំចាត់ចែង និងសម្របសម្រួលរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡាខេត្តសៀមរាប ជាសេនាធិការ។ នៅក្នុងផែនការថវិកាប្រចាំឆ្នាំរបស់សាលា មិនមានជាក់បញ្ចូល នូវថវិកាជាអំណោយរបស់សប្បុរសជន ដែលទទួលបានតាមការអំពាវនាវរបស់នាយកសាលាបឋមសិក្សានោះឡើយ។ ទោះយ៉ាងណា ចំណូល និងចំណាយទាំងអស់ រួមទាំងថវិកាជាអំណោយរបស់សប្បុរសជន ត្រូវបានរាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធដែលមានសមត្ថកិច្ច ឱ្យបានគ្រប់ជ្រុងជ្រោយ ដោយត្រូវបិទផ្សព្វផ្សាយជាសាធារណៈនៅមុខខ្លោងទ្វារសាលាផងដែរ។

គ. ប្រភពថវិកា

ថវិកានៅក្នុងការគ្រប់គ្រងសាលាបឋមសិក្សាវត្តបូពិ មានប្រភពយ៉ាងតិច ចំនួន ៣ សំខាន់ៗ គឺ÷

ទី១. ថវិកាជាតិ÷ ថវិកាជាតិ ដែលបានផ្តល់ទៅឱ្យសាលាបឋមសិក្សាវត្តបូពិ ក៏ដូចជា

សាលាបឋមសិក្សាផ្សេងទៀត នៅទូទាំងប្រទេស ផងដែរ គឺមានប្រមាណ ៦០ លាន រៀល ក្នុងមួយឆ្នាំ។

ទី២. ថវិកាអំណោយ÷ មានប្រភពសំខាន់មកពីសប្បុរសជនផ្សេងៗ ដែលមានទាំង ក្នុងនិងក្រៅប្រទេស។ ថវិកាអំណោយក្នុងប្រទេស ទទួលបានពីសប្បុរសជនផ្សេងៗ ដែល បានមកតាមរយៈការអំពាវនាវរបស់សាលា តាមរយៈការរៀបចំកម្មវិធីផ្សេងៗ ដូចជា បុណ្យ ផ្កាប្រាក់សាមគ្គី, ទិវាអប់រំសិល្បៈតន្ត្រីសិស្សប្រចាំឆ្នាំ និងការឧបត្ថម្ភផ្ទាល់ពីមាតាបិតាសិស្ស នៅក្នុងពេលប្រជុំប្រចាំឆ្នាំ និងការទទួលបានពីសប្បុរសជនដែលបានបរិច្ចាគជូនសាលា ជា ដើម។ ជាងនេះទៅទៀត ថវិកាអំណោយក្រៅប្រទេស បានទទួលមកពីសប្បុរសជន នៃបណ្តាប្រទេសសំខាន់ៗមួយចំនួន ដូចជាប្រទេសថៃ ប្រទេសកូរ៉េ ប្រទេសជប៉ុន ជា ដើម។

ទី៣. ថវិកាចំណូលផ្ទាល់ពីការគ្រប់គ្រងសាលា÷ សាលាបឋមសិក្សាវត្តបូពិ ក៏មានន្ទូវ ចំណែកតូចនៃថវិកា ដើម្បីរួមចំណែកទ្រទ្រង់នូវកិច្ចដំណើរការរបស់ខ្លួនផងដែរ ដែលបាន មកពីថវិកាលើអាជីវកម្មរបស់អាជីវករនៅក្នុងសាលារៀន, ថវិកាលើសេវាដឹកជញ្ជូនសិស្ស និងថវិកាបានពីការលក់កាកសំណល់ (អេតចាយ)។

ឃ. ការគ្រប់គ្រងថវិកា

ដើម្បីធានាការគ្រប់គ្រងថវិកាប្រកបដោយប្រសិទ្ធភាព និងតម្លាភាព សាលាបឋមសិក្សា វត្តបូពិ មានគណៈកម្មការ ចំនួន ២ គឺ÷

ទី១. គណៈកម្មការអចិន្ត្រៃយ៍គ្រប់គ្រងថវិកា÷ គ្រប់គ្រងថវិកា PB, SIG, អាជីវករ។

ទី២. គណៈកម្មការគ្រប់គ្រងថវិការយៈពេលខ្លី÷ (រំសាយក្រោយពេលបិទបញ្ជីទូទាត់ រួច)។

គណៈកម្មការគ្រប់គ្រងថវិកា មានភារកិច្ចរៀបចំឯកសារទូទាត់សងបំណុល ឬការ ចំណាយផ្សេងៗ ព្រមទាំងដាក់ស្នើសុំការសម្រេច និងឯកភាពពីនាយកសាលា។ ក្រោយពី ទូទាត់ចំណាយរួច គណៈកម្មការនេះមានភារកិច្ចផ្សព្វផ្សាយ ដោយបិទផ្សាយនូវលទ្ធផល

ចំណូលនិងចំណាយ ជូនជាសាធារណៈ។

៦. ការប្រើប្រាស់ថវិកា

ទស្សនៈនៃការគ្រប់គ្រងថវិការបស់សាលាបឋមសិក្សាវត្តបូពិ គឺស្ថិយភាពហិរញ្ញវត្ថុ ឬ ស្ថិយភាពថវិកា ដែលនេះគឺជាកត្តាកំណត់ជោគជ័យ នៃការគ្រប់គ្រងសាលាបឋមសិក្សាវត្តបូពិតែម្តង។

រូបមន្តនៅក្នុងការប្រើប្រាស់ថវិការបស់សាលា ជាពិសេស លោកនាយក ពីង គិមឆេន ផ្ទាល់តែម្តង មានគោលការណ៍ចំនួន ៣ គឺ÷ គុណភាពល្អ តម្លៃថោក និងអាចជំពាក់បាន។

ជំពូកទី២. សិស្សានុសិស្ស

ផ្នែកទី១. ការអប់រំសមាសភាគទាំង ៥

សីលធម៌ល្អ អាចត្រូវបានបណ្តុះឡើងបាន លុះត្រាតែមានការអប់រំសមាសភាគទាំង ៥ គឺការអប់រំបញ្ញា ការអប់រំពលកម្ម ការអប់រំសោភ័ណ ការអប់រំសិល្បៈ និងការអប់រំកាយ និងកីឡា។ កាលណាសិស្សានុសិស្ស ប្រតិបត្តិបានខ្ជាប់ខ្ជួននូវការអប់រំសមាសភាគទាំង ៥ បានល្អប្រសើរនោះ នឹងទទួលបានសីលធម៌ល្អនិងមានសន្តិភាពទាំងផ្លូវកាយ ក្រៅផ្លូវកាយ និងផ្លូវចិត្ត។

ក. ការអប់រំបញ្ញា

បណ្តុះវិជ្ជា បណ្តាលឱ្យកើនបញ្ញា បណ្តុះយ៉ាងណាឱ្យសិស្សានុសិស្សក្លាយជាមនុស្សល្អពិតប្រាកដ។ ការអប់រំបញ្ញានៅក្នុងសាលាបឋមសិក្សាវត្តបូពិ បានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាគន្លឹះៗ និងគ្រប់កម្រិតថ្នាក់សិក្សា ចាប់ពីកម្រិតថ្នាក់មត្តេយ្យ រហូតដល់កម្រិតថ្នាក់ទី៦។

ការអប់រំបញ្ញា ផ្តោតសំខាន់លើមុខវិជ្ជាសំខាន់ៗចំនួន ៤ គឺ ផ្នែកភាសាខ្មែរ ផ្នែកគណិតវិទ្យា ផ្នែកសិក្សាសង្គម និងផ្នែកវិទ្យាសាស្ត្រ ដែលបានកំណត់ដោយកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។

ចំណេះដឹងគឺគ្មានដែនកំណត់ ចង់ចេះប្រាកដរៀនគ្មានឈប់ឈរ គឺជាកត្តាចាំបាច់ដែលសាលាបានបង្កើតនូវកម្មវិធីសិក្សាភាសាបរទេស និងកម្មវិធីសិក្សាបច្ចេកវិទ្យាព័ត៌មានសម្រាប់សិស្សានុសិស្ស ទុកជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍសមត្ថភាពផ្នែកបញ្ញា។

ការអប់រំបញ្ញាផ្នែកភាសាបរទេស ផ្តោតសំខាន់ទៅលើការសិក្សាភាសាអង់គ្លេស និងភាសាបារាំង ជាអាទិភាព ដែលភាសាបរទេសទាំងពីរប្រភេទនេះ ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់សាលាអស់រយៈពេល ២១ ឆ្នាំ មកហើយ។ ថ្នាក់ភាសាអង់គ្លេស មានចាប់ពីកម្រិតថ្នាក់ទី៣ ដល់ថ្នាក់ទី៦ និងថ្នាក់ភាសាបារាំងមានចាប់ពីកម្រិតថ្នាក់ទី៤ ដល់ថ្នាក់ទី៦។

ទន្ទឹមនឹងនេះ កម្មវិធីសិក្សាថ្នាក់ភាសាជប៉ុន និងភាសាចិន នឹងត្រូវដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់សាលានាពេលខាងមុខផងដែរ ដោយតាមរយៈកិច្ចសហការរវាងសាលា និងអ្នកស្ម័គ្រចិត្តជាតិនិងអន្តរជាតិនានា។

ទន្ទឹមនេះ ការអប់រំបញ្ញាផ្នែកបច្ចេកវិទ្យាព័ត៌មាន ត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សារបស់សាលា ចាប់ពីកម្រិតថ្នាក់ទី៣ ដល់ថ្នាក់ទី៦។ កម្មវិធីសិក្សាថ្នាក់កុំព្យូទ័រ បាននិងកំពុងសិក្សាដោយសិស្សានុសិស្សនៃសាលាបឋមសិក្សាវត្តបូព៌ អស់រយៈពេលជាង ១០ ឆ្នាំ មកហើយ។ ការបង្កើតកម្មវិធីសិក្សាថ្នាក់កុំព្យូទ័រនេះឡើង ក្នុងគោលបំណងបណ្តុះបញ្ញារបស់សិស្សានុសិស្ស ឱ្យបានយល់ដឹងពីអត្ថប្រយោជន៍នៃការប្រើប្រាស់កុំព្យូទ័រ ក៏ដូចជាកម្មវិធីបច្ចេកវិទ្យាព័ត៌មាននានា។

២. ការអប់រំពលកម្ម

ការអប់រំពលកម្ម មិនសំដៅទៅលើការអប់រំដោយការប្រើប្រាស់កម្លាំងតែម្យ៉ាងនោះទេ ពោលគឺសំដៅលើការអប់រំបរិស្ថាន និងការអប់រំកសិកម្ម។

២.១. ការអប់រំបរិស្ថាន

សាលារៀនល្អកុំទាន់ថាស្អាត បើគ្រប់គ្នាមិនសង្វាតជាប្រចាំ ប្រៀបដូចការអប់រំបរិស្ថានដែលជោគជ័យ មកពីស្មាដៃនៃអ្នកចូលរួម។ ដូចនេះ ការអប់រំបរិស្ថានដល់សិស្សានុសិស្ស ឱ្យចូលរួមក្នុងកិច្ចការពារនិងថែរក្សាបរិស្ថាន គឺជាកិច្ចការដ៏មានសារៈសំខាន់ សម្រាប់បណ្តុះបណ្តាលស្មារតីនៃការស្រឡាញ់និងថែរក្សាបរិស្ថានទៅដល់សិស្សានុសិស្ស។ ក្នុងន័យនេះ ការអប់រំបរិស្ថាន មាន ២ ប្រភេទគឺ បរិស្ថានបុគ្គល និងបរិស្ថានសង្គម។

២.១.១. បរិស្ថានបុគ្គល

ការអប់រំផ្នែកបរិស្ថានបុគ្គល សំដៅទៅលើការអប់រំបរិស្ថានធម្មជាតិ និងបរិស្ថានខ្លួនប្រាណ ដែលត្រូវគិតពីបរិស្ថានក្នុងសាលា និងបុគ្គលខ្លួនឯងផ្ទាល់តែម្តង។

ចំពោះបរិស្ថានធម្មជាតិសម្រាប់កម្រិតផ្នែកក្នុងសាលា គឺ ចែកចេញជា ៣ កម្រិត រួមមាន÷

កម្រិតទី១. ការបង្រៀនសិស្សឱ្យចេះចោលសំរាម ពោលគឺសិស្សានុសិស្សត្រូវចេះចោលសំរាមទៅក្នុងធុងសំរាម។

កម្រិតទី២. ការបង្រៀនសិស្សឱ្យចេះញែកសំរាមមានប្រយោជន៍ និងគ្មានប្រយោជន៍ ពោលគឺសិស្សានុសិស្ស ត្រូវចេះញែកសំរាមដែលអាចកែច្នៃបាន និងមិនអាចកែច្នៃបាន។

កម្រិតទី៣. ការបង្រៀនសិស្សឱ្យចេះកាត់បន្ថយកាកសំណល់ និងគ្រប់គ្រងកាកសំណល់ដែលជារបស់ខ្លួនឯង ពោលគឺសិស្សានុសិស្ស ត្រូវទុកដាក់និងរក្សាទុកនូវសំរាមដែលជារបស់ខ្លួន ទៅក្នុងកាតាបរបស់ខ្លួន។ ហេតុនេះហើយ បានជានៅក្នុងបរិវេណសាលាបឋមសិក្សាវត្តបូពិ ពុំសូវមានធុងសំរាមឡើយ។

ការអប់រំផ្នែកបរិស្ថានខ្លួនប្រាណ គឺការអប់រំឱ្យសិស្សានុសិស្សចេះរៀបចំនិងសម្អាតខ្លួនប្រាណក្នុងពេលសិក្សាឱ្យបានស្អាតជានិច្ច ដើម្បីថែរក្សាសុខភាពផ្ទាល់ខ្លួន និងចៀសវាងការបង្កបរិស្ថានមិនល្អក្នុងពេលរៀនសូត្រ ដល់អ្នកនៅជុំវិញខ្លួន។

២.១.២. បរិស្ថានសង្គម

ការអប់រំបរិស្ថានសង្គម ត្រូវបានបំពាក់បំប៉នដល់សិស្សានុសិស្ស ដោយផ្តោតសំខាន់លើការបណ្តុះស្មារតីឱ្យចេះយកចិត្តទុកដាក់ និងមានកង្វល់ពីបញ្ហាបរិស្ថាននៅក្នុងសង្គមជាតិទាំងមូល ទន្ទឹមនឹងការចេះគិតគូរថែរក្សាបរិស្ថាននៅក្នុងសាលា។ លោកគ្រូ អ្នកគ្រូតែងតែធ្វើការបង្រៀននិងពន្យល់អំពីផលប៉ះពាល់នៃការបំពុលបរិស្ថាន វិធីសាស្ត្រនៃការគ្រប់គ្រងកាកសំណល់និងការកាត់បន្ថយកាកសំណល់ជាដើម។ តាមរយៈការបណ្តុះស្មារតីនិងអប់រំឱ្យចេះស្រឡាញ់បរិស្ថាន ជានិច្ចកាល សិស្សានុសិស្សនៃសាលាបឋមសិក្សាវត្តបូពិបានចូលរួមធ្វើការសម្អាតបរិស្ថាននៅតាមដងផ្លូវសាធារណៈ តំបន់ប្រាសាទ និងវត្តអារាមជាដើម។

២.២. ការអប់រំផ្នែកកសិកម្ម

ការអប់រំផ្នែកកសិកម្ម គឺជាផ្នែកមួយនៃការអប់រំពលកម្ម។ ការអប់រំកសិកម្ម គឺជាការអប់រំមួយបែប ដែលបង្រៀនឱ្យសិស្សានុសិស្សចេះដាំដំណាំគ្រប់ប្រភេទ។ ទន្ទឹមនេះ សិស្សា-

នុសិស្ស ត្រូវធ្វើការសិក្សាស្ទង់ស្រាវជ្រាវ អំពីវិធីសាស្ត្រនៃការដាំដំណាំ តាមរយៈសហគមន៍ដែលខ្លួនរស់នៅផ្ទាល់ ដោយមិនប្រើប្រាស់ទូរជីគីមី ថ្នាំគីមី ឬសារធាតុគីមីឡើយ។

ការអប់រំបែបនេះ នឹងបណ្តុះទម្លាប់ឱ្យសិស្សចេះស្រឡាញ់ ការពារ ថែរក្សារុក្ខជាតិ ព្រមទាំងយល់ដឹងអំពីការកាត់បន្ថយការបំពុល និងការបំផ្លាញធម្មជាតិ តាមរយៈការដាំដើមឈើ និងរុក្ខជាតិផ្សេងៗ ដើម្បីរួមចំណែកជួយកាត់បន្ថយផលប៉ះពាល់សុខភាព និងលើកកម្ពស់ជីវភាពគ្រួសារ និងសង្គមជាតិទាំងមូល។

សាលាបឋមសិក្សាវត្តបូពិ តែងតែរៀបចំកម្មវិធីតាំងពិព័រណ៍ដំណាំកសិកម្មធម្មជាតិ ដោយមិនប្រើប្រាស់ថ្នាំគីមីនិងជីគីមី ដែលបានសិក្សាស្រាវជ្រាវនិងដាំដោយសិស្សានុសិស្ស នៃសាលាបឋមសិក្សាវត្តបូពិផ្ទាល់ មកបង្ហាញក្នុងកម្មវិធីតាំងពិព័រណ៍នេះ។

គ. ការអប់រំសិល្បៈ

ការអប់រំសិល្បៈ សំដៅទៅលើការអប់រំផ្នែកច្រៀង វាំរបាំ លេងតូរ្យតន្ត្រី គូររូប និពន្ធទំនុកច្រៀង និងសម្តែង ជាដើម។ ការអប់រំសិល្បៈ ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាលា និងដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើបដិសណ្ឋារកិច្ចរបស់សាលា សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ ដែលបានមកធ្វើទស្សនកិច្ចសិក្សានៅសាលាបឋមសិក្សាវត្តបូពិ។

ការអប់រំសិល្បៈ ត្រូវបានបង្ហាត់និងបង្រៀនផ្ទាល់ដោយលោកគ្រូ និងអ្នកគ្រូ នៃសាលាបឋមសិក្សាវត្តបូពិ។ គួរគូសបញ្ជាក់ផងដែរថា ក្រោមការដឹកនាំនិងគ្រប់គ្រងរបស់លោកនាយកសាលា លោកគ្រូ អ្នកគ្រូ នៃសាលាបឋមសិក្សាវត្តបូពិ មិនត្រឹមតែមានសមត្ថភាពក្នុងការអប់រំបញ្ញា អប់រំបរិស្ថាន ការអប់រំកាយនិងកីឡា និងការអប់រំសោភ័ណនោះទេ ចំណេះដឹងផ្នែកសិល្បៈត្រូវបានបំពាក់បំប៉ន ជូនលោកគ្រូ អ្នកគ្រូ តាមរយៈកិច្ច-សហការរបស់ដៃគូជាតិ និងអន្តរជាតិនានា។ ក្នុងន័យនេះ លោកគ្រូ និងអ្នកគ្រូ ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្រៀនសិស្សានុសិស្សឱ្យចេះវាំរបាំ លេងតូរ្យតន្ត្រី ច្រៀង សម្តែង និពន្ធទំនុកច្រៀង និងគូររូប ជាដើម។

យើងសង្កេតឃើញថា រាល់ការរៀបចំកម្មវិធីនានារបស់សាលា ព្រមទាំងការទទួល

ភ្ញៀវជាតិ ឬអន្តរជាតិ សិស្សានុសិស្សនៃសាលាបឋមសិក្សាវត្តបូព៌ គឺជាអ្នកលេងតូរ្យតន្ត្រី ច្រៀង សម្តែងផ្ទាល់តែម្តង ប្រកបដោយចំណេះជំនាញយ៉ាងច្បាស់លាស់។

ឃ. ការអប់រំកាយនិងកីឡា

ការអប់រំកាយនិងកីឡាសម្រាប់សិស្សានុសិស្ស នៃសាលាបឋមសិក្សាវត្តបូព៌ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងប្រព័ន្ធអប់រំរបស់សាលា ដែលមានចាប់ពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី៦ ជ្បិតការអប់រំនេះ នឹងផ្តល់ឱកាសដល់សិស្សានុសិស្ស ក្នុងការអភិវឌ្ឍនិងអប់រំចំណេះដឹងផ្នែកសុខភាពរូបរាងកាយ អាកប្បកិរិយា និងរបៀបរស់នៅក្នុងសង្គមជាដើម។

សម្លៀកបំពាក់ពណិទឹកក្រូច និងមានផ្លាកសញ្ញាសម្គាល់របស់សាលា អមជាមួយស្បែកជើងឃ្លុបពណិស គឺជាឈុតសម្លៀកបំពាក់កីឡារបស់សាលាបឋមសិក្សាវត្តបូព៌ ដែលសិស្សានុសិស្ស ត្រូវស្លៀកពាក់រៀងរាល់ម៉ោងសិក្សាកីឡា។ ការអប់រំកាយនិងកីឡា ចំពោះសិស្សានុសិស្ស មានដូចជា ការធ្វើអត្តពលកម្ម បាល់បោះ បាល់ទះ បាល់ទាត់ ការអប់រំកាយជាមួយចង្វាក់ភ្លេង និងកាយសម្ព័ន្ធ ជាដើម។

ឈ្នះគ្នាដោយកិច្ចសហការការងារជាក្រុម ដោយសាមគ្គី និងអ្វីដែលឈ្នះធំបំផុតគឺសុខភាព ដែលរៀងរាល់ឆ្នាំ ទិវាអប់រំកាយនិងកីឡាប្រចាំឆ្នាំ តែងតែត្រូវបានប្រារព្ធឡើងនៅក្នុងសាលាបឋមសិក្សាវត្តបូព៌ ដែលអនុញ្ញាតឱ្យសិស្សធ្វើការប្រកួតប្រជែងលេងកីឡានានា ដោយប្រើប្រាស់ស្មារតីជាក្រុមនិងប្រកបដោយសាមគ្គីភាព។

ង. ការអប់រំសោភ័ណ

សុភាវធម៌និងតំរិយាបថថ្លៃថ្នូរ គឺជាកញ្ចក់ឆ្លុះបញ្ចាំងនូវការគោរពវិន័យ របស់សាលាបឋមសិក្សាវត្តបូព៌ ដែលជាស្នូលគ្រឹះនៃការអប់រំសោភ័ណ។

សិស្សានុសិស្សនៃសាលាបឋមសិក្សាវត្តបូព៌ ត្រូវបានបង្រៀននិងអប់រំ ឱ្យមានសុភាវធម៌ល្អ ចេះគោរពចាស់ព្រឹទ្ធាចារ្យ និងប្រកាន់ខ្ជាប់នូវតំរិយាបថថ្លៃថ្នូរ ក្នុងការរស់នៅក្នុងសង្គម ទាំងការ **"ដេក ដើរ ឈរ អង្គុយ"** ដោយសិស្សានុសិស្ស ត្រូវប្រើប្រាស់តំរិយាបថទាំងបួននេះប្រកបដោយភាពសមរម្យ សុជីវធម៌ មិនឆ្គាំឆ្គង ដោយអំណរ និងមិនស្តាយក្រោយ។

ផ្នែកទី២. សាសនា និងការអប់រំ

ព្រះពុទ្ធសាសនា គឺជាសាសនាដែលទាក់ទងនឹងជីវិតរស់នៅរបស់មនុស្ស។ សាលាបឋមសិក្សាវត្តបូព៌ា បានដាក់បញ្ចូលការអប់រំតាមបែបព្រះពុទ្ធសាសនា ទៅក្នុងកម្មវិធីអប់រំរបស់ខ្លួន។

ការបង្កើតកម្មវិធីអប់រំតាមបែបព្រះពុទ្ធសាសនានេះ គឺកើតចេញពីកិច្ចសហការរវាងសាលាបឋមសិក្សាវត្តបូព៌ា និងវត្តរាជបូណ៌ិ។ ជារៀងរាល់សប្តាហ៍ថ្ងៃព្រហស្បតិ៍ ព្រះសង្ឃនៃវត្តរាជបូណ៌ិ តែងតែនិមន្តទៅបង្ហាត់បង្រៀនអប់រំដល់សិស្សានុសិស្ស ព្រមទាំងលោកគ្រូអ្នកគ្រូ និងគណៈគ្រប់គ្រងសាលា ដោយផ្តោតសំខាន់លើសីល សមាធិ បញ្ញា ឬធម៌វិន័យ ពោលគឺការបង្រៀនឱ្យលះបង់នូវទង្វើអាក្រក់ ការប្រព្រឹត្តនូវសេចក្តីល្អ និងការជម្រះចិត្តឱ្យស្អាត។ ទន្ទឹមនេះ សិស្សានុសិស្ស ក៏ត្រូវបានទទួលការអប់រំពីការប្រើប្រាស់សង្ឃសព្ទនៃព្រះពុទ្ធសាសនា ការសូត្រធម៌ ការយល់ដឹងអំពីព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ផងដែរ។

ព្រះសង្ឃនៃវត្តរាជបូណ៌ិ មិនត្រឹមតែធ្វើការបង្រៀនអប់រំ ដោយប្រើប្រាស់កម្លាំងកាយ និងបញ្ញាញាណផ្ទាល់ខ្លួននោះទេ ប៉ុន្តែវត្តរាជបូណ៌ិក៏បានចំណាយធនធានហិរញ្ញវត្ថុផ្ទាល់ ដើម្បីទ្រទ្រង់ការអប់រំដល់សិស្សានុសិស្សប្រកបដោយប្រសិទ្ធភាព ជាអាទិ៍ការរៀបចំឯកសារមេរៀន សម្រាប់សិស្សានុសិស្ស ជាដើម។

ផ្នែកទី៣. គោលការណ៍ប្រតិបត្តិទាំង ៥

វិន័យនាំឱ្យអង្គភាពមានរបៀប វិន័យនាំមនុស្សជាតិឱ្យថ្លៃថ្នូរ វិន័យនាំឱ្យគុណភាពសិក្សាប្លែ (ទស្សនៈពីង គិមឆេន)។

គោលការណ៍ប្រតិបត្តិទាំង ៥ របស់សាលាបឋមសិក្សាវត្តបូព៌ា គឺជាវិន័យដែលប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនដោយសិស្សានុសិស្ស រួមមាន ស្អាត របៀប សុភាព ទៀងពេល សមាធិ។ គោលការណ៍ប្រតិបត្តិទាំង ៥ គឺជាគោលការណ៍ **“អំពើល្អមនុស្សសកល ៥ ប្រការ”** ដែលអាចធ្វើឱ្យបុគ្គលមួយរូប ក្លាយជាមនុស្សម្នាក់ដែលមានវិន័យ និងសីលធម៌ខ្ពស់។

គោលការណ៍នេះ បានចាប់ផ្តើមយកមកប្រតិបត្តិនៅក្នុងសាលាបឋមសិក្សាវត្តបូព៌ យ៉ាងខ្ជាប់ខ្ជួន។

គោលការណ៍ប្រតិបត្តិទាំង ៥ ប្រការ មានខ្លឹមសារ ដូចខាងក្រោម÷

ទី១-ស្អាត÷ ភាពស្អាតក្នុងន័យនេះមិនមែនសំដៅតែទៅលើរូបរាងកាយនោះទេ ប៉ុន្តែត្រូវស្អាតទាំងផ្លូវកាយ ក្រៅផ្លូវកាយ និងផ្លូវចិត្ត។ សាលាបឋមសិក្សាវត្តបូព៌ បានធ្វើការអប់រំសិស្សានុសិស្ស ឱ្យយល់ពីតម្លៃនៃភាពស្អាត តាមរយៈការសម្អាតរាងកាយ ការសម្អាតបរិស្ថាននៅជុំវិញខ្លួន ទាំងបរិស្ថាននៅក្នុងសាលា និងបរិស្ថាននៅក្រៅសាលា ដែលនេះមានន័យថាការសម្អាតឱ្យស្អាតជាប្រចាំ នឹងធ្វើឱ្យប្រាកដថាយើងរស់នៅក្នុងទីជម្រកពោរពេញទៅដោយអនាម័យល្អនិងបរិស្ថានល្អ។

ទី២-របៀប÷ គឺជាការរៀបចំខ្លួនឱ្យត្រឹមត្រូវ មានវិន័យ និងមានសណ្តាប់ធ្នាប់ ទាំងរបៀបដេក ដើរ ឈរ អង្គុយ និងការស្លៀកពាក់។ សាលាបឋមសិក្សាវត្តបូព៌ បានបង្រៀនសិស្សឱ្យយល់ពីរបៀបនៃការរស់នៅប្រចាំថ្ងៃ និងរបៀបដែលត្រូវអនុវត្តនៅក្នុងសាលាជាប្រចាំថ្ងៃ ជាអាទិ៍ការរៀបចំកាលវិភាគសិក្សាដោយខ្លួនឯង, ការរៀបចំទុកដាក់របស់តាមលំដាប់លំដោយនិងមានសណ្តាប់ធ្នាប់, ការរៀបចំសម្លៀកបំពាក់ឱ្យបានត្រឹមត្រូវ, ការរៀបចំកន្លែងសិក្សា និងការរៀបចំកន្លែងដាក់ស្បែកជើងឱ្យបានត្រឹមត្រូវជាដើម។ ការរៀបចំជីវិតឱ្យមានរបៀប នឹងបង្កើតបរិយាកាសឱ្យជីវិតខ្លួនឯង ពោរពេញទៅដោយភាពមានសណ្តាប់ធ្នាប់ និងផ្តល់ឱកាសឱ្យការត្រិះរិះគិតប្រកបដោយប្រសិទ្ធភាព និងពោរពេញទៅដោយសុខភាពល្អ។

សិស្សានុសិស្ស នៃសាលាបឋមសិក្សាវត្តបូព៌ គឺមានឈុតសម្លៀកបំពាក់ ចំនួន ២ ប្រភេទ គឺសម្លៀកបំពាក់សម្រាប់ថ្នាក់ម៉ោងសិក្សាធម្មតា និងសម្លៀកបំពាក់កីឡា។ សម្លៀក-បំពាក់ទាំង ២ ប្រភេទនេះ គឺជាអត្តសញ្ញាណរបស់សាលាបឋមសិក្សាវត្តបូព៌ និយាយជារួមជាពិសេសឆ្លុះបញ្ចាំងយ៉ាងប្រត្យក្សពីការគោរពវិន័យ សមធម៌ក្នុងការសិក្សា និងការឱ្យតម្លៃទៅលើការអប់រំ ជាពិសេសរបៀបនិងរបៀបនៃការសិក្សាយ៉ាងត្រឹមត្រូវ និយាយដោយឡែក។

ទី៣-សុភាព÷ "សុភាពកាយ សុភាពវាចា និងសុភាពចិត្ត" គឺជាសីលធម៌វិន័យដ៏ប្រពៃមួយ ដែលសាលាបឋមសិក្សាវត្តបូព៌ បានយកមកប្រតិបត្តិសម្រាប់គ្រប់តួអង្គទាំងអស់ ជាពិសេសសិស្សានុសិស្ស នៃសាលាបឋមសិក្សាវត្តបូព៌។ ការបង្រៀនឱ្យមានឥរិយាបថល្អ ឬសីលធម៌ល្អ ដោយចេះឱនលំទោន ស្គាល់គោរពចាស់ព្រឹទ្ធាចារ្យ គ្រូបាអាចារ្យ គឺជាវិន័យដែលត្រូវអនុវត្តទាំងក្នុងសាលា និងក្នុងសង្គមទាំងមូល។

ទី៤-ទៀងពេល÷ "ពេលវេលា ជាមាសប្រាក់" ដែលគណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ បានយកចិត្តទុកដាក់និងឱ្យតម្លៃយ៉ាងខ្លាំងទៅលើពេលវេលានៃការអប់រំ។ ភាពទៀងពេល មានន័យដូចទៅនឹង "ភាពមកទាន់ពេល" ពោលគឺ សិស្សានុសិស្ស ត្រូវមកឱ្យបានមុនពេលវេលាបង្រៀន និងសិក្សាជាប្រចាំ ដោយមិនត្រូវលើកយកបញ្ហាផ្សេងៗ ជាចំណោទបញ្ហានៃការបង្អាក់ការមកសាលារៀនឱ្យទៀងពេលនោះឡើយ។

ទី៥-សមាធិ÷ គឺជាការអប់រំផ្លូវចិត្ត ការតម្កល់ចិត្តឱ្យនឹងនរ រៀនគិត និងរៀនធ្វើដើម្បីឆ្ពោះទៅកាន់សន្តិភាពផ្លូវចិត្ត។ សមាធិ គឺជាវិធីសាស្ត្រអប់រំផ្លូវចិត្ត ដ៏មានប្រសិទ្ធភាពខ្ពស់ និងត្រូវបានយកមកប្រតិបត្តិនៅក្នុងសាលាបឋមសិក្សាវត្តបូព៌។

ការធ្វើសមាធិ មានគោលបំណងអប់រំផ្លូវចិត្តរបស់សិស្សានុសិស្ស ឱ្យចេះគិតពិចារណានូវសកម្មភាពដែលបានប្រព្រឹត្ត ក្នុងអំឡុងពេលសិក្សារយៈពេលមួយថ្ងៃពេញ។ តាមរយៈនេះការធ្វើសមាធិមានគោលបំណងសំខាន់ៗ ចំនួន ២ ដូចជា÷

គោលបំណងទី១÷ បណ្តុះសិស្សានុសិស្សឱ្យពិចារណាលើការសិក្សារបស់ខ្លួន ក្នុងរយៈពេលមួយថ្ងៃពេញ ថាមានកិច្ចការអ្វីខ្លះដែលមានប្រយោជន៍ និងកិច្ចការអ្វីខ្លះដែលមិនមានប្រយោជន៍។ ប្រយោជន៍នៅទីនេះ សំដៅទៅលើតួអង្គចំនួន ៤ សំខាន់ គឺប្រយោជន៍សម្រាប់ខ្លួនឯង សម្រាប់អ្នកជិតខែ សម្រាប់គ្រួសារ និងសម្រាប់សង្គមជាតិ។

គោលបំណងទី២÷ បញ្ញាបឱ្យសិស្សានុសិស្ស ពិចារណាទៅលើកំហុស ឬអំពើទាំងឡាយណាដែលមិនមានប្រយោជន៍ ដោយដាក់ចេញនូវសំណួរនិងដំណោះស្រាយ

មួយចំនួនសម្រាប់ខ្លួនឯង ដូចជា÷

ទី១. អំពើដែលមិនមែនជាប្រយោជន៍សម្រាប់ខ្លួនឯង តើមានផលប៉ះពាល់អ្វីខ្លះ និងត្រូវដោះស្រាយ និងកែតម្រូវយ៉ាងដូចម្តេច?

ទី២. ធ្វើឱ្យអ្នកដទៃមានកង្វល់ឬមានបញ្ហាដោយសារតែអំពើរបស់ខ្លួន តើមានផលប៉ះពាល់អ្វីខ្លះ និងត្រូវដោះស្រាយ និងកែតម្រូវយ៉ាងដូចម្តេច?

ទី៣. ធ្វើឱ្យមានកង្វល់ឬបញ្ហាដល់គ្រួសារ តើមានផលប៉ះពាល់អ្វីខ្លះ និងត្រូវដោះស្រាយ និងកែតម្រូវយ៉ាងដូចម្តេច?

ទី៤. បើមានមនុស្សដែលប្រព្រឹត្តអំពើគ្មានប្រយោជន៍បែបនេះ តើមានផលប៉ះពាល់ដល់សង្គមជាតិអ្វីខ្លះ?

ការធ្វើសមាធិ គឺជាការរៀនគិតនិងដោះស្រាយដោយខ្លួនឯង នូវអំពើដែលបានប្រព្រឹត្តក្នុងអំឡុងពេលសិក្សារយៈពេលមួយថ្ងៃពេញ ទាំងអំពើល្អ និងអាក្រក់ ហើយអាចផ្តល់ឱកាសឱ្យសិស្សានុសិស្សចេះគិតពិចារណានិងស្វែងរកដំណោះស្រាយបញ្ហាដោយខ្លួនឯង។

មានទស្សនៈមួយលើកឡើងថា **"គ្រូនិយាយច្រើន គ្រូអប់រំច្រើន"** ដែលវាជាវិធីសាស្ត្រអប់រំមានលក្ខណៈប្រពៃណីយូរណាស់មកហើយ ប៉ុន្តែសាលាបឋមសិក្សាវត្តបូព៌ បានយកចិត្តទុកដាក់ខ្ពស់ទៅលើការបង្រៀនសិស្សឱ្យចេះគិតដោយខ្លួនឯង ដោយផ្លាស់ប្តូរពីការប្រាប់ច្រើន និយាយច្រើនពីមុន ឱ្យពួកគេចេះគិតឡើងវិញ ដោយខ្លួនឯង និងត្រូវយកមកអនុវត្តផ្ទាល់ដោយខ្លួនឯង។

វិធីសាស្ត្រនៃការធ្វើសមាធិ ត្រូវបានប្រតិបត្តិរៀងរាល់ពេល មុនសិស្សានុសិស្សបញ្ចប់ការសិក្សារៀនសូត្ររបស់ខ្លួន ឬមុនពេលចេញទៅគេហដ្ឋានរៀងៗខ្លួន។ ជារៀងរាល់ថ្ងៃសាលាបឋមសិក្សាវត្តបូព៌តែងតែរៀបចំការធ្វើសមាធិនេះ ដោយសិស្សានុសិស្ស នៅតាមបណ្តាថ្នាក់នីមួយៗ ត្រូវសម្រួលឥរិយាបថ បិទភ្នែក អង្គុយដងខ្លួនឱ្យត្រង់ និងរក្សាភាពស្ងៀមស្ងាត់។ ក្នុងអំឡុងពេលសមាធិ មានការបន្លឺនូវសម្លេងអប់រំដោយគណៈគ្រប់គ្រងសាលា អមជាមួយនឹងបទភ្លេងអន្ទងចិត្ត ដើម្បីបញ្ជូនវគំនិតពិចារណាទៅលើអ្វីដែល

សាលានិងសង្គមចង់បាន ក្នុងរយៈពេលប្រមាណ ៥ នាទី ទៅ ១០នាទី ទៅកាន់សិស្ស-នុសិស្សដែលកំពុងសមាធិនៅក្នុងថ្នាក់រៀន។ ការប្រើប្រាស់វិធីសាស្ត្រអត្ថាធិប្បាយពីការអប់រំទូទៅ សំដៅធ្វើយ៉ាងណាឱ្យសិស្សានុសិស្សនឹកឃើញនូវសកម្មភាពទាំងឡាយ ដែលខ្លួនបានប្រព្រឹត្តនិងត្រិះរិះថាសកម្មភាពនោះ មានផលប៉ះពាល់ចំពោះឪពុកម្តាយ ខ្លួនឯង មិត្តភក្តិ និងសង្គមជាតិដែរឬទេ។ អំពើណាដែលល្អ ត្រូវតែបន្តធ្វើទៀត ហើយអំពើណាដែលមិនទាន់ល្អ គឺត្រូវលះបង់ចេញ និងលុបវាចេញ ហើយចាប់ផ្តើមធ្វើអ្វីដែលជាអំពើល្អ។

ផ្នែកទី៤. មិត្តអប់រំមិត្ត

๓๑๘- បុណ្យកុំចេះធ្វើតែក្នុងពិធី បុណ្យបានមកពីធ្វើល្អប្រចាំ
๓๑๙- ប្រព្រឹត្តត្រូវ ឬខុសខ្លួនឯងដឹង គួរតែកុំប្រឹងប្រែកដោះសា
๓๒๐- ប្រមាណមាឌទើបមិនចង្អៀតចិត្ត គ្មានវិប្រក្រឹតិសម្រាប់ពេលក្រោយ
๓๒๑- ផលពិតមិនត្រឹមចេះគិតនិងថា ធ្វើបានអស្ចារ្យទើបជាផលពិត
๓๒๒- ពាក្យបង្ហាប់ប្រៀបដូចគ្រាប់ស្លែង គប្បីចាស់ក្មេងកុំនាំបង្ហាប់
๓๒๓- ពាក្យដែលពិតប្រាកដជាគួរ ចំពោះអ្នកមកក្លាយជាមិត្ត
๓๒๔- ពាក្យពិតត្រឹមត្រូវមិនងាយធ្វើបាន ព្រោះតែសន្តានទម្លាប់ដោះសា
๓๒๕- ពីក្រទៅមានធ្វើបានកម្រ តែមានទៅក្រអាចធ្វើបានងាយ
๓๒๖- ពឹងគេជួយច្រើនគ្មាន់គ្មេរចិត្ត ព្រោះអ្វីៗជ្បិតភ្ជាប់លក្ខខណ្ឌ
๓๒๗- ពេលដែលអត់ទើបគិតដល់មាន ពេលដែលឃ្លានទើបនឹកដល់ចង់
๓๒๘- ពេលមានគប្បីព្យាយាមសន្សំ សម្រាប់ផ្សែផ្សំនៅពេលដែលខ្សត់
๓๒๙- ពោលពាក្យបង្ហាប់ ដូចបានសម្ដាប់មនសិការ

៣៣០- ព្យាយាមគ្រប់គ្រងចិត្តពាល ប្រៀបដូចជាឃ្វាលពពក

៣៣១- ព្យាយាមធ្វើល្អដើម្បីប្រយោជន៍គេ ពាក្យសរសើរជេរគឺជារបស់យើង

៣៣២- ព្យាយាមធ្វើសេចក្តីល្អប៉ុណ្ណា តែងមានបញ្ហានឹងអ្នកអាក្រក់

៣៣៣-មធ្យោបាយល្អមិនឱ្យធ្វើខុស គឺទាល់តែមិនត្រូវធ្វើអ្វីទាំងអស់

៣៣៤- មាសប្រាក់ជាទ្រព្យក្រៅប្រាណ ឯចិត្តទើបបានក្នុងប្រាណប្រាកដ

៣៣៥- មនុស្សពាលប្រដៅអ្នកខ្លៅ ប្រៀបដូចដំបៅមហារីក

៣៣៦- មនុស្សមានតម្លៃ គឺថ្លៃអាស្រ័យអំពើ

៣៣៧- មនុស្សដែលអាចចាត់ទុកថាជាអ្នកចេះ តែងយកចំណេះជួយដល់មនុស្ស
ដទៃ

៣៣៨- មនុស្សចេះរៀបខ្លួនស្អាតជាសាមញ្ញកិត្តិយសមូលវិញដោយបញ្ញាខ្ពស់

៣៣៩- មនុស្សដែលក្លាយជាអ្នកទោសវិប្បដិសារី ព្រោះតែរំពៃទោសអ្នកដទៃ
ផ្តល់ផលដល់ខ្លួនឯង

៣៤០- មនុស្សល្ងង់មិនដែលយកបទពិសោធន៍អ្នកដទៃ មនុស្សឆ្លាតរៀកែច្នៃ
បទពិសោធន៍អ្នកដទៃ ឱ្យក្លាយជាប្រយោជន៍ខ្លួន

៣៤១- មនុស្សដែលឆ្លាតរៀតែងតែស្វែងរកគំនិតថ្មីៗ ដូចផ្កាឈូករីត្មកឃ្វាតខ្ចីរក
ពន្លឺព្រះអាទិត្យ

៣៤២- មនុស្សចេះពិត តែងមានគំនិតមើលធ្វើគិតស្តាប់ពីអ្នកដទៃ

៣៤៣- មនុស្សលេងតែល្បែងស្រីស្រាមានពាក្យពីណាប្រដៅប្រាប់

៣៤៤- មនុស្សកំណាញ់ការសរសើរព្រោះខ្លាចគេគ្រាន់បើជាងខ្លួន

៣៤៥- មនុស្សក្មេងទំនើងមកពីចាស់ធ្វើទ្រើងឱ្យវារឡើង

៣៤៦- មនុស្សអាចផ្លាស់ប្តូរជីវិតខ្លួនបានតាមរយៈផ្លាស់ប្តូរនូវការគិត ភាពឆ្លួតៗ
គឺការធ្វើរឿងដដែលៗ ហើយរំពឹងចង់បាននូវលទ្ធផលផ្លាស់ប្តូរ

៣៤៧- មនុស្សភាគច្រើនបរាជ័យ ដោយសារតែគេមិនព្រមចាប់ផ្តើម

៣៤៨- មនុស្សអាក្រក់មិនចង់ស្តាប់ឮលទ្ធផលល្អអ្នកដទៃ ព្រោះចិត្តរឹពៃទោស អ្នកដទៃបង្ហាប់ឱ្យវិនាស

៣៤៩- មនុស្សគ្រប់រូបជួបទុក្ខធម្មតា គួរកុំសោកានាំខ្វល់ខ្វាយចិត្ត

៣៥០- មនុស្សខ្វចឈ្មោះព្រោះយកទ្រព្យដែលគេមិនបានឱ្យ

៣៥១- មនុស្សគ្មានវិជ្ជា ដូចនាវាគ្មានចង្កូត

៣៥២- មនុស្សដែលជាមង្គលតែងមានធាតុបី គឺការសំចៃ ព្យាយាម និងការដឹងគុណ

៣៥៣- មនុស្សជួយអ្នកទន់ខ្សោយឱ្យមានស្មារតី ជាអ្នកប្រពៃប្រសើរកន្លង

៣៥៤- មនុស្សចាត់ទុកថាមានអំណួត ធ្វើអ្វីគ្មានប្រយោជន៍បានត្រឹមថា

៣៥៥- មនុស្សដែលពិបាកអប់រំបំផុត ត្រង់មានគំនិតពីងព្រេងវាសនា

៣៥៦- មនុស្សដែលមិនស្គាល់ការពិត ធ្វើឱ្យជីវិតបរាជ័យ

៣៥៧- មនុស្សនិយាយកុហកអ្នកដទៃ មានន័យកំពុងកុហកខ្លួនឯង

៣៥៨- មនុស្សដែលគ្មានវិចារណញ្ញាណ ធ្វើហើយមិនហ៊ានទទួលខុសត្រូវ

៣៥៩- មនុស្សសេពសុរាហើយបើកបរ អាចក្លាយជាឃាតករតាមដងផ្លូវ

៣៦០- មនុស្សវាយឫកជាអ្នកធំ មិនដែលជំនុំនឹងអ្នកចេះ

៣៦១- មនុស្សវាយឫកជាអ្នកធំ តាំងខ្លួនយ៉ាងហ៊ាំឱ្យគេកោត

៣៦២- មនុស្សវាយឫកជាអ្នកធំ តែងពួនសម្ងំល្បិចចោលម្យ៉ៀត

៣៦៣- មនុស្សវាយឫកជាអ្នកធំ អែបអបយកបុណ្យមិនខ្មាសញាតិ

៣៦៤- មានជំនួយតែគ្មានគំនិត ប្រៀបបាន ត្រីមគិតតែមិនធ្វើ

៣៦៥- មានថ្ងៃនេះគួរគិតពីថ្ងៃមុន ពីឧបការគុណនាំដល់ថ្ងៃនេះ

៣៦៦- មានទ្រព្យរបស់ហើយ មិនចេះថែ រឫតផុតបែរទើបនឹកស្តាយក្រោយ

៣៦៧- មានភ្នែកត្រូវឱ្យចេះមើល កុំមើលហើយមិនហ៊ានឃើញ

៣៦៨- មានវិន័យនាំឱ្យមានសេចក្តីថ្លៃថ្នូរ

៣៦៩- មានប្រាក់យសសក្តិមានកន្លង ហេតុជាចម្បងដោយមារយាទ
៣៧០- មិនស្គាល់បញ្ហាមិនអាចដោះបាន ប្រៀបដូចបាត់ជានតែខំស្វែងរក
៣៧១- មិនអាចផ្គាប់ចិត្តអ្នកអាត្មានិយមបាន ព្រោះតែសន្ដានមិនខ្វល់ពីអ្នកដទៃ
៣៧២- មានគំនិតទើបមានកំណើត ព្រោះអ្វីៗកើតដោយគំនិត
៣៧៣- មានចម្ងល់ទើបមានចំណេះ ព្រោះអ្វីដែលចេះផ្តើមពីឆ្ងល់
៣៧៤- មុនធ្វើអ្វីត្រូវយកគំនិតទៅប្រើ ទើបអាចប្រសើរប្រើចំគោលដៅ
៣៧៥- មុនដើរគប្បីសិក្សាពីផ្លូវ ទើបនាំឆ្ពោះទៅនៃភាពជោគជ័យ
៣៧៦- មុនបង្រៀនគួររៀនខ្លួនឯងឱ្យចេះ ទើបបានចំណេះមិនចេះត្រឹមតែថា
៣៧៧- មុនទូន្មានគេត្រៀមទូន្មានខ្លួនឯង ទើបមិនកោតក្រែងពេលទូន្មានគេ
៣៧៨- មុននឹងធ្វើត្រូវគិត រួចពិនិត្យសឹមពិចារណា
៣៧៩- មុននឹងថា ត្រូវគិតពីផែនការដែលធ្វើឱ្យសម្រេច
៣៨០- មុនបង្រៀនគួរសាកល្បងឱ្យចេះ ទើបមានចំណេះអាចចេះបង្រៀន
៣៨១- មុនពេលចូលគេង ពួកយើងក្មេងៗត្រូវដុសធ្មេញរៀងរាល់យប់
៣៨២- មេផ្ទុះទៅផ្សារតែងយកថវិកាទៅចោលក្នុងធុងសម្រាម
៣៨៣- មើលឃើញគេស្អាត គប្បីវៃឆ្លាតធ្វើឱ្យស្អាតដូចគេ
៣៨៤- មើលឃើញគេស្អាត គ្មានគំនិតវៃឆ្លាតធ្វើឱ្យស្អាតដូចគេ
៣៨៥- រៀនដើម្បីជីវិតរស់ ទើបជាឈ្មោះអ្នកព្យាយាមរៀន
៣៨៦- រៀនឱ្យចេះមេត្តា គឺជាខ្លឹមសារនៃមនុស្សពិត
៣៨៧- រៀនចេះជួយដល់មិត្តភក្តិ មានពំនាក់ក្នុងសន្ដាន
៣៨៨- រៀនដើម្បីឱ្យជីវិតរស់ ទើបជាឈ្មោះនៃអ្នកខំរៀន
៣៨៩- រៀនឱ្យចេះដឹងធ្វើបានខ្ពង់ខ្ពស់ ទើបមានកេរ្តិ៍ឈ្មោះអ្នកសិក្សាល្បី
៣៩០- រៀនមើលរៀនស្តាប់រៀនត្រាប់ ទើបអាចឆាប់ចេះចាំបាន
៣៩១- រៀនដោះស្រាយនូវបញ្ហា ទើបគ្មានបញ្ហាសម្រាប់ជីវិត

៣៩២- រៀនពីពិភពពិត ទើបជីវិតរុងរឿង
៣៩៣- រៀនពីហេតុទើបសង្កេតឃើញផល ស្វែងហេតុជិតដល់បានផលពណ្ណរាយ
៣៩៤- រៀនសង្កេតនិងពិនិត្យ ជាគ្រូពិតនៃចំណេះ
៣៩៥- រៀនឱ្យមានទម្លាប់ល្អ កម្រចោលមារយាទ
៣៩៦- រៀនឱ្យហ្មត់ចត់ ប្រាកដជាជីវិតជោគជ័យ
៣៩៧- សត្រូវចំមុខស្រណុកការពារ ចូរប្រយ័ត្នមារដែលនៅពីក្រោយ
៣៩៨- សភាពចិត្តប្រៀបដូចចង្កៀងប្រេង ឆេះភ្លឺរមែងមានផ្សែងខ្មៅជិត
៣៩៩- សមត្ថភាព ឬសកម្មភាពដែលពិត បញ្ជាក់ពីជីវិតប្រចាំថ្ងៃ
៤០០- សារជាតិជាមនុស្សក្រពើ មិនដែលអើពើគុណអ្នកដទៃ
៤០១- សេពគប់ជាមួយអ្នកប្រាជ្ញ អ្នកនឹងអាចជាបណ្ឌិត
៤០២- សេពសុរាថាកំដរបុណ្យ ជាពាក្យដោះកុននៃអ្នកផឹក
៤០៣- សម្តីលួទង្វើអាក្រក់ ចិត្តខ្មៅកខ្វក់នៃល្បិចពាល
៤០៤- សម្តីអ្នកដទៃដែលមានន័យ ស្តាប់ហើយលកលៃត្រៀមប្រតិបត្តិ
៤០៥- សម្តីអ្នកដទៃដែលគ្មានន័យជាមេរៀនរាល់ថ្ងៃនៃជីវិត
៤០៦- សម្តីអ្នកដទៃមាន ឬគ្មានន័យ ស្តាប់ហើយត្រូវកែច្នៃឱ្យជាប្រយោជន៍
៤០៧- សម្តីដែលចាត់ទុកមិនបានការ គឺបានត្រឹមថាតែធ្វើមិនកើត
៤០៨- សម្តីមិនបានការ ជាបន្លាក្នុងបេះដូងនៃអ្នកស្តាប់
៤០៩- សម្តីពិរោះកុំទាន់ថាល្អ ទង្វើស្មោះសរទើបជាល្អពិត
៤១០- សម្តីពោលមិនប្រាកដថាត្រូវ បើអ្នកស្តាប់នៅចាំចាប់កំហុស
៤១១- សម្តីមួយម៉ាត់មានគាប់មានទាស់ ដល់ជនទាំងអស់កំពុងចាំស្តាប់
៤១២- សម្តីលួតែគ្មានការពិត ប្រៀបដូចកាំបិតចាំប្រហារ
៤១៣- សម្តីរោយរាយឥតប្រយោជន៍ បានត្រឹមតែអសោចកិត្តិយស
៤១៤- សម្តីអាក្រក់មិនប្រាកដថាមិនល្អ សម្តីផ្អែមដូចស្ករមិនប្រាកដថាមិនអាក្រក់

៤១៥- សម្តីពិរោះនឹងមិត្តមិនងាយប្រព្រឹត្តបាន ដោយមិត្តក្នុងក្រុមគ្រប់ប្រាណ
ចេះមូលចិត្តសាមគ្គី

៤១៦- សម្ថសាបប្រៃអាស្រ័យលើអ្នកជាំស្ល ចិត្តអាក្រក់ល្អព្រោះសារជាតិនៃបុគ្គល

៤១៧- សម្តីងមើលជិតត្រូវគិតឱ្យឆ្ងាយ ទើបមិនអន្តរាយដល់កិច្ចការធំ

៤១៨- សេចក្តីប្រមាទតែងនាំឱ្យឆ្គោយ បាត់លាភញយៗដោយការប្រមាទ

៤១៩- សេចក្តីល្អកម្រនឹងរក សេចក្តីស្មោកគ្រោករកបានងាយ

៤២០- សេចក្តីសុខទុក្ខនៅជាប់នឹងគ្នា ពឹងលើរាល់គ្នាប្រតិបត្តិមួយណា

៤២១- សេចក្តីសុខទុក្ខមិនទៀងគ្រប់ប្រាណ ដែលអាចកើតបាន គ្រប់ពេលវេលា

៤២២- សេចក្តីក្រោធ បណ្តាលមកពីការឆោតល្ងង់

៤២៣- ស្តាប់សំដីអ្នកដទៃទៅគិត ជាងប្រើគំនិតអាត្មានិយម

៤២៤- ស្តាប់ច្រើនឱ្យចាំទុកជាគ្រូ ជាគំនិតគួរទុកពិចារណា

៤២៥- ស្តាប់ពាក្យបណ្ឌិត តែងជាគំនិតនៅក្នុងសន្តាន

៤២៦- សៀវភៅគឺជាឃ្លាំងដែលផ្ទុកនូវចំណេះដឹង

៤២៧- សៀវភៅគឺជាមិត្តពិត ដែលស្ម័គ្រចិត្តតាមបម្រើ

៤២៨- អនាគតដែលគាប់ប្រសើរ គឺព្យាយាមដើរលើផ្លូវត្រូវ

៤២៩- អានច្រើនបង្កើនចំណេះ ធ្វេសប្រហែសនាំអន្តរាយ

៤៣០- អំពើខុសត្រូវខ្លួនឯងអ្នកដឹង បើខុសខំប្រឹងកែត្រូវវិញបាន

៤៣១- អំពើល្អអាក្រក់មិនប្រាកដលើអ្នកថា អ្វីដែលអស្ចារ្យនៅត្រង់ខ្លួនឯងធ្វើ
ដឹងខុសត្រូវ

៤៣២- អំពើល្អគប្បីធ្វើគួរធ្វើ កុំរង់ចាំធ្វើថ្ងៃនៅថ្ងៃស្អែក

៤៣៣- អំពើល្អក្នុងចំណោមអ្នកអាក្រក់ ប្រាកដជាល្អក់ចិត្តជ្បិតការរំខាន

៤៣៤- អំពើល្អរបស់អ្នកដទៃ គប្បីរំពៃឱ្យជាប្រយោជន៍

៤៣៥- អំពើដែលត្រឹមត្រូវបែរជាខ្លាច ខុសច្បាប់មិនខ្លាចព្រោះលាភអាត្មា

៤៣៦- អំពើកុសលទើបបានស្ងប់ចិត្ត អគុណនាំចិត្តខ្វល់តសន្តាន
៤៣៧- អំពើខុសត្រូវពិតជាខ្លួនឯងអាចដឹង ពុំចាំបាច់ប្រឹងឱ្យអ្នកដទៃដឹងឡើយ
៤៣៨- អ្នកមានភ្នែកមិនចេះប្រើ ចាត់ទុកដូចស្មើគ្មានគំនិត
៤៣៩- អ្នកមានភ្នែកតែគ្មានគំនិត អាចពិបាកពិតស្វែងរកផ្លូវ
៤៤០- អ្នកប្រាជ្ញកណ្តាលខ្លៅ ដូចដាំស្មៅកណ្តាលខ្សាច់
៤៤១- អ្នកមានចំណេះមិនចេះប្រើ មិនអាចប្រសើរដល់ជីវិត
៤៤២- អ្នករឹងចចេសជួបបរាជ័យ ទើបឱ្យតម្លៃអ្នកធ្លាប់ទូន្មាន
៤៤៣- អ្នកដែលតែងរិះគន់គំនិតគេ មានដែលគិតទេចិត្តឯងយ៉ាងណា
៤៤៤- អ្នកដែលរឹងចចេសមានៈ ច្រើនជួបប្រទះបរាជ័យ
៤៤៥- អ្នកឆ្ងល់ដែលគ្មានហេតុនិងផល គឺជាកង្វល់ដល់អ្នកស្តាប់
៤៤៦- អ្នករើសអេតចាយអាចក្លាយជាមាន បើស្ងាធ្យាយរៀនមេរៀនជីវិត
៤៤៧- អ្នកមានជំនឿដោយផ្តាប់មុខ អាចនាំនូវទុក្ខដល់អាត្មា
៤៤៨- អ្នកមានគំនិតធ្វើលួនឹងមុខ គឺមិនបានទុកខ្លួនឯងជាធំ
៤៤៩- អ្នកមានគំនិតពិតជាចម្រើន ធនធានអាចកើនព្រោះតែគំនិត
៤៥០- អ្នកធ្វើអ្វីតាមតែទម្លាប់ កំពុងតែងាប់នូវបញ្ញា
៤៥១- អ្នកដែលល្ងង់ប្រាកដជាចេះ បើព្យាយាមចេះអ្វីដែលល្ងង់
៤៥២- អ្នកដែលធ្លាប់ពឹងឱ្យតែគេជួយ គ្មានគំនិតព្រួយពឹងមួយជីវិត
៤៥៣- អ្នកបានត្រឹមថាមិនប្រាកដជាចេះ អ្នកមានចំណេះមិនប្រាកដថាដឹង
៤៥៤- អ្នកមានឆន្ទៈតែខ្វះបញ្ញា ធ្វើឱ្យកិច្ចការមិនសូវជោគជ័យ
៤៥៥- អ្នកដែលចេះអាចក្លាយជាល្ងង់បាន បើសិនគ្រប់ប្រាណមិនរៀនបន្ថែម
៤៥៦- អ្នកមានភ្នែកតែងងឹតទាំងភ្លឺ ព្រោះមានជំងឺប្រមាថនិយម
៤៥៧- អ្នកចេះថាប្រាកដជាត្រឹមត្រូវ ព្រោះបានតម្រូវតាមចិត្តចង់ថា
៤៥៨- អ្នកចេះថាបានជាប្រយោជន៍ ទើបមិនអសោចដល់គំនិត

៤៥៩- អ្នកដែលចេះមិនមែនបានតែថា ធ្វើកើតត្រឹមណាទើបរាប់ថាចេះ
៤៦០- អ្នកដែលមិនទទួលស្គាល់ការពិត កំពុងតែស្ថិតភាពបាត់តម្លៃ
៤៦១- អ្នកដែលមានចំណេះចេះឥតខ្ចោះ នៅមានចន្លោះដោយក្តីប្រមាថ
៤៦២- អ្នកដែលធ្វើពិបាកតម្រូវចិត្តអ្នកថា ប៉ុន្តែយ៉ាងណាថាខ្លះក៏ជាប្រយោជន៍
៤៦៣- អ្នកដែលមិនចេះមកពីភាពល្ងង់ ព្រោះតែកំពុងតាំងខ្លួនអ្នកចេះ
៤៦៤- អ្នកព្លឹកថាមិនប្រាកដធ្វើអ្វីកើត ព្រោះពីកំណើតរៀនបានត្រឹមតែចេះថា
៤៦៥- អ្នកដែលមានចិត្តគំនិតឥស្សា គឺប្រើតិរិយានៃការច្រណែន
៤៦៦- អ្នកចេះមិនប្រាកដថាចេះអ្វីៗទាំងអស់ គួររកចន្លោះភាពមិនទាន់ចេះជាប្រចាំ
៤៦៧- អ្នកចេះប្រាកដហើយមិនប្រមាថ ទើបជាអ្នកឆ្លាតគតិបណ្ឌិត
៤៦៨- អ្នកល្ងង់ប្រឹងតាំងខ្លួនជាអ្នកចេះ ដោយសារចំណេះចេះត្រឹមភាពល្ងង់
៤៦៩- អ្នកចេះមិនប្រាកដថាមិនល្ងង់ ព្រោះអ្វីដែលល្ងង់នៅត្រង់មិនចេះ
៤៧០- អ្នកដែលទន់ខ្សោយ ព្រោះតែបណ្តោយឱ្យខ្លួនល្ងង់
៤៧១- អ្នកតែងតែរង់ចាំនូវពេលវេលា ប៉ុន្តែវេលាមិនដែលរង់ចាំអ្នក
៤៧២- អ្នកធ្វើខុសមិនទទួលកំហុស ច្រើនតែប្រទូស្តនឹងអ្នកពិន័យ
៤៧៣- អ្នកមានស្នេហា ដូចមានបន្លានៅក្នុងបេះដូង
៤៧៤- អ្នកឋានៈធំកុំតាំងខ្លួនចេះ ក្នុងលោកចំណេះចេះមិនអស់ឡើយ
៤៧៥- អ្នកចេះនូវអ្វីដែលចេះ តែមិនទាន់ចេះនូវអ្វីដែលអ្នកដទៃបានដឹង
៤៧៦- អ្នកដែលធ្វើល្អបានត្រឹមរួចខ្លួន អ្នកចាំរុកគួនបានឡើងបុណ្យស័ក្តិ
៤៧៧- អ្នកគ្មានមាសប្រាក់ប្រសើរជាងគ្មានវិញ្ញាណ បើមានធនធានគ្មានវិញ្ញាណគ្មានអ្វីទាំងអស់
៤៧៨- អ្នកមិនដឹងគឺគ្មានកំហុស កុំតែធ្វើខុសធ្វើមិនដឹង
៤៧៩- អ្នកដែលមានចិត្តបុណ្យពិតប្រាកដ គឺបានសន្មតដោយការចូលរួម

៤៨០- អ្នកគប្បីធ្វើម្ចាស់លើសំរាម កុំឱ្យសំរាមធ្វើម្ចាស់លើអ្នក

៤៨១- អ្នកមិនហ៊ានពោលនូវការពិត គឺជាគំនិតបរាជ័យ

៤៨២- អ្នកមិនហ៊ានធ្វើអំពើល្អ កំពុងបន្តបរាជ័យ

៤៨៣- អ្នកដែលមានសេចក្តីស្ងប់ ទើបគ្មានចិត្តស្អប់ស្រឡាញ់

៤៨៤- អ្នកមានគំនិតឈ្មោនីសឥស្សា ដូចមានបន្លាមុតចិត្តប្រចាំ

៤៨៥- អ្នកចេះតបគុណារមែងបានសុខ ដោយសាងពូជសុខទុកជាគំរូ

៤៨៦- អ្នកខឹងមកពីមិនដឹងខ្លួនខុស ទើបឱ្យកំហុសក្លាយជាកំហឹង

៤៨៧- អ្នកចេះប្រដូចជីវិតខ្លួនឯងនឹងអ្នកដទៃ ជាអ្នកមានអធ្យាស្រ័យព្រហ្ម-
វិហារធម៌

៤៨៨- អ្នកចេះរៀបចំទុកដាក់ទ្រព្យ ជាអ្នកមានភ័ព្វដ៏ប្រសើរ

៤៨៩- អ្នកប្រាជ្ញស្វែងរកវិជ្ជា គប្បីគិតថាមិនចាស់មិនស្លាប់

៤៩០- អ្នកជោគជ័យអាស្រ័យដោយការលះបង់ ដែលមានចំណង់ប្រកបដោយ
ឆន្ទៈ

៤៩១- អ្នកមិនយល់ពិតអាចព្យាយាមកែបាន តែកែសន្តានអ្នកយល់ធ្វើមិនដឹង
ទោះបីខំប្រឹងកែក៏គ្មានប្រយោជន៍

៤៩២- អ្នកចូលចិត្តសិក្សាផ្នែកសិល្បៈតន្ត្រី ច្រើនធ្វើកិច្ចការអ្វីៗដោយចិត្តព្យាយាម

៤៩៣- អ្នកមានស្មារតីធ្វើការងារល្អ មិនទុកការងារចរឱ្យហួសរំលង

៤៩៤- អ្នកដែលមានចិត្តក្តៅ ឥស្សាច្រណែន ចិត្តផ្សាយរីសែន ព្រោះអ្នកផ្សេង
ផ្សងជោគជ័យ

៤៩៥- អ្នកកុំគប្បីរំពៃទោសគេ គួរគិតផងដែរទោសឯងប៉ុណ្ណា

៤៩៦- អ្នកក្រខំប្រឹងត្រដរធ្វើមាន ភាពក្រកើតមានតជៅសន្តាន

៤៩៧- អ្នកខាកស្តោះនៅតាមដងផ្លូវ នាំប៉ះពាល់នូវដល់សុខភាព

៤៩៨- អ្នកខាកស្តោះនៅតាមដងផ្លូវ អត់ខ្មាសប៉ះត្រូវដល់អ្នកចរ

๔๙๙- អ្នកខ្លៅគប់រកប្រាជ្ញ ក្រោយ គង់អាចជាបណ្ឌិត
๕๐๐- អ្នកចេះត្រឹមតែថា ខ្លាចគេថាខ្លួនមិនធំ
๕๐๑- អ្នកចេះនិយាយប្រៀបដូចជាផ្កា អ្នកចេះតែថាប្រៀបដូចលាមក
๕๐๒- អ្នកនិយាយប្រៀបដូចជាផ្កា អ្នកចេះធ្វើការប្រៀបដូចជាផ្លែ
๕๐๓- អ្នកចេះប្រាកដ មានភាពអំណត់មិនជេរប្រមាថ
๕๐๔- អ្នកចេះពិតប្រាកដ តែងព្យាយាមសព្វគ្រប់កិច្ចការ
๕๐๕- អ្នកចេះ មិនប្រាកដថាដឹង អ្នកខឹងមិនប្រាកដមិនក្រោធ
๕๐๖- អ្នកចេះស្ងួត្រធមិមានច្រើនណាស់ ម្តេចបានខ្វះអ្នកប្រតិបត្តិធមិ
๕๐๗- អ្នកចោលសំរាមក្នុងទឹកលើដី ខូចគុណតម្លៃខ្លួននិងសង្គម
๕๐๘- អ្នកឆ្លាតក៏អាចនៅមានល្ងង់ អ្នកដែលស្មោះត្រង់ក៏គង់ក្បត់
๕๐๙- អ្នកឆ្លាត ត្រូវរៀនពីអ្នកជោគជ័យ រួចគិតកែច្នៃឱ្យជាប្រយោជន៍
๕๑๐- អ្នកដឹងថាខ្លួនឯងល្ងង់ ត្រូវខំប្រឹងរកចំណេះ
๕๑๑- អ្នកដែលចាត់ទុកថាចេះប្រាកដ យល់ដឹងហ្មត់ចត់ហេតុផលត្រឹមត្រូវ
๕๑๒- អ្នកដែលចេះគោរពពេលវេលា ទើបមានឈ្មោះជាគោរពខ្លួនឯង
๕๑๓- អ្នកដែលចេះរៀនគ្មានទីបញ្ចប់ អ្នកដែលប្រសប់ មិនគ្រប់ជ្រុងជ្រោយ
๕๑๔- អ្នកដែលវៃឆ្លាត មកពីសង្វាតរៀនមើលគិតស្តាប់
๕๑๕- អ្នកដែលឧស្សាហ៍ព្យាយាម ទើបរាប់ថាមានជោគវាសនា
๕๑๖- អ្នកត្រូវចេះខ្មាសខ្លួនឯង អំពើដែលតែងតែធ្វើខុស
๕๑๗- អ្នកថាជាគំនិតរបស់គេ គប្បីរិះរេរកគំនិតត្រូវ
๕๑๘- អ្នកធ្វើខុសចេះកែកំហុស គឺជាមនុស្សដែលជោគជ័យ
๕๑๙- អ្នកធ្វើខុសមិនដែលស្គាល់កំហុស ធ្វើឱ្យអ្នកនោះធ្លាក់ក្នុងរណ្តៅ
๕๒๐- អ្នកធ្វើខុស មិនទទួលកំហុស គឺជាមនុស្សដែលបរាជ័យ
๕๒๑- អ្នកធ្វើខុសមិនទទួលកំហុស ច្រើនតែប្រទូស្តនឹងអ្នកដទៃ

៥២២- អ្នកធ្វើខុសហើយដោះសា គឺអ្នកអាត្មានិយម

៥២៣- អ្នកនៅជិតប្រៀបដូចជាឆ្ងាយ ដោយចិត្តមាក់ងាយមើលរំលង

៥២៤- អ្នកពូកែមិនដែលចេះបានប្រាកដ អ្នកដែលប្រសប់ មិនដែលគ្រប់ជ្រុងជ្រោយ

៥២៥- អ្នកពូកែអត់ធ្មត់ តែងបានសម្រេចនូវភាពជោគជ័យ

៥២៦- អ្នកព្យាយាមរៀនកើនចំណេះ អ្នកកម្ចិលផេះអត់បញ្ហា

៥២៧- អ្នកព្យាយាមរៀនគំនិតកាន់តែក្មេង អ្នកប្រមាទតែងគំនិតកាន់តែចាស់

៥២៨- អ្នកមានកង់ថោកតែចរិតថ្លៃ តែងមានតម្លៃជាងឡានថ្លៃតែចរិតថោក

៥២៩- អ្នកមានគ្មានគុណធម៌ រងគ្រោះបន្តដល់ជនទន់ទាប

៥៣០- អ្នកមានមិនប្រាកដថាមិនក្រ អ្នកល្ងង់មិនប្រាកដថាមិនអាក្រក់

៥៣១- អ្នកមាន មិនអាចប្រាកដ អ្នកខ្សត់មិនប្រាកដថាគ្មាន

៥៣២- អ្នកមិនចេះឱ្យតម្លៃទៅគេ ព្រោះតែខ្លាចគេគ្រាន់បើជាងឯង

៥៣៣- អ្នកមិនដែលធ្វើកុំតាំងខ្លួនគ្រាន់ ត្រូវចេះរៀបចំឃ្លាំគ្រាប់អ្នកធ្វើ

៥៣៤- អ្នកមិនទទួលស្គាល់ភាពត្រឹមត្រូវ សតិសត្រូវនឹងសច្ចធម៌

៥៣៥- អ្នករក្សាសីលចរិតមានៈ មិនដែលបានឈ្នះចិត្តខ្លួនឯងឡើយ

៥៣៦- អ្នករុញគេឱ្យព្យាយាមរៀន តែងគ្រាំក្រៀមដោយពាក្យប្រហារ

៥៣៧- អ្នករៀនពីកំហុស ជាកញ្ចក់ឆ្លុះមើលខ្លួនឯង

៥៣៨- អ្នករៀនសូត្រតែងមានវិធី អ្នកសំភីតែងមានគំនិត

៥៣៩- អ្នកល្ងង់មិនមែនធ្វើអ្វីមិនដែលខុស បើមានកំហុសចេះកែពិតជាល្អ

៥៤០- អ្នកមានប្រើរបស់ល្អ អ្នកក្រប្រើរបស់ចាំបាច់

៥៤១- អ្នកមានភ្នែកតែងងឹតទាំងភ្លឺ ព្រោះតែជំងឺអាត្មានិយម

៥៤២- អ្នកចេះប្រើប្រាស់សៀវភៅ គឺជាពន្លឺនៃចំណេះដឹងដ៏រុងរឿង

៥៤៣- អ្នកមានគំនិតតែមិនបិនប្រសប់ មកពីគ្មានទម្លាប់ក្នុងការស្រាវជ្រាវ

៥៤៤- អ្នកជាបណ្ឌិត តែងតែទទួលយកគំនិតអ្នកដទៃ

៥៤៥- អ្នករៀនដែលចេះពិត គឺគ្មានគំនិតលួចចម្លង

៥៤៦- អ្នកដែលរៀនចេះពិត តែងមានគំនិតច្នៃប្រឌិតជាប្រចាំ

៥៤៧- អ្នកវិះគន់ថាគេអួត មកពីខ្លួនឯងមិនខ្មោចគ្មានអ្វីមកអួតដូចគេ

៥៤៨- អ្នកវិះគន់គេថាមានអំណួត គឺកំពុងតែបញ្ចេញអំណួតពីខ្លួនឯង

៥៤៩- អ្នកដែលវិះគន់ថាគេអួត ជាអ្នកមានចេតនាអួតអំពីខ្លួនឯង

៥៥០- អ្នកដទៃធ្វើអ្វីគ្មានន័យកុំទោមនស្ស ត្រូវជួយកែវិញនោះទើបជាមនុស្ស ប្រពៃ

៥៥១- អ្នកបើកបរខាកស្តោះចោលតាមផ្លូវ នាំឱ្យអាស្រូវដល់ពូជសន្តាន

៥៥២- អ្នកដែលទៅផ្សារ បើមិនពិចារណាអាចថវិកាក្លាយជាសំរាម

៥៥៣- អ្នកដែលលក់របស់ បើមិនគិតសោះប្រាក់ក្លាយជាសំរាម

៥៥៤- អ្នកមានប្រាក់ទិញរបស់ មិនបានប្រើសោះចំណែកប្រាក់ខ្លះជាសំរាម

៥៥៥- អ្នកលើកស្ទួយគេឱ្យមានតម្លៃ ជាបុណ្យពេកក្រៃកម្រនឹងរក

៥៥៦- អ្នកស្គាល់ច្បាស់បុណ្យ ត្រូវជួយធ្វើមុនទុកជាគំរូ

៥៥៧- អ្នកធ្វើបុណ្យច្រើនបង្កប់បាប ព្រោះមិនឆ្លាតដោយមិនស្គាល់បុណ្យ

៥៥៨- អ្នកចិត្តបុណ្យពិត តែងមានគំនិតជួយអ្នកជួបភ័យ

៥៥៩- អ្នកមានជំនាញត្រូវប្រយ័ត្ន ក្រែងលោភ្លាត់ឱ្យបរាជ័យ

ផ្នែកទី២. ការអប់រំ ឬដឹកនាំស្ថាប័ន

៥៦០- ការដឹកនាំល្អនិងវៃឆ្លាត គប្បីសង្កេតក្តាប់ព័ត៌មាន

៥៦១- ការដឹកនាំល្អមិនដៅមេដាយសរសើរ អ្វីដែលប្រសើរមហាជនឱ្យតម្លៃ

៥៦២- ការដឹកនាំបុគ្គលិកមជ្ឈមណ្ឌល គឺមានហេតុផលចូលរួមគិតធ្វើ

៥៦៣- ការគ្រប់គ្រងបុគ្គលិកមិនបានល្អ វិនាសអន្តដូចច្រែះស៊ីដែក

៥៦៤- ការដឹកនាំលាបម្សៅឡើងសម្តែង លទ្ធផលជាក់ស្តែងដូចកប់អាត្មា

៥៦៥- ការដឹកនាំប្រកបដោយបញ្ញា មិននាំបញ្ហាសម្រាប់សង្គម

៥៦៦- ការដឹកនាំអង្គភាពធ្វើការឱ្យមានរបៀប ដូចបានបញ្ជ្រាបគុំរស់នៅក្នុងសង្គម

៥៦៧- ការដឹកនាំចាត់ទុកថាអស្ចារ្យ ជួយរាល់កិច្ចការអភិវឌ្ឍជាតិ

៥៦៨- ការដឹកនាំមិនគួរកាន់កន្ទុយខ្សែ ធ្វើឱ្យក្បាលខ្សែរង់ចាំតែគំនិត

៥៦៩- ការដឹកនាំមិនត្រឹមត្រូវបានល្អ លទ្ធផលកម្រមានការចូលរួម

៥៧០- ការដឹកនាំបែបមជ្ឈការ កំពុងប្រហារនូវគំនិត

៥៧១- ការដឹកនាំមានគំនិតវិជ្ជមាន ទើបអាចកើតមានការអភិវឌ្ឍ

៥៧២- ការដឹកនាំដែលមានភាពប្រសើរ គួរក្តាប់សំណើបញ្ហាប្រចាំ

៥៧៣- ការដឹកនាំធ្វើតាមបង្គាប់រង់ចាំបញ្ញា គឺបានត្រឹមងារជាការគ្រប់គ្រងគ្មានគំនិត

៥៧៤- ការលើកទឹកចិត្តដោយវិជ្ជមាន ទើបជាប្រធាននៃប្រយោជន៍

៥៧៥- ការដឹកនាំចេះដោះស្រាយបញ្ហា ជាក្តីប្រាថ្នាអ្នកក្រោមបង្គាប់

៥៧៦- ការដឹកនាំខុសមិនត្រូវបន្ទោសមកពីបញ្ហា ព្រោះមិនសិក្សាប្រភពបញ្ហាទើបបរាជ័យ

៥៧៧- ការដឹកនាំរស់សោយសុខលើគំនរទុក្ខ គឺជាប្រមុខនាំមកនូវក្តីវិនាស

๕๗๘- ការដឹកនាំអង្គភាពរបៀបហែអើ ធ្វើឱ្យដំណើរអភិវឌ្ឍគ្មានន័យ

๕๗๙- ការផ្តើមបង្កើតបានគំនិតថ្មី គឺជានិស្ស័យនៃអ្នកដឹកនាំ

๕๘๐- ការដឹកនាំខ្វះគំនិតគ្មានមារយាទ ដួចបានបន្ទាបកិត្តិយសសង្គម

๕๘๑- ការគ្រប់គ្រងកែច្នៃដោយប្រើបញ្ញា ចេះដោះបញ្ហាជាកត្តាជោគជ័យ

๕๘๒- ការដឹកនាំបែបប្រជាធិបតេយ្យជ្រុល មិនជាឫសគល់នាំផលជោគជ័យពិត

๕๘๓- ការដឹកនាំដែលអាត្មានិយម ធ្វើខុសតួចធំមិនមកពីអញ

๕๘๔- ការដឹកនាំខុសដួចធ្លាក់ជ្រោះដ៏សែនជ្រៅ ប្រយោជន៍បាត់ទៅគឺអនាគតកុមារ

๕๘๕- ការដឹកនាំគ្មានទំនួលខុសត្រូវ កំពុងនាំផ្លូវអង្គភាពវិនាស

๕๘๖- ការដឹកនាំរៀនឱ្យមានគំនិត ដើម្បីចេះគិតត្រៀមមុខរបរ

๕๘๗- ការទំនាក់ទំនងជាកិច្ចចម្បង នាំឱ្យអ្នកផងចូលរួមសហការ

๕๘๘- ការពង្រឹងគុណភាពនាយកគួរចាប់ផ្តើមពី÷ រៀនទ្រឹស្តីតិចយកទៅរៀនអនុវត្តនៅអង្គភាពឱ្យច្រើន បង្ហាញលទ្ធផលពិតអភិវឌ្ឍនៅសាលារៀនជាក់ស្តែង និងបង្កើតទ្រឹស្តីថ្មីត្រឡប់។

๕๘๙- ការលើកទឹកចិត្តដោយមិនលម្អៀងទៅតាមកម្រិតចំណាត់ថ្នាក់ (និទ្ទេស A B C D E F)។ ស្ងប់ភាពអង្គភាព (សមត្ថភាពជំនាញ ចំណេះដឹងជាមូលដ្ឋានត្រូវបានបង្កើន មានមនសិការវិជ្ជាជីវៈ ការទទួលខុសត្រូវខ្ពស់ក្នុងការសម្រេចចិត្ត ដោយមិនទម្លាក់កំហុសឱ្យថ្នាក់លើឬថ្នាក់ក្រោម។ មិនអាត្មានិយម មានឆន្ទៈ មានការអត់ធ្មត់ មានការព្យាយាម មានភាពស្មោះត្រង់និងមានការលះបង់ខ្ពស់ដើម្បីអង្គភាពនិងកូនចៅប្រជាជន។

๕๙๐- កិច្ចការជោគជ័យត្រូវមើលឱកាស មានហេតុផលច្បាស់សុំសម្រេចធ្វើ

๕๙๑- កិច្ចការធ្វើដោយស្មារតីចាត់តាំង មិនមានកម្លាំងដួចដោយឆន្ទៈ

๕๙๒- កុំឡើងក្តិច កុំជាន់ពន្លិច អ្នកនៅក្រោម

៥៩៣- កំណែទម្រង់តែងជួបបញ្ហាជាឧបសគ្គ គប្បីហ៊ានស៊ូគ្រប់រឿឧបសគ្គតូចៗ រាំងផ្លូវ

៥៩៤- ខ្លឹមសារនៃការអភិវឌ្ឍការងារ “ត្រូវមានឆន្ទៈ (សេចក្តីប្រាថ្នា), ត្រូវមានសទ្ធា (ជំនឿមុតមាំ), ត្រូវមានភាពម្ចាស់ការទទួលខុសត្រូវ”

៥៩៥- ខ្លឹមសារនៃសាលារៀនល្អ “ត្រូវតែស្អាត Clean, ត្រូវតែបៃតង Green, ត្រូវតែហ្មត់ចត់ Strict”

៥៩៦- ខ្លឹមសារនៃអ្នកដឹកនាំអមតៈ÷ ឱ្យដឹងទាំងអស់គ្នា ឱ្យយល់ទាំងអស់គ្នា ឱ្យជឿទាំងអស់គ្នា ឱ្យទទួលស្គាល់ទាំងអស់គ្នា

៥៩៧- គិតការរហ័សកុំឆាប់បោះបង់ អនុវត្តជាកង់គង់បានជោគជ័យ

៥៩៨- គុណភាពប្រសិទ្ធភាពគ្រូបង្រៀន អាចនាំឱ្យមានសហគមន៍ចូលរួម

៥៩៩- គ្រូបង្រៀនគ្មានកិច្ចតែងការ ប្រៀបដូចហោរាថាគ្មានក្បួន

៦០០- គ្រូបង្រៀនត្រូវចេះផ្លាស់ប្តូរចំណេះ បើមិនដូច្នេះសិស្សផ្លាស់ប្តូរគ្រូវិញ

៦០១- ដឹកនាំអ្នកដទៃបានសុខ ទើបមានក្តីស្ងប់ក្នុងអាត្មា

៦០២- ដឹកនាំឱ្យគេខ្លាចបានត្រឹមខ្លើមស្អប់ ដឹកនាំប្រសប់បានបេះដូងស្រឡាញ់

៦០៣- ដឹកនាំមិនឱ្យគេជួបក្តីវិនាស គឺមិនអាចជៀសរួចពីពាក្យគេជេរ

៦០៤- ដឹកនាំគួរគិតពីលទ្ធផល ទើបបានដល់អ្នកដឹកនាំល្អ

៦០៥- ដឹកនាំគ្មានយន្តការត្រួតល្អ រាយការណ៍បន្តភូតបណ្តាក់

៦០៦- ដឹកនាំជាប្រយោជន៍សម្រាប់គេ ចំណែកខាងជេរសម្រាប់ខ្លួនឯង

៦០៧- តម្លៃនៃគ្រូមានបីក្នុងខ្លួន មួយក្រៅសាច់ បៀវត្សរ៍ក្រៅសាច់ បីចាំបាច់ស្រេចខ្លួនអ្នកធ្វើ

៦០៨- តួនាទីរបស់នាយកសាលា÷ ជាអាជ្ញាធរអប់រំ, ជាមន្ត្រីរដ្ឋបាល, ជាទីប្រឹក្សាគរុកោសល្យ, ជាអធិការអប់រំអចិន្ត្រៃយ៍, ជាភ្នាក់ងារអភិវឌ្ឍរបស់សហគមន៍

៦០៩- ឋានៈខ្ពង់ខ្ពស់ប្រកាន់ខ្លួនទាប ទើបជាសុភាពនៃអ្នកដឹកនាំ

๖๑๐- ទីណាមានសំរាម អ្នកគ្រប់គ្រងទីនោះមានសមត្ថភាពទាបជាងសំរាម
๖๑๑- ធនធានមនុស្សជាកម្លាំងទីពីរ បញ្ហាមូលមីអង្គភាពខ្ពង់ខ្ពស់
๖๑๒- ធ្វើបានថ្ងៃនេះហើយបាត់ថ្ងៃក្រោយ ព្រោះតែបណ្តោយពីអ្នកដឹកនាំ
๖๑๓- បរិមាណបង្ហាញពីគុណភាព រីការឈ្លាសឆ្លាតបង្ហាញពីសមត្ថភាពប្រពៃ
๖๑๔- បរិមាណបានពីគុណភាព បរិមាណទាបគុណភាពអន់
๖๑๕- បរិមាណ រីកចម្រើន គឺបានចាប់ផ្តើមពីគុណភាព
๖๑๖- បុគ្គលិកប្រៀបដូចជាកង់រត់ នាំការអភិវឌ្ឍដល់គោលដៅ
๖๑๗- បុគ្គលិកធ្វើខុស ជាកំហុសរបស់មេដឹកនាំ
๖๑๘- បុគ្គលចេះសហការជាក្រុម គឺមានសុខដុមក្នុងអង្គភាព
๖๑๙- បង្រៀនដែលមានកិច្ចតែងការ គឺជាគោលការណ៍នៃអប់រំ
๖๒๐- បង្រៀនមានកិច្ចតែងការ ប្រៀបដូចច្រវាអុំទូកទៅមុខ
๖๒๑- បើអ្នកដឹកនាំប្រព្រឹត្តខុស ពិតជាកំហុសការដឹកនាំ
๖๒๒- បើហ៊ានថា ត្រូវត្រៀមធ្វើឱ្យកើត ទើបជាកំណើតនៃអ្នកដឹកនាំ
๖๒๓- បើមានវោហារហើយធ្វើឱ្យកើត ពិតជាកំណើតនៃអ្នកដឹកនាំ
๖๒๔- បើមេមិនគោរពម៉ោង មិនអាចនាំហ្វូងគោរពវេលា
๖๒๕- បើចេះគិតសង្វែកជីវិតគេ ទើបក្លាយជាមេដឹកនាំប្រពៃ
๖๒๖- បើសាលាគ្មានសំរាម នៅផ្ទះក៏គ្មានសំរាមដែរ
๖๒๗- ប្រសិទ្ធភាពនៃការដឹកនាំល្អ គឺចេះព្យាករនិងក្តាប់ឱកាស
๖๒๘- ប្រើប្រាក់រដ្ឋ ទាក់លុយសហគមន៍ ទើបនាំសង្គមអភិវឌ្ឍប្រែប្រួល
๖๒๙- មនុស្សល្អនៅត្រង់ប្រព្រឹត្តល្អ អ្នកដឹកនាំបវរ គឺដឹកនាំក្នុងផ្លូវត្រូវ
๖๓๐- មេដាយឬលិខិតសរសើរ ពុំអាចថ្លៃស្មើរាស្ត្រគាំទ្រ
๖๓๑- មិនប្រាកដថាមេចាំតែដឹក កិច្ចខ្លះកូនថ្នឹកនាំមេក៏មាន
๖๓๒- មួយមិន ប្រាំមាន គឺជាវិញ្ញាណនៃអ្នកដឹកនាំ÷ ១មិនអាត្មានិយម ៥មាន

ឆន្ទៈ អត់ធ្មត់ ព្យាយាម ស្មោះត្រង់ លះបង់ ធ្វើឱ្យចំណង់ជឿនាំជោគជ័យ

៦៣៣- លក្ខណសម្បត្តិនៃអ្នកដឹកនាំ “ទម ការអប់រំខ្លួនឯង, ខន្តី ការអត់ធ្មត់, សច្ចៈ ការស្មោះត្រង់, ចាក ការលះបង់”

៦៣៤- លទ្ធផលសិក្សារបស់សិស្ស ជាកញ្ចក់ឆ្លុះសមត្ថភាពគ្រូ

៦៣៥- លទ្ធផល ជាម៉ែត្រវាស់ទ្វរគុណភាព

៦៣៦- វិន័យគឺមិនអាចទិញដូរ ប៉ុន្តែជាថ្នូរមានតម្លៃ

៦៣៧- វិន័យនាំឱ្យអង្គភាពមានរបៀប វិន័យនាំមនុស្សជាតិឱ្យថ្លៃថ្នូរ វិន័យនាំឱ្យគុណភាពសិក្សាប្លែ វិន័យរក្សាថ្នូរស្ថិរភាពសង្គម

៦៣៨- សមាសភាពគ្រប់គ្រងមានចំនួនតិច តែមានគំនិតច្រើនទើបបង្កើនការពិត

៦៣៩- សម្អាតសាលារៀនដូចភ្លៀងរលឹម ទើបអាចសង្ឃឹមមានបរិស្ថានល្អ

៦៤០- សម្តីថ្នាក់លើមិនសុទ្ធតែត្រូវ ថ្នាក់ក្រោមថាទៅសុទ្ធសឹងតែខុស

៦៤១- សីល៦ប្រការ នៃអ្នកដឹកនាំ÷ ១-ការអត់ធន់ (ការអត់ធ្មត់មិនញាប់ញ័រដោយការស្តប់ ឬស្រឡាញ់), ២-ការភ្ញាក់រឭក (ការស្វែងរកចំណេះដឹងសម្រាប់ខ្លួនឯង និងអ្នកដទៃ), ៣-ការអាណិតអាសូរ (ការចេះជួយដល់អ្នកជួបការលំបាកប្រកបដោយបញ្ញា និងគុណធម៌), ៤-ការខុស្សាហ៍ព្យាយាម (ការខិតខំប្រឹងប្រែងជួយអង្គភាពដោយម្ចាស់ការមិនរង់ចាំជំនួយ និងមានគំនិតច្នៃប្រឌិត), ៥-ការរំពៃមើលការខុសត្រូវ (ការចាត់ចែងដោយតម្លាភាព ត្រួតពិនិត្យត្រឹមត្រូវមិនទម្លាក់កំហុសដល់ថ្នាក់ក្រោម), ៦-ការចែករំលែក (អំណាចអនុវត្ត ដល់អ្នកដទៃការមិនក្តោបអំណាច គ្មានភាពលម្អៀង បក្ខពួកនិយម)

៦៤២- សាលារៀនស្អាតកុំទាន់ថាល្អ បើគ្មានគ្រូល្អនៅជាប្រចាំ

៦៤៣- សាលារៀនល្អកុំទាន់ថាស្អាត បើគ្រូមិនសង្វាតជាប្រចាំ

៦៤៤- សាលារៀនផ្លាស់ប្តូរឬមិនផ្លាស់ប្តូរ អាស្រ័យលើជំហរនៃអ្នកដឹកនាំ

៦៤៥- សាលារៀនស្អាតមិនស្ថិតនៅលើតែគ្មានសំរាម បើស្អាតប្រចាំ សិស្សចេះចោលទើបសាលារៀនល្អ

៦៤៦- សាលារៀនស្អាត អប់រំសិស្សល្អ ទើបមិនបង្កប៉ះពាល់បរិស្ថាន

៦៤៧- សាលារៀនសម្រាប់អ្នកជំនាន់ថ្មី ពំនាក់អាស្រ័យស្មារតីគ្រូបង្រៀន

៦៤៨- សាលារៀនស្អាតមិនមែនគ្មានសំរាមទេ ប៉ុន្តែសាលារៀន ដែលមានសំរាមហើយគ្មានសំរាមទើបជាសាលារៀនល្អ

៦៤៩- សាលារៀនរីកចម្រើន សហគមន៍អភិវឌ្ឍ

៦៥០- សាលារៀនដែលថ្កើងថ្កានបាន ដោយសារសណ្តានចិត្តស្មោះសរនៃគ្រូបង្រៀន

៦៥១- សាលារៀនគ្មានការគាំទ្រពីគ្រួសារ លទ្ធផលសិក្សាកុមារនៅមានកម្រិត

៦៥២- សាលារៀនមិនត្រូវការ គ្រឿងញៀនកញ្ឆាស្រា និងផ្សែងបារី

៦៥៣- សាលារៀនដែលមានសោភ័ណភាព គ្រូរួមគ្នារៀបដោយចិត្តមេត្រី

៦៥៤- សាលារៀនស្អាតគ្រូអប់រំសិស្សល្អ ទើបជាសសរធនធានមនុស្សពិត

៦៥៥- សាលារៀនរដ្ឋនិងសហគមន៍សហការរឹងមាំ បានអន្ទងនាំក្រុមហ៊ុនឯកជនចូលរួមអភិវឌ្ឍ

៦៥៦- សាលារៀនមួយមានតួឯកបួន ទើបជួយអង្រួនការអភិវឌ្ឍ

៦៥៧- ស្មាដៃការងារអង្គភាពអ្នកធ្វើ មកពីថ្នាក់លើចេះវាយតម្លៃ

៦៥៨- ហេតុដែលប្រជែងគ្នាចាក់ដីឱ្យខ្ពស់ ព្រោះគ្មានអ្នកដឹកនាំដោះដោយបញ្ញា

៦៥៩- អង្គភាពគ្មានវិន័យសណ្តាប់ធ្នាប់ ព្រោះមកពីងាប់ន្លូវមនសិការ

៦៦០- អនុវត្តទ្រឹស្តីមិនមើលស្ថានការណ៍ នាំឱ្យបរាជ័យការដឹកនាំ

៦៦១- អង្គភាពមានបុគ្គលអាត្មានិយម នាំឱ្យសង្គមគ្មានការអភិវឌ្ឍ

៦៦២- អង្គភាពដែលទទួលបានលទ្ធផលល្អ មកពីបុគ្គលស្មោះសររួមសាមគ្គី

៦៦៣- អាជីពគ្រូគ្មានអារម្មណ៍បង្រៀន នាំឱ្យអ្នករៀនគ្មានលទ្ធផលល្អ

៦៦៤- អ្នកដឹកនាំដែលមានការិះគន់ ត្រូវខំកែកុនស្វែងរកកំហុស

៦៦៥- អ្នកដឹកនាំអគុណបាត់គោរព ប្រៀបដូចឈើពុកហើយប្រហោងក្នុង

៦៦៦- អ្នកដឹកនាំលើកតម្កើងខ្លួនហួស អាចនាំនូវគ្រោះចំពោះខ្លួនឯង

៦៦៧- អ្នកដឹកនាំដូចលាបម្សៅឡើងឆាក លទ្ធផលពិបាកធ្លាក់ដល់សង្គម

៦៦៨- អ្នកដឹកនាំដែលមានមនសិការ មានក្តីប្រាថ្នាជួយជាតិសង្គម

៦៦៩- អ្នកដឹកនាំដែលចាត់ទុកថាអស្ចារ្យ គឺជួយគ្រួសារគ្មានបញ្ហាដល់ជាតិ

៦៧០- អ្នកដឹកនាំគ្មានបេះដូងពិត ធ្វើឱ្យជីវិតបរាជ័យ

៦៧១- អ្នកដឹកនាំចេះចលនាចូលរួម កំពុងលើកស្ទួយកម្លាំងគាំទ្រ

៦៧២- អ្នកដឹកនាំដែលគ្មានគុណធម៌ ធ្វើឱ្យវឹកវរដល់សង្គម

៦៧៣- អ្នកដឹកនាំគ្មានការចូលរួម កំពុងបង្រួញនូវអំណាច

៦៧៤- អ្នកដឹកនាំដែលប្រកបដោយអំណាច ប្រមូលអំណាចតាមគំនិតចូលរួម

៦៧៥- អ្នកដឹកនាំកុំកំសាកធ្វើសេចក្តីល្អ បែរជាស្មោះសរតែនឹងអំពើអាក្រក់

៦៧៦- អ្នកដឹកនាំគ្មានការលះបង់ កំពុងបាត់បង់នូវអំណាច

៦៧៧- អ្នកដឹកនាំដែលច្រណែនឥស្សា ដូចនាំអាត្មាឯងឱ្យវិនាស

៦៧៨- អ្នកដឹកនាំវ័យក្មេងធ្វើកិច្ចការល្បឿនលឿនរហ័ស អ្នកដឹកនាំចាស់យឺតតែពិសោធន៍ខ្លះច្បាស់ជាងក្មេង

៦៧៩- អ្នកដឹកនាំស្គាល់ពីសុខទុក្ខ គឺជាជង្រុកនៃធនធាន

៦៨០- អ្នកដឹកនាំមិនគួរបង្ហាញឫកឱ្យគេគោរព គំរូនាំមុខធ្វើឱ្យក្នុនចៅគោរពទើបថ្លៃ

៦៨១- អ្នកដឹកនាំត្រូវចេះបង្កើតគំនិតថ្មី មានបញ្ញាស្មារតីចេះច្នៃប្រឌិត ចេះចលនាមិត្តជួយមិត្តរួមរស់ខ្ពស់ត្តម

៦៨២- អ្នកដឹកនាំកុំខ្វាយខ្វល់នឹងពាក្យគេសរសើរិះគន់ថា គួរធ្វើកិច្ចការឱ្យអ្នកសរសើរជេរថាបានជាប្រយោជន៍

៦៨៣- អ្នកដឹកនាំអង្គភាពអាត្មានិយម មិនអាចសង្គមសុខដុមចម្រើន
៦៨៤- អ្នកដឹកនាំធ្វើគំរូលួដល់រាស្ត្រ គឺមានតេជៈនាំឱ្យរាស្ត្រគាំទ្រ
៦៨៥- អ្នកដឹកនាំពិត ត្រូវមានគំនិតច្នៃប្រឌិតជាប្រចាំ
៦៨៦- អ្នកដឹកនាំជោគជ័យព្រោះឆ្លាតវៃការគ្រប់គ្រង ដើរតាមគន្លងច្នៃប្រឌិត មានគំនិតផ្តើម
៦៨៧- អ្នកក្រោមចេះភរ អ្នកលើចំហឱ្យរៀនកុហក
៦៨៨- អ្នកដឹកនាំ ត្រូវដាក់ខ្លួនឱ្យទាប ដកកឱ្យខ្ពស់ទស្សនៈវែងឆ្ងាយ
៦៨៩- អ្នកដឹកនាំមានគំនិត ទើបនាំឱ្យមានជំនួយ
៦៩០- អ្នកដឹកនាំមានគំនិត ទើបមានពិតអ្នក មកជួយ
៦៩១- អ្នកដឹកនាំមានចិត្តលម្អៀង ដូចជាភ្លៀងកណ្តាលថ្ងៃក្តៅ
៦៩២- អ្នកដឹកនាំមានសីលប្រាំមួយ មានតម្លៃជួយអ្នកដឹកនាំ
៦៩៣- អ្នកដឹកនាំល្ងង់ប្រើអំណាច អ្នកដឹកនាំឆ្លាតប្រើបញ្ញា
៦៩៤- អ្នកដឹកនាំគាំពារកូនចៅ ដូចសត្វម្រឹគញីបំបៅកូន
៦៩៥- អ្នកដឹកនាំដែលសម្តែងឫក ដូចសត្វម្រឹគនៅព្រៃតែឯង
៦៩៦- អ្នកដឹកនាំ មិនគប្បីក្លាយជាអ្នកនាំពាក្យគ្មានភាពជាអ្នកដឹកនាំ
៦៩៧- ឯកសណ្ឋានគ្រូទាំងដប់មួយពណ៌ តែចិត្តរួមពណ៌សង្គតែមួយ

ផ្នែកទី៣. ការអប់រំ ឬដឹកនាំគ្រួសារ និងសង្គម

๖๙๘- ការមិនបៀតបៀនគ្នា ជាប្រភពនៃសន្តិសុខក្នុងផ្ទៃលោក

๖๙๙- ការងារត្រូវតែមានទំនាក់ទំនង ទើបជាគន្លងនៃកិច្ចអភិវឌ្ឍ

๗๐๐- ការយល់បានមកពីពន្យល់ត្រូវ ទើបបានជាផ្លូវនៃការចូលរួម

๗๐๑- ការពង្រឹងយុវជនក្នុងវិស័យអប់រំ ធ្វើឱ្យសង្គមរីកចម្រើនរៀងរហូត

๗๐๒- ការអប់រំផ្សារភ្ជាប់នឹងពលកម្ម

๗๐๓- ការអប់រំចំពោះមនុស្សពាល ប្រៀបដូចប្រមៀលថ្មឡើងលើភ្នំ

๗๐๔- ការបង្រៀន មិនបានអប់រំ ជាគ្រោះដ៏ធំដល់អ្នកសិក្សា

๗๐๕- ការលំបាកម៉ែទ្រាំមិនប្រាប់កូន ដោយខ្លាចមាសស្ងួនពិបាកព្រោះម៉ែ

๗๐๖- ការចេះលើកស្ទួយ ជាពន្លឺមួយនៃការអភិវឌ្ឍ

๗๐๗- ការងារអភិវឌ្ឍន៍ដែលវិជ្ជមាន គឺក្តាប់ព័តិមានទំនាក់ទំនង

๗๐๘- ការងារពិបាកអាចធ្វើឱ្យងាយបាន ការពិបាកស្មានគឺចរិតមនុស្ស

๗๐๙- កុមារឡើងចាង មកពីចាស់កាង ទើបចាងបានកើត

๗๑๐- ការលេងល្បែងស៊ីសងថាកម្សាន្ត អសោចសន្តានពូជទាំងគ្រួសារ

๗๑๑- ការងារល្អ ទំនាក់ទំនងល្អ ចំណេះដឹងខ្ពស់ ជាកិត្តិយសសម្រាប់សង្គម

๗๑๒- ការប្រព្រឹត្តអំពើពុករលួយ គឺជាបូសត្រួយបំផ្លាញសង្គម

๗๑๓- ការគាំពារបរិស្ថានឱ្យបានរស់ ទើបអាចសង្គ្រោះការអភិវឌ្ឍល្អ

๗๑๔- ការអប់រំបរិស្ថានដែលជោគជ័យ មកពីស្មាដៃនៃអ្នកចូលរួម

๗๑๕- ការបែកបាក់សាមគ្គីគ្រួសារអង្គភាពសង្គម បូសគល់ដែលធំគ្រួសារនិយមក្រុមបក្ខពួក

๗๑๖- ការកែទម្រង់អប់រំដោយស្ងប់ភាព ជាវីរភាពលើកស្ទួយដល់សង្គម

๗๑๗- ការអង្គុយដែលមានរបៀប គឺជាមារយាទស្ងួយសង្គម

៣១៨- ការជួយកែប្រែទម្លាប់មិនល្អ ច្រើនតែតបតដោយពាក្យជ្រុជាតិ

៣១៩- ការអប់រំកុមារជាតួនាទីរបស់យើងទាំងអស់គ្នា

៣២០- ការងារដែលគួរមិនស្វះជាគាប់ សម្រាប់ទម្លាប់នៃមនុស្សខ្ជិល

៣២១- ការរឹងចចេសដោយគំនិតងប់ គឺជាប្រភពនៃក្តីវិនាស

៣២២- ការអប់រំដែលមានលទ្ធផលល្អ គឺសិស្សផុតក្រហើយល្អជាងគ្រូ

៣២៣- ការរស់ដោយចេះចែករំលែក គឺជាផ្នែករស់ដោយសុខដុម

៣២៤- ការអប់រំមិនចំគោលដៅបញ្ហា នាំឱ្យកិច្ចការមិនសម្រេចបំណង

៣២៥- ការងារមមាញឹកទោះយប់ល្ងាចព្រឹកព្យាយាមធ្វើ កុំរស់អត់អំពើគ្មានប្រយោជន៍ដល់ញាតិសង្គម

៣២៦- ការគ្រប់គ្រងសំរាមនៅក្នុងធុងបាន ទាល់តែសន្តានមានសំរាមក្នុងចិត្ត

៣២៧- ការព្យាយាមកំណែទម្រង់ ជាប្តង់គំនិតជំនាន់ក្រោយ

៣២៨- ការគោរពច្បាប់វិន័យគឺមានអំណាច ការមិនកោតខ្លាចច្បាប់អំណាចត្រូវបាត់បង់

៣២៩- ការចាប់ផ្តើមធ្វើគំរូពីមន្ត្រី នាំរាស្ត្រឃ្លាតខ្មីត្រាប់ដោយប្រណិប័តន៍

៣៣០- កិច្ចសហប្រតិបត្តិការល្អ គឺជាសសរទ្រទ្រង់សង្គម

៣៣១- កិត្តិយសសង្គមគឺបញ្ហាសំរាម ត្រូវជនគ្រប់ប្រាណទុកដាក់ឱ្យត្រឹមត្រូវ

៣៣២- កិត្តិយសសង្គមពឹងលើម្ចាស់សំរាម គួរជាប្រចាំវេចខ្ចប់ចោលឱ្យល្អ

៣៣៣- កីឡានាំមកស្មារតីសាមគ្គី ចងមិត្តមួលមីរួបរួមកសាង

៣៣៤- កីឡាជួយកំចាត់គ្រឿងញៀនសុរា ដែលជាប្រការជួយគ្រួសារសង្គម

៣៣៥- កីឡាគឺជាប្រភពកម្លាំង ជាឱសថច្បាំងប្រឆាំងមេរោគ

៣៣៦- កីឡាមិនមែនជាល្បែងស៊ីសង ដែលតែងអ្នកផងភ្នាល់ស៊ីសងគ្នា

៣៣៧- កុមារប្រៀបដូចជាក្រដាសពណិស ចាត់ជាមនុស្សល្អ នៅក្នុងពិភពលោក

៣៣៨- កូនខ្មែរត្រូវតែស្រឡាញ់ ការពារមាតុភូមិ

៧៣៩- កុំពេលជួបជុំចេះតែខុសទាស់ ដល់បែកគ្នាអស់ទើបនឹកស្តាយក្រោយ

៧៤០- កុំឱ្យឆ្នេះឆ្នយក្រែងលោមានវិបត្តិ ឧបសគ្គមកកំចាត់ពិបាកកែកុន

៧៤១- កើតមួយជាតិត្រូវតែសងដល់សង្គម កុំរស់គ្រោះធំនាំសង្គមរលាយ

៧៤២- កើតមកមួយជាតិកត្តាសុខភាព សុវត្ថិភាព ជីវភាពជាបញ្ហាចម្បង

៧៤៣- កើតមួយជាតិគួរឆ្លៀតសងសង្គម គប្បីគួរកុំរស់បំផ្លាញជាតិ

៧៤៤- កើតមួយជាតិគប្បីឆ្លៀតសងគុណសង្គម កុំរស់ធាត់ធំបំផ្លាញសង្គមជាតិឯង

៧៤៥- កូនចាប់កំណើតពុកម៉ែសប្បាយ កើតទុក្ខខ្វល់ខ្វាយពេលកូនមិនល្អ

៧៤៦- ក្រុមគ្រួសារមានកិច្ចសហការ ធ្វើឱ្យកុមារមានភាពរឹងមាំ

៧៤៧- ក្នុងសង្គមមនុស្សនាពេលបច្ចុប្បន្ន មនុស្សច្រើនពេកពន់ផ្គាប់គុណកិលេស ស៊ីចាយដើរដេក ឬក៏ស្លៀកពាក់ គឺច្រើនពំនាក់ទៅលើកិលេស

៧៤៨- ក្មេងនិងទឹក ក្មេងនិងព្រៃ ក្មេងនិងដី ចូរឪពុកម្តាយឃ្លាតខ្មី ប្រុងប្រយ័ត្នកុំឱ្យថ្លោះឆ្គោយក្រែងលោមានវិបត្តិ ឧបសគ្គមកកម្ចាត់ពិបាកកែកុន

៧៤៩- ខ្មែរមិនចេះខ្មែរចេះតែអង់គ្លេស អសោចកើរ្តីណាស់អ្នកស្តាប់មិនយល់

៧៥០- ខ្មែរមិនចេះខ្មែរថាចេះតែបរទេស គួរសង្វេគណាស់កូនខ្មែរមិនមែនខ្មែរ

៧៥១- ខ្លឹមសារនៃសាលាកុមារមេត្រី÷ កុមារទាំងអស់ត្រូវបានចូលរៀន, ការសិក្សាប្រកបដោយប្រសិទ្ធភាព, ការការពារកុមារ សុវត្ថិភាព និងសុខភាព, ការឆ្លើយតបទៅនឹងយេនឌ័រ, ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ និងការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ

៧៥២- ខ្លឹមសារនៃការអប់រំចតុស្តម្ភ “រៀនដើម្បីឱ្យមានចំណេះដឹង, រៀនដើម្បីឱ្យមានចំណេះធ្វើ, រៀនដើម្បីឱ្យមានគុណធម៌ និង រៀនដើម្បីឱ្យចេះរស់នៅជាមួយគ្នា”

៧៥៣- ខ្លឹមសារនៃព្រហ្មវិហារធម៌ “មេត្តា សេចក្តីប្រណីចង់ឱ្យអ្នកដទៃសុខចំរើន, ករុណា សេចក្តីអាណិតអាសូរដល់អ្នកដទៃ, មុទិតា សេចក្តីរីករាយចំពោះ

ក្តីសុខអ្នកដទៃ, ឧបេក្ខា សេចក្តីតាំងចិត្តជាកណ្តាលមិនលម្អៀង”

๓๕๔- ខ្លឹមសារនៃសិទ្ធិកុមារកម្ពុជា“ សិទ្ធិរស់រានមានជីវិត, សិទ្ធិទទួលការការពារ, សិទ្ធិក្នុងការចូលរួម និង សិទ្ធិក្នុងការអភិវឌ្ឍ”

๓๕๕- ខ្លឹមសារនៃការអប់រំសមាសភាគ ๕÷ ការអប់រំបញ្ញា, ការអប់រំកាយ, ការអប់រំសិល្ប:, ការអប់រំពលកម្ម និងការអប់រំសោភ័ណ

๓๕๖- គប្បីកែប្រែវប្បធម៌ក្តីចត្រួយ បែរមកស្រោចជ្រួយទើបមានពូជល្អ

๓๕๗- គប្បីកុំឡើងនាំគ្នាក្តីចត្រួយ គួរស្រោចទឹកជួយទើបសង្គមល្អ

๓๕๘- គប្បីកុំធ្វើល្អតែនឹងមុខ អាចនាំទ្វន្ទ្វទុក្ខអ្នកជំនាន់ក្រោយ

๓๕๙- គប្បីរួមគ្នាគិតធ្វើថា ទើបជាកត្តានៃជោគជ័យ

๓๖๐- គប្បីបណ្ឌិតធ្វើអ្វីជាប្រយោជន៍ កុំឱ្យអសោចខ្វចកេរ្តិ៍ដល់សង្គម

๓๖๑- គុណភាពអប់រំជាតិរឹងមាំ នាំឱ្យប្រទេសជាតិរុងរឿង

๓๖๒- គួរជួយគិតធ្វើទើបជាប្រយោជន៍ កុំចាំកម្តោចស្រោចឱ្យរលត់

๓๖๓- គំនិតដែលគួរគប្បីកុំកប់ គឺជាកំណប់សម្រាប់សង្គម

๓๖๔- គំនិតពាលពិតជាមិនងាយកែ គួរចៀសកុំក្បែរសេពគប់ជាមិត្ត

๓๖๕- គោរពច្បាប់ចរាចរណ៍ រក្សាជីវិតល្អខ្លួននិងសង្គម

๓๖๖- គ្មានកិច្ចសហការសាលានិងគ្រួសារ លទ្ធផលសិក្សាគ្មានគុណភាព

๓๖๗- គ្រូបង្រៀនជាឪពុកពេទ្យដូចម្តាយ ខិតខំនឿយណាយរែកស្តាយសង្គម

๓๖๘- គ្រូបង្រៀនសាលាបឋមសិក្សាវត្តបូព៌ សម្រួចឆន្ទៈដើម្បីអនាគតកុមារ

๓๖๙- គ្រូបង្រៀនត្រៀមប្រយុទ្ធ ដើម្បីអនាគតកុមារ

๓๗๐- គ្រួសារសហការជាមួយសាលា ធ្វើឱ្យកុមារមានការអភិវឌ្ឍ

๓๗๑- គ្រួសារបែកបាក់នឹងបាត់តម្លៃ ព្រោះអធ្យាស្រ័យមិនលួនឹងគ្នា

๓๗๒- គ្រឿងអលង្ការជួយលម្អប្រាណ ចិត្តមារយាទបានលម្អសង្គម

๓๗๓- ងារជាឧកញ៉ាព្រោះបានជួយជាតិ ប៉ុន្តែកុំឆ្លៀតបំផ្លាញសង្គម

៧៧៤- ចងអាឃាតបានត្រឹមឃ្លាតសន្តាន ចងមិត្តវិញបានមូលមីសុខដុម

៧៧៥- ចាក់ដីខ្ពស់ព្រោះមិនចង់ឱ្យលិចទឹក មិនបានជានឹកលិចផ្ទះដទៃ

៧៧៦- ចិត្តម្តាយសុខព្រោះឃើញកូនសប្បាយ ឫជាចិត្តកាយដើម្បីកូនសុខ

៧៧៧- ចិត្តអាក្រក់ដែលមានមហិច្ឆតា នាំភាពឈឺផ្សាផ្សំវិចិត្តសង្គម

៧៧៨- ចំណងសាមគ្គីជ័រឯងមាំ គឺជាកម្លាំងខ្វះមិនបាន

៧៧៩- ចំណេះដឹងខ្ពស់ខ្វះសីលធម៌ នាំអគុណធម៌ក្នុងសង្គម

៧៨០- ចំណីអាហារជាអាវុធមុខពីរ មួយឱ្យរស់ជីវិ ពីរគឺសម្លាប់

៧៨១- ចំណីអាហារមានសារជាតិគីមី កំពុងសម្លាប់ជីវិអ្នកពិសា

៧៨២- ចំណីអាហារដែលមានអនាម័យល្អ នាំឱ្យសុខភាពបវរួបកាយមាំមួន

៧៨៣- ជំងឺអាត្មានិយម នាំឱ្យសង្គមវិនាស

៧៨៤- ជើងឆ្វេងដៃស្តាំស្របគ្នានៅពេលដើរបង់បោយ គប្បីធ្វើឱ្យទ្រឹស្តីប្រតិបត្តិគូគ្នាទើបអភិវឌ្ឍ

៧៨៥- ជោគជ័យអាស្រ័យមានការចូលរួម ទើបជួយបង្រួមការងារគ្រប់គ្រង

៧៨៦- ជោគជ័យអាស្រ័យនៃទំនាក់ទំនង កើតពីគន្លងដោយការប្រតិបត្តិ

៧៨៧- ដំដែកទាន់នៅក្តៅ ប្រដៅមនុស្សទាន់នៅក្មេង

៧៨៨- ដំណឹកនាំរៀនផ្តើមពីចេះគិត ទើបមានគំនិតជំនាញរបរ

៧៨៩- ដីរើជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្មាត់គង់មានភ្លេច

៧៩០- ដើរតែរៀនមិនដែលបានជួយធ្វើ ខាតឥតអំពើគ្មានជួយសង្គម

៧៩១- ដាំដើមឈើឱ្យប៉ងបួស បើដាំមនុស្សឱ្យបម្រុងចរិត សីលធម៌

៧៩២- ត្រូវបណ្ឌិតនិន្ទា លួជាងពាលលើកតម្កើង

៧៩៣- តម្លៃអប់រំមិននៅត្រឹមតែចេះថា ធ្វើកើតផងណាទើបរាប់ថាចេះប្រាកដ

៧៩៤- តម្លៃមន្ត្រីស្ថិតលើពេលវេលា សេវាការងារឱ្យ ប្រជារង់ចាំ

៧៩៥- ថ្ងៃណាក៏ជាថ្ងៃបុណ្យដែរ ឱ្យតែខ្មែរព្រមប្រតិបត្តិ

๗๙๖- ទឹកចិត្តម៉ែអប់រំរក្សាកូន ប្រៀបដូចជាក្បួនឱ្យមាសស្ងួនសុខ
๗๙๗- ទឹកឡើងនាំគ្នាប្រជែងចាក់ដីខ្ពស់ ដល់ពេលរងគ្រោះទឹកលិចទាំងអស់គ្នា
๗๙๘- ទឹកមានប្រឡាយរួចកាយពន្លប់ ប្រជែងគ្នាទប់លិចទាំងអស់គ្នា
๗๙๙- ទំនាក់ទំនង កុមារ សាលា គ្រួសារ និងសហគមន៍
๘๐๐- ទំនិញអ្នកមានទិញមិនហ៊ានត ទំនិញអ្នកក្រទិញតឱ្យថោក
๘๐๑- ទោះបីត្រូវខំប្រឹងយ៉ាងណា គ្មានកិច្ចសហការពីគ្រួសារ កុមារគ្មានការអភិវឌ្ឍ
๘๐๒- ធម្មជាតិជួយជីវភាពមនុស្ស ដោយយកចំណេះទៅប្រើវា
๘๐๓- ធម្មជាតិជួយមនុស្ស ពេលយើងចេះរក្សាថែ
๘๐๔- ធម្មជាតិធ្វើឱ្យជីវិតរស់ បើយើងទាំងអស់ចេះការពារ
๘๐๕- ធម្មជាតិបម្រើមនុស្ស ពេលអភិវឌ្ឍដោយសក្តា
๘๐๖- ធម្មជាតិបំផ្លាញមនុស្ស ពេលណាមនុស្សបំផ្លាញធម្មជាតិ
๘๐๗- ធម្មជាតិពំនាក់មនុស្ស រឹងមនុស្សពឹង ធម្មជាតិ
๘๐๘- ធម្មជាតិសម្លាប់មនុស្ស ពេលក្រុមមនុស្សបំផ្លាញវា
๘๐๙- ធ្វើអ្វីដើម្បីទទួលផលប្រសើរជាងគិតមិនដល់ធ្វើអ្វីដើម្បីតែធ្វើ
๘๑๐- ធ្វើអ្វីកុំតាមត្រាប់ ជាទម្លាប់មិនប្រពៃ ធ្វើអ្វីតាមការច្នៃឱ្យមានន័យទើបប្រសើរ
๘๑๑- ថ្មីគំនិត ច្នៃប្រឌិត មានមិត្តល្អ
๘๑๒- បទពិសោធន៍ដែលចែករំលែក អាចក្លាយជាមែកយកទៅដាំ
๘๑๓- បណ្ឌិតមានច្រើនអនេក ប៉ុន្តែចម្លែកខ្លះនូវបណ្ឌិតពិត
๘๑๔- បណ្ឌិតជួយជាតិ គប្បីកុំឆ្លៀតបំផ្លាញសង្គម
๘๑๕- បណ្ឌិតដែលចាត់ទុកថាមានយស តែងជួយសង្គ្រោះលើកស្ទួយសង្គម
๘๑๖- បណ្ឌិតត្រូវមានគំនិតជួយសង្គម នាំជនសុខដុមទើបជាបណ្ឌិតពិត
๘๑๗- បណ្ឌិតពិត តែងមានគំនិតចង់ជួយដល់អ្នកដទៃ

៨១៨- បណ្ឌិតពិត តែងមិនប្រព្រឹត្តមារយាទជាមនុស្សពាល
៨១៩- បណ្ឌិតដែលពិត ស្វែងរកគំនិតគិតជួយដល់ជាតិ
៨២០- បណ្ឌិតប្រើមធ្យោបាយទូន្មាន គ្មានគិតបៀតបៀនដល់អ្នកដទៃ
៨២១- បទពិសោធន៍ល្អជិតមិនដែលមើល ព្រោះខ្លាចការធ្វើតាមគេវាអន់
៨២២- បរិស្ថានស្អាត សុខភាពល្អ ជីវភាពរុងរឿង
៨២៣- បង្កជម្លោះគ្មានផលចំណេញ បើត្រូវគ្នាវិញចំណេញទាំងសង
៨២៤- បរិស្ថានគឺជាកត្តាស្លាប់រស់ អ្វីៗដែលរស់គឺព្រោះបរិស្ថាន
៨២៥- បង្រៀនតិច បើមានល្បិចសិស្សចេះច្រើន
៨២៦- ប្តីប្រពន្ធកុំទាស់ចាប់កំហុស គួរគិតកាលណោះស្នេហាក្មេងខ្ចី
៨២៧- បុណ្យនិងបាបមាននៅក្នុងចិត្ត យើងអ្នកប្រតិបត្តិរៀងរាល់ថ្ងៃ
៨២៨- បុណ្យប្រៃថាការធ្វើអំពើល្អ ម្តេចប្រជាករមិនព្រមប្រតិបត្តិ
៨២៩- បុណ្យនិងបាបមាននៅក្នុងចិត្ត តាមការប្រតិបត្តិនៃកិច្ចការងារ
៨៣០- បុណ្យនិងបាបតែងចែកដាច់ពីគ្នា គួរតែជនារើសយកខាងបុណ្យ
៨៣១- បុណ្យស្រុកយើងមានច្រើនណាស់ ប៉ុន្តែអ្នកស្គាល់បុណ្យច្បាស់មានដោយកម្រ
៨៣២- បុណ្យគឺបានដោយចេះចែករំលែក អ្នកខ្សត់អរត្រេកអរស្រស់ដោយសុខដុម
៨៣៣- បុគ្គលដែលអាត្មានិយម នាំឱ្យសង្គមរងវិនាស
៨៣៤- បុគ្គលព្យាយាមធ្វើល្អអ្វីមួយ កំពុងលើកស្ទួយសីលធម៌សង្គម
៨៣៥- បុគ្គលខ្ជិលតែងធ្វើកិច្ចការដោយខ្ជីខ្ជា គឺជាភ្នាក់ងារបំផ្លាញគ្រួសារសង្គម
៨៣៦- បើចង់លើកស្ទួយសិទ្ធិកុមារ មិនមែនរកការងារឱ្យកុមារធ្វើឡើយ
៨៣៧- បើជួយទិញរបស់ដែលកុមារលក់ ដូចជួយពង្វក់ឱ្យកុមារឈប់រៀន
៨៣៨- បើពិភពលោកគ្មានកុមារ ប្រៀបដូចជាស្បែអន្ធិកាសម្រាប់មនុស្សចាស់
៨៣៩- បើធឹកសុរាស្វមកុំបើកបរ នាំគ្រោះបន្តដល់អ្នកមិនដឹង

៨៤០- បើមានថ្ងៃនេះថ្ងៃស្អែកពិតជាមាន ថ្ងៃស្អែកវិញគ្មាន ដ្បិតគ្មានថ្ងៃនេះ
៨៤១- បើមានអ្នកឈ្នះក៏មានអ្នកចាញ់ មានអ្នកកំណាញ់ក៏មានអ្នកឱ្យ
៨៤២- បើគេមានកុំផ្តន្ទាទារឱ្យក្រ គប្បីអបអរមុនក្រក្រោយមាន
៨៤៣- បើមានអំណាចតាំងខ្លួនឱ្យទាប ជាប្រសិទ្ធភាពមានអំណាចយូរ
៨៤៤- បើពោលពាក្យពិតគំនិតប្រពៃ គឺមានអត្ថន័យជួយថ្មៃមនុស្សជាតិ
៨៤៥- បើគ្រាន់តែចេះក្នុងភាពខ្លៅ គឺនាំកម្ចៅដល់សង្គម
៨៤៦- បើមានគំនិតគួរព្រាងត្រៀមធ្វើ នៅគ្រប់អំពើសងគុណសង្គម
៨៤៧- បើបណ្ឌិតដែលមានតែឈ្មោះ អាចនាំនូវគ្រោះដល់សង្គម
៨៤៨- បើក្រទ្រព្យតែមានមារយាទ ទើបធ្វើឱ្យជាតិមិនរលាយ
៨៤៩- បើទស្សនកិច្ចគួរបានគំនិតជួយខ្មែរ កុំទស្សនកិច្ចដែរបែបទេសចរណ៍កម្សាន្ត
៨៥០- បើទស្សនកិច្ចកុំបែបកម្សាន្ត គួរមើលឱ្យបានទៅជាប្រយោជន៍
៨៥១- បើឆ្លងទុក្ខបានជាជង្រុកជោគជ័យ បើខ្លាចទុក្ខភ័យបរាជ័យប្រាកដ
៨៥២- បើបណ្ឌិតពិត តែងមានគំនិតជួយជាតិសង្គម
៨៥៣- បើនាំគ្នាថាតែមិនព្រមធ្វើ គឺជាអំពើដែលគ្មានប្រយោជន៍
៨៥៤- បើមានគុណភាពនៃការអប់រំ គឺមានសង្ឃឹមអនាគតល្អ
៨៥៥- បើរស់ឱ្យគាប់ងាប់មានន័យ ទើបមិនចង្រៃដល់សង្គម
៨៥៦- បើនៅក្នុងថ្នាក់ឬសាលារៀនមានសំរាម ទោះរាប់រយឆ្នាំក៏សំរាមមានក្នុងសង្គម
៨៥៧- បើហែកកេរ្តិ៍ញាតិឯងឱ្យគេស្តាប់ ដូចបានសម្លាប់តពូជវង្សត្រកូល
៨៥៨- បើរស់ក្នុងសង្គមពួកក្រុមញាតិ កុំមានមារយាទអាត្មានិយម
៨៥៩- បើមារយាទខ្ជិលមានអាជីពជាគ្រូ សាបព្រោះគំរូអាក្រក់ដល់សង្គម
៨៦០- បើមានមុខការធ្វើកុំចោលម្សៀត កេរ្តិ៍ឈ្មោះមារយាទញាតិមើលសាច់ការ

๘๖๑- បើមិនចាប់ផ្តើមដោយព្យាយាមពីថ្ងៃនេះ បំណងថ្ងៃនេះមិនបានជាផលថ្ងៃក្រោយ

๘๖๒- បើមានថ្ងៃនេះព្រោះមានថ្ងៃមុន បានជួយជំរុញឱ្យមានថ្ងៃនេះ

๘๖๓- បើដើរគ្រប់ទីដោយចេះសង្កេត គឺបានជាម៉ែត្រវាស់ទូរមារយាទ

๘๖๔- បើក្រមារយាទគ្មានញាតិជួយបាន ក្រសន្តានខ្លួចអសោចកើរ្តិ

๘๖๕- បើមានការងាររស់ជួយជាតិ ញាតិសន្តាន ទើបរស់ថ្កើងថ្កានបានដោយមិនអសោចកើរ្តិ

๘๖๖- បើអាចារ្យតាចេះគ្មានអាចារ្យធ្វើ មិនមានអំពើដល់ការអភិវឌ្ឍ

๘๖๗- បើអាណិតកុមារកុំជួយទិញ រកវិធីវិញជួយគេបែបណា

๘๖๘- បៀតបៀនព្រោះខឹងត្រូវខំចៀស ព្រោះខឹងវិនាសគូទាំងសង

๘๖๙- បង្រៀនឱ្យចេះជាការងាយ កែមិនពណ្ណរាយគឺទម្លាប់

๘๗๐- បង្រៀនឱ្យចេះទទួលខុសត្រូវ គឺលំនាំផ្លូវក្លាយជាមនុស្សល្អ

๘๗๑- ប្រទេសគ្មានអ្នកគោរពច្បាប់នាំកើតភ័យ គ្រួសារគ្មានវិន័យបាត់តម្លៃសង្គម

๘๗๒- បូស្សីតែងដុះជាគុម្ព មនុស្សត្រូវរស់សាមគ្គីជាក្រុមឱ្យដូចបូស្សី

๘๗๓- បូស្សីដុះជាគុម្ព មនុស្សរស់នៅប្រមូលផ្តុំបានសុខកន្លង

๘๗๔- ភាពល្បីល្បាញរបស់អ្នកចេះធ្វើ មកពីអ្នកមើលចេះវាយតម្លៃ

๘๗๕- ភាពសង្ហាអ្នកបើកបរធឹកជក់តាមផ្លូវ ជាកើរ្តិ៍ដ៏អាស្រូវដល់ភ្នែកអ្នកទេសចរ

๘๗๖- ភាពខ្វិលខ្វីខ្ចោ នាំទុក្ខវេទនាក្រុមគ្រួសារសង្គម

๘๗๗- ភាពជោគជាំដោយការស្រវឹង គឺបាត់ពំនឹងក្នុងជីវិត

๘๗๘- ភាពជោគជ័យ មិនពឹងអាស្រ័យចាំតែគេជួយ

๘๗๙- ភាពល្ងង់មកពីមិនចង់ចេះ ទើបគ្មានចំណេះសម្រាប់ខ្លួនពឹង

๘๘๐- ភាពហ្មត់ចត់ ប្រាកដជាជោគជ័យ

๘๘๑- ភាពអៀនប្រៀន តែងមិនមានសិរីដល់អាត្មា

៨៨២- ពាលឬបណ្ឌិតស្តាប់តាមវាចា មើលពីសិរិយាទើបកំណត់ត្រូវ
៨៨៣- ពាក្យដែលពិតប្រៀបដូចគ្រាប់ស្លែង ល្ងីងចត់ក្រៃលែងសម្រាប់ពាល
៨៨៤- ពាក្យពិតល្ងីងដូចគ្រាប់ស្លែង ពាក្យបោកប្រែងផ្អែមដូចទឹកឃ្មុំ
៨៨៥- ពាក្យបណ្ឌិតពាលមិនងាយស្តាប់ ពាក្យថោកល្ងង់គ្រាប់ងាយកន្តង
៨៨៦- ពាក្យសម្តីមានន័យថោកឬថ្លៃ គឺវាអាស្រ័យនៃការប្រើប្រាស់
៨៨៧- ពាក្យទូន្មានប្រៀបដូចជាគ្រាប់ស្លែង ពាក្យបញ្ចោរតែងផ្អែមដូចទឹកឃ្មុំ
៨៨៨- ពាក្យទូន្មានប្រៀបដូចការប្រាប់ផ្លូវ គួរជនទូទៅចេះទទួលយក
៨៨៩- ពាក្យទូន្មាន រមែងដូចគ្រាប់ស្លែង បញ្ចោរមែងដូចសែងទៅដុត
៨៩០- ពាក្យប្រៀនហៅប្រាប់ថា ជាបន្ទានៃពាលស្តាប់
៨៩១- ពាក្យដោះសា ជាគំនរបញ្ហានៃការដោះស្រាយ
៨៩២- ពិភពលោកជាទ្រុងនៃមនុស្ស គួរជនស្រីប្រុសសង្វេគអាត្ម
៨៩៣- ពិបាកពត់កែមនុស្សខ្លៅ ពិបាកប្រដៅល្ងង់ធ្វើចេះ
៨៩៤- ពិបាកបំផុតគឺកែមារយាទ ដែលមានសារជាតិផ្តើមពីគ្រួសារ
៨៩៥- ពិធីបុណ្យមានច្រើនអនេក ប៉ុន្តែចម្លែកមិនស្មើមានមនុស្សលួ
៨៩៦- ពេលនៅជួបជុំគួរចេះរក្សាសុខ វេលាទៅមុខក្តីសុខមិនទៀងឡើយ
៨៩៧- ពេលវេលាពិតជាមិនទៀងទាត់ អ្វីៗវិវឌ្ឍប្រែប្រួលវិលវល់
៨៩៨- ពោលពាក្យពិតកុំប្រឱនញុះញង់ ទើបជៀសអន្លង់នៃការបែកបាក់
៨៩៩- ពោលពាក្យប្រហោងក្នុងជាយថាណាស់ បើមនុស្សក្មេងចាស់សុទ្ធតែប្រហោង បើកិលេសក្រាស់ធំប៉ុនភ្នំផង មនុស្សស្រីប្រុសផងព្រមយកទាំងអស់
៩០០- ពោលពាក្យបែបនេះក្រែងស្តាប់ពុំយល់ ខ្ញុំសូមលើកដល់រឿងក្នុងសង្គមជាឧទាហរណ៍ជូនមិត្ត និងម៉ែអាកុំទុកជាសណ្តាប់ និងពិចារណា
៩០១- ព្រះអាទិត្យបំភ្លឺតែពេលថ្ងៃ បណ្ឌិតកវីបំភ្លឺគ្រប់ពេល

៩០២- ពួកក្មេងៗចូលចិត្តភ្លើង ទឹក ឈើ ដី ចូរជនប្រុសស្រីមានស្មារតីប្រយ័ត្ន

៩០៣- ព្រះធម៌មិនត្រឹមចេះស្ងួត្រប៉ោចៗ អ្វីជាប្រយោជន៍យល់ហើយបដិបត្តិ

៩០៤- ព្យាយាមតាមបែបកំណែទម្រង់ ទើបមិនលិចលង់ដល់សង្គមជាតិ

៩០៥- មនុស្សគ្រប់រូបធ្វើចិត្តដូចសម្តេងតន្ត្រីបាន គឺជាសង្គមមនុស្សមួយថ្កើងថ្កានក្នុងលោកា

៩០៦- មនុស្សដែលចោលសំរាមពាសទឹកពាសដី ជាទង្វើមិនគប្បីសម្រាប់សង្គមជាតិ

៩០៧- មនុស្សដែលចោលសំរាមពាសទឹកពាសដី ជាទង្វើមិនគប្បីដល់កិត្តិយសជាតិ

៩០៨- មនុស្សចោលសំរាមពាសវាលពាសកាល ជាអ្នកនាំអន្តរាយកិត្តិយសសង្គម

៩០៩- មនុស្សនិងធម្មជាតិ មិនអាចរស់ឃ្លាតពីគ្នាបានឡើយ

៩១០- មនុស្សបីក្រុមដែលជួយកុមារ គឺគ្រូអាចារ្យ បិតា និងព្រះសង្ឃ

៩១១- មនុស្សអន់ចរិតមិនងាយសាងធន មិនដែលរែកពុនជួយសង្គមគ្រួសារ

៩១២- មនុស្សក្មេងទំនើង មកពីចាស់ធ្វើទ្រើងឱ្យវារឡើង

៩១៣- មនុស្សចាស់ជាអ្នកបង្រៀនន្ធវកំហុស ឬភាពត្រឹមត្រូវទាំងអស់ដល់មនុស្សក្មេង

៩១៤- មនុស្សខ្វចឈ្មោះ ព្រោះយកទ្រព្យរបស់ដែលគេមិនបានឱ្យ

៩១៥- មនុស្សពាលងាយណាស់ប្រព្រឹត្តន្ធវអំពើអាក្រក់

៩១៦- មនុស្សល្ងង់ធ្វើចេះ ជាមនុស្សខ្ចៅដំបៅដល់សង្គម

៩១៧- មនុស្សរស់ដោយចេះចែករំលែក ទើបបានជាផ្នែកជួយដល់សង្គម

៩១៨- មនុស្សចរិតអន់ កុំគិតថាគ្រាន់ជាងអ្នកដទៃ

៩១៩- មនុស្សចរិតអួតអាង បានត្រឹមសាងទុក្ខវេទនា

៩២០- មនុស្សដែលជាអាត្មានិយម មិនជួយសង្គមរស់ស្រួលតែឯង

៩២១- មនុស្សដែលរស់នៅលើផែនដី គ្រាន់តែអាស្រ័យបណ្តោះអាសន្ន

៩២២- មនុស្សតែឈ្មោះ ព្រោះតែរស់ដូចសត្វតិរច្ឆាន

៩២៣- មន្ត្រីជោគជ័យតែងតែបម្រើរាស្ត្រ មន្ត្រីយករាស្ត្រកញ្ជះបរាជ័យ

៩២៤- មិនគោរពច្បាប់ព្រោះគ្មានវិន័យ ចរិតមិនថ្លៃកិត្តិយសឯនអាប់

៩២៥- មានចំណេះដឹងច្រើន ចម្រើន ប្រទេសជាតិ

៩២៦- មានកង្វេះទើបជំរឹខ្លាច មានអ្នកប្រាជ្ញទើបប្រទេសរុងរឿង

៩២៧- មេផ្ទះទៅផ្សារ តែងយកថវិកាទៅចោលក្នុងធុងសម្រាម

៩២៨- ម៉ែចិញ្ចឹមថែកូនមកកន្លង គ្មានគំនិតប៉ងឱ្យកូនសងវិញ

៩២៩- ម្តាយគិតកូនដូចរលកប្រដេញ កូនគិតម៉ែវិញដូចខែរនោច

៩៣០- រសជាតិផ្អែមតែងតែមានជាតិជូរ រស់ជុំគ្នាយូរផ្អែមជូរកើតមាន

៩៣១- រស់មួយជាតិគួរតែឆ្លៀតសងដល់សង្គម កុំរស់កំពុងធ្វើឱ្យសង្គមរលាយ

៩៣២- រស់មួយជាតិឆ្លៀតបំផ្លាញសង្គម ស្លាប់ទៅស្អុយធំរស់អសោចកេរ្តិ៍

៩៣៣- រស់មួយជាតិធាតុតែមួយចាន គួរធ្វើអ្វីបានជួយជាតិសង្គម

៩៣៤- រក្សាញាតិជិតខាងរបង ប្រសើរកន្លងជាងធ្វើរបងរាប់សិបជុំ

៩៣៥- រាស្ត្រប្រៀបដូចត្រី មន្ត្រីជាទឹក ត្រីរស់រឹតព្រោះទឹកល្អក់ខ្វល់

៩៣៦- រាស្ត្រមានទឹកចិត្តស្រឡាញ់មន្ត្រី ព្រោះចិត្តភក្តីស្មោះត្រង់នឹងរាស្ត្រ

៩៣៧- រូបកាយបាត់បង់ទៅមែនពិត ឱ្យតែគំនិតនៅរស់រវើក

៩៣៨- រៀនឱ្យចេះអាណិត ទើបស្គាល់ពិតជីវិតសង្គម

៩៣៩- រៀនឱ្យមានគំនិតជុំ ទើបសុខុមជុំកម្លាំងប្រាជ្ញ

៩៤០- រៀនមាន៤ វដ្តឱ្យគាប់ជួនមើល ស្តាប់ គិត ធ្វើ

៩៤១- រៀនពីសង្គម គ្រួសារ សាលា គឺជាកត្តាវាសនាជោគជ័យ

៩៤២- រៀនចេះបង្កើតគំនិតថ្មី រៀនមានស្មារតីមិត្តជួយមិត្ត រៀនច្នៃប្រឌិតឱ្យប្រសើរ

៩៤៣- រៀនឱ្យចេះគិតបង្កើតនូវគំនិតថ្មី រៀនឱ្យមានស្មារតីចេះច្នៃប្រឌិត រៀន

ឱ្យមានមិត្តចេះជួយមិត្តជាប្រចាំ

៩៨៤- រៀនពូកែទើបពុកម៉ែស្រលាញ់

៩៨៥- លទ្ធផលសិក្សារបស់កុមារ បើមានយន្តការមានការប្រែប្រួល

៩៨៦- វិន័យនាំមកនូវភាពថ្លៃថ្នូរ គួរមានជំហរប្រតិបត្តិវិន័យ

៩៨៧- វិស័យអប់រំដែលប្រកបដោយគុណភាព គឺសមភាព ចេះដឹង ធ្វើមារយាទល្អ

៩៨៨- សង្គមដែលចាត់ថាប្រសើរពិត គឺបានប្រព្រឹត្តច្បាប់ទាំងអស់គ្នា

៩៨៩- សង្គមដែលតែងមានការវិវាទ មកពីជីវភាពមិនសមធម៌

៩៩០- សង្គមគ្មានអ្នកគោរពច្បាប់កើតភ័យ បុគ្គលគ្មានវិន័យបាត់តម្លៃគ្រួសារ

៩៩១- សារជាតិជាមនុស្សក្រពើ មិនដែលនឹកធ្វើតបគុណតម្លៃ

៩៩២- សារជាតិជាមនុស្សក្រពើ មិនដែលអើពើគុណអ្នកដទៃ

៩៩៣- សារជាតិជាមន្ត្រីតែងតែបម្រើរាស្ត្រ កុំឫកមានៈចាត់ទុករាស្ត្រជាខ្ញុំបម្រើ

៩៩៤- សាមគ្គីល្អ កិច្ចការបរិវប្រសើររុងរឿង

៩៩៥- សាមគ្គីជាកម្លាំង បែកកម្លាំងរលាយ

៩៩៦- សាមគ្គីមនុស្សជាកម្លាំងទីមួយ ជំរុញលើកស្ទួយអង្គភាពវិវឌ្ឍ

៩៩៧- សាមគ្គីល្អ កិត្តិយសថ្លៃថ្លាប្រសើរឧត្តម

៩៩៨- សារៈប្រយោជន៍នៃបណ្ណាល័យ គឺជាលទ្ធផលចុងក្រោយនៃអ្នកស្រាវជ្រាវ

៩៩៩- សំរាមមានមកពីចោលមិនចេះ ព្រោះតែចំណេះទាបស្មើសំរាម

៩៦០- សំរាមអាចច្នៃលក់បានជាកម្រៃ បើទុកមិនថ្លៃតម្លៃគំនិតថោក

៩៦១- ស្រឡាញ់កូនមួយតៅចៅមួយតោន ព្រោះតែជ្រកក្រោមនៃក្តីមេត្តា

៩៦២- សន្សំសំចៃ បានលើកតម្លៃដល់បរិស្ថាន

៩៦៣- សិស្សដែលល្អទៅបាន ដោយសារមានភាពរាក់ទាក់ស្និទ្ធស្នាលពីគ្រូបង្រៀន

៩៦៤- សិស្សល្អទៅដល់ផ្ទះត្រូវជម្រាបសួរឪពុក ម្តាយ

๙๖๕- សិស្សបញ្ញា ត្រូវព្យាយាមធ្វើកិច្ចការដែលមានប្រយោជន៍ដល់ខ្លួនឯង គ្រួសារ និងសង្គមជាតិ

๙๖๖- សម្តីពិរោះនឹងមិត្តមិនងាយប្រព្រឹត្តបាន ដោយមិត្តក្នុងក្រុមគ្រប់ប្រាណចេះមូលចិត្តសាមគ្គី

๙๖๗- សម្តីអាក្រក់តែចិត្តល្អ មានដោយកម្រអ្នកស្រឡាញ់

๙๖๘- សម្តីដែលចាត់ទុកថាបានការ ធ្វើកើតផ្លែផ្កាត្រជាក់សុខដុម

๙๖๙- សម្តីអាចារ្យអាចជាឱសថ ក៏ជាទឹកក្រូចបំផ្លាញអារម្មណ៍

๙๗๐- សន្និដ្ឋានចិត្តល្អឬអាក្រក់ អំពើកញ្ចក់អាចឆ្លុះធៀបបាន

๙๗๑- សិទ្ធិទាំងបួនរបស់កុមារ ចូរគ្រូគ្រួសារត្រូវចងចាំ

๙๗๒- សម្លេងតន្ត្រីដែលប្រគំពិរោះទៅបាន ដោយមិត្តក្នុងក្រុមគ្រប់ប្រាណចេះមូលចិត្តសាមគ្គី

๙๗๓- សម្លេងតន្ត្រីដែលប្រគំពីរោះទៅបាន ដោយមិត្តក្នុងក្រុមគ្រប់ប្រាណចេះមូលចិត្តសាមគ្គី

๙๗๔- សុខភាពមាត់ធ្មេញប្រសើរកន្លង ព្រោះញ៉ាំនំតែ២ដងក្នុង១ថ្ងៃ

๙๗๕- សំពះស្អាតញញឹមស្រស់ប្រតិបត្តិល្អ គឺជាសសរអប់រំតិរិយាបថថ្លៃ

๙๗๖- អាហារដែលមានរសជាតិពិត ព្រោះភាពប្រសប់អ្នកចម្អិន

๙๗๗- អ្នកលក់អាហារគ្មានអនាម័យ កំពុងប្រល័យដល់អ្នកពិសា

๙๗๘- អាហារដែលសម្ភាប់គឺមានពីរ មួយជាតិគីមី ពីរគ្មានអនាម័យ

๙๗๙- អគារសិក្សាថ្មីលើដីចាស់ ត្រូវបានប្តូរផ្លាស់ដោយមារយាទថ្លៃ

๙๘๐- អាចារ្យតាថេះទ្រីស្តីហៀរកែង អនុវត្តជាក់ស្តែងចេះបានត្រឹមថា

๙๘๑- អំពើត្រឹមត្រូវបែរជាខ្លាច ខុសបាត់អំណាចតែហ៊ានធ្វើ

๙๘๒- អំពើដែលមានមនសិការ បានផលផ្លែផ្កាដល់សង្គម

๙๘๓- អ្នកមានមិនប្រាកដថាមិនក្រ អ្នកមានរូបល្អមិនប្រាកដថាមិនអាក្រក់

៩៨៤- អ្នកមានមិនទៀងថាតែនៅមាន ដូចកាយវិញ្ញាណទៀងតែរលត់

៩៨៥- អ្នកប្រៀបព្រលឹងជាតិនឹងសុរា បង្ខូចសាវតារខ្មែរអ្នកប្រមឹក

៩៨៦- អ្នកបំផ្លាញធម្មជាតិ កំពុងតែរៀបខ្លួនឱ្យវិនាស

៩៨៧- អ្នកបំផ្លាញធម្មជាតិ ប្រៀបដូចបំផ្លាញខ្លួនឯង

៩៨៨- អ្នកផលិតស្រាបានជាប្រយោជន៍ ដល់កើរ្តិ៍អសោចសម្រាប់អ្នកផឹក

៩៨៩- អ្នកធ្វើកិច្ចការតែគ្មានកំណើត ជាប្រភពកើតនៃដើមបញ្ហា

៩៩០- អ្នកមានពិសោធចង់ចែករំលែក លួតែទាស់ភ្នែកដល់អ្នកមិនចង់

៩៩១- អ្នកចរិតពាលមិនងាយប្រដៅ បើចរិតខ្លៅគីប្រដៅយ៉ាប់

៩៩២- អ្នកលូងគង់បង្រៀនឱ្យចេះ តែទាល់តម្រិះប្រៀនប្រដៅខ្លៅ

៩៩៣- អ្នកមានមិនបានជួយអ្វីជាប្រយោជន៍ រស់កើរ្តិ៍អាសោចព្រោះមិនស្នួយសង្គម

៩៩៤- អ្នកបួសរួចបង្ខូចសាសនា ដូចមានផែនការបំផ្លាញជាតិ

៩៩៥- អ្នកកំសាកមិនដែលហ៊ានចេញមុខ ចាំតែចាក់រុកនៅពីក្រោយខ្នង

៩៩៦- អ្នកបួសមិនប្រតិបត្តិធម៌វិន័យ នាំបាត់តម្លៃដល់ពុទ្ធសាសនា

៩៩៧- អ្នកតូចនិងធំសុទ្ធតែបម្រើរាជការ គួរពិចារណាកុំហិង្សាបំពានសិទ្ធិ

៩៩៨- អ្នកលូងធ្វើចេះនាំប្រទេសលិចលង់ អ្នកចេះធ្វើលូងនាំសង្គមអន់ថយ

៩៩៩- អ្នកប្រើសារជាតិគីមីក្នុងអាហារ ជាឃាតករទីផ្សារនៃអ្នកប្រើប្រាស់

១០០០- អ្នកលក់អាហារកុំគិតតែពីចំណេញ ត្រូវជួយគិតផងវិញសុខភាពអ្នកពិសារ

១០០១- អ្នកដែលគ្មានគំនិតជាតិនិយម រូបិយសង្គមនិយមបរទេស

១០០២- អ្នកបើកបរបញ្ហាសចរាចរណ៍ អាចជាឃាតករនៅលើដងផ្លូវ

១០០៣- អ្នកដែលធ្វើឱ្យវិស័យអប់រំមានជោគជ័យ ពិតជាមានន័យជួយកែច្នៃសង្គមប្រាកដ

១០០៤- អ្នកបំពានច្បាប់តែងចង់បានសិទ្ធិ ប្រភេទនេះពិតគីមិនងាយកែ

១០០៥- អ្នកដែលសប្បាយមិនប្រាកដថាគ្មានទុក្ខ ឯអ្នកស្រណុកមិនប្រាកដថាសប្បាយ

១០០៦- អ្នកបួសឈ្លោះព្រោះដណ្តើមលាភ នាំឱ្យថោកទាបដល់សាសនា

១០០៧- អ្នកដឹកនាំមានគំនិតអាត្មានិយម នាំគ្រោះអាសន្នដល់សង្គមជាតិទៀងជាក់

១០០៨- អ្នកមានកិត្តិយសមិនប្រាកដមានតម្លៃ សកម្មភាពថ្លៃទើបតម្លៃបង្កើតយស

១០០៩- អ្នកបង្កើតព្យុះបានគឺជាខ្យល់ អ្នកប៉ះពាល់ផលគឺរាស្ត្រប្រជា

១០១០- អ្នកប្រព្រឹត្តអាក្រក់ធ្វើអ្វីមិនចេះខ្មាស់អៀន គួរអ្នកលួហ៊ានជួយអប់រំទើបសង្គមថ្កើង

១០១១- អ្នកដឹកនាំអប់រំនៅវ័យក្មេង ក្លៀវក្លាក្រៃលែងជួយជាតិសង្គម

១០១២- អ្នករស់ក្នុងសង្គម ត្រូវជួយពូនជុំ ទើបមាតុភូមិរុងរឿង

១០១៣- អនាគតភ្លឺថ្លានៃកុមារ ពឹងលើសាលា គ្រួសារ និងសង្គម

១០១៤- អ្វីដែលជួយបានគួរតែជួយ ព្រោះជាជំនួយបែបគុណធម៌

១០១៥- អ្វីដែលឈឺចាប់កាន់តែទ្វេ ខំប្រឹងជួយគេបែរជាខុស

១០១៦- អ្វីដែលថោកកែ មកឱ្យថ្លៃ ទើបជានិស្ស័យជាបណ្ឌិត

១០១៧- អ្វីដែលធ្វើបានគួរនាំគ្នាធ្វើ កុំទម្លាក់លើថាធ្វើមិនកើត

១០១៨- អ្វីដែលគប្បីខ្លាចគឺភាពខ្លៅ មិនងាយប្រដៅខ្លៅឱ្យក្លាយចេះ

១០១៩- អ្វីដែលពិបាក មិនងាយធ្វើបាន ទូន្មានខ្លួនប្រាណបានដោយកម្រ

១០២០- អ្វីដែលមាន ត្រូវចេះរក្សា កុំគិត ស្រវាអ្វីដែលអត់

១០២១- អ្វីដែលល្អគួររក្សាឱ្យមាន តែអ្វីដែលគ្មានគួរកុំដល់ខ្សត់

១០២២- អ្វីពិបាកធ្វើគឺការតបគុណ វាស្រាលតែធ្ងន់មិនងាយនឹកតប

១០២៣- អ្វីមានដោយកម្រកុំឱ្យបាត់ កុំដល់ពេលខ្ចាត់ទើបស្តាយស្រណោះ

១០២៤- អ្វីអត់ឱនបាន គួរតែអត់ឱន ធ្វើចិត្តជ្រកក្រោមម្លប់ដ៏ត្រជាក់

១០២៥- អ្វីទៅដែលជាចិត្តអកុសល នោះគឺបានដល់ចិត្តគ្មានមេត្តា

ឧបសម្ព័ន្ធ

១០២៦- អ្វីទៅដែលហៅថាចិត្តបុណ្យ គឺចិត្តអត់ធន់ជួយគ្រប់មនុស្សសត្វ
១០២៧- អ្វីៗធម្មជាតិជាអ្នកកំណត់ តែអ្វីប្រាកដមនុស្សជាអ្នកធ្វើ
១០២៨- តរិយាបថនៃអ្នកបរិស្ថាន ម្ចាស់ការខ្ជិនបានសុខសាន្តសង្គម
១០២៩- ឥទ្ធិពលនាំជោគជ័យដល់អ្នកសិក្សា មកពីគ្រូគ្រួសារប្រើពេលវេលា
១០៣០- តរិយាបថសណ្តាប់ធ្នាប់វិន័យ ធ្វើឱ្យប្រពៃដល់តម្លៃសិក្សា
១០៣១- តរិយាបថជាគំរូរបស់មន្ត្រី មានន័យប្រពៃជាងប្រើទ្រឹស្តីអប់រំរាស្ត្រ
១០៣២- ឯកទគ្គកម្មនៃមនុស្សពាល ចរិកមិនងាយកែជាបណ្ឌិត

មាតិកានុក្រមពិស្តារ

អារម្ភកថា..... I
សេចក្តីផ្តើម..... III
មាតិកាទី១. សាវតារ និងចក្ខុវិស័យ..... ១
ជំពូកទី១. មុនការដឹកនាំរបស់លោកនាយក ពឹង គិមឆេន ឆ្នាំ១៩៩៤..... ១
ផ្នែកទី១. មុនឆ្នាំ១៩៧៩..... ១
ផ្នែកទី២. ក្រោយឆ្នាំ១៩៧៩..... ១
ជំពូកទី២. ចាប់ពីការដឹកនាំរបស់លោកនាយក ពឹង គិមឆេន ឆ្នាំ១៩៩៤ ដល់បច្ចុប្បន្ន... ៣
ជំពូកទី៣. ចក្ខុវិស័យ និងយុទ្ធសាស្ត្រ..... ៧
ផ្នែកទី១. ចក្ខុវិស័យ..... ៧
ផ្នែកទី២. យុទ្ធសាស្ត្រ..... ៧
មាតិកាទី២. សម្ភារតិចាល..... ៩
ជំពូកទី១. សាលារៀន..... ៩
ផ្នែកទី១. ក្របខ័ណ្ឌស្ថាប័ន..... ៩
ក. រចនាសម្ព័ន្ធដឹកនាំ..... ៩
ខ. រចនាសម្ព័ន្ធគ្រប់គ្រង..... ១៤
ផ្នែកទី២. គុណតម្លៃរបស់សាលារៀន..... ២០
ក. វិញ្ញាណរបស់អ្នកដឹកនាំ..... ២០
ខ. លក្ខណសម្បត្តិរបស់អ្នកដឹកនាំ..... ២០
គ. គោលការណ៍ប្រចាំជីវិតរបស់អ្នកដឹកនាំ..... ២០
ឃ. លក្ខណសម្បត្តិនៃសេវាអប់រំ..... ២០
ផ្នែកទី៣. ការគ្រប់គ្រងធនធានគ្រូបង្រៀន..... ២១

ក. ព័ត៌មានទូទៅ ២១
ខ. ការលើកកម្ពស់គុណតម្លៃគ្រូបង្រៀន ២២
ផ្នែកទី៤. ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ២៤
ក. របបប្រជុំ ២៤
ខ. ការកសាងផែនការ ២៦
គ. ប្រភពថវិកា ២៦
ឃ. ការគ្រប់គ្រងថវិកា ២៧
ង. ការប្រើប្រាស់ថវិកា ២៨
ជំពូកទី២. សិស្សានុសិស្ស ២៩
ផ្នែកទី១. ការអប់រំសមាសភាគទាំង ៥ ..... ២៩
ក. ការអប់រំបញ្ញា ២៩
ខ. ការអប់រំពលកម្ម ៣០
ខ.១. ការអប់រំបរិស្ថាន ៣០
ខ.១.១. បរិស្ថានបុគ្គល ៣០
ខ.១.២. បរិស្ថានសង្គម ៣១
ខ.២. ការអប់រំផ្នែកកសិកម្ម ៣១
គ. ការអប់រំសិល្បៈ ៣២
ឃ. ការអប់រំកាយនិងកីឡា ៣៣
ង. ការអប់រំសោភ័ណ ៣៣
ផ្នែកទី២. សាសនា និងការអប់រំ ៣៤
ផ្នែកទី៣. គោលការណ៍ប្រតិបត្តិទាំង ៥ ..... ៣៤
ផ្នែកទី៤. មិត្តអប់រំមិត្ត ៣៨
ផ្នែកទី៥. ការត្រួតពិនិត្យវិន័យ ៣៨

ផ្នែកទី៦. ការលើកទឹកចិត្តសិស្សានុសិស្ស ៤២
ជំពូកទី៣. សហគមន៍ ៤៥
ផ្នែកទី១. សហគមន៍ជាតិ ៤៥
ផ្នែកទី២. សហគមន៍អន្តរជាតិ ៤៨
មាតិកាទី៣. ឧស្សាហវិស័យ ៥១
ជំពូកទី១. ភាពជាគំរូ ៥១
ជំពូកទី២. ការថែទាំគ្រាប់ពូជ នៅភូមិសិក្សាបន្ទាប់ ៥៣
ជំពូកទី៣. ការបន្តវេន ៥៥
សេចក្តីសន្និដ្ឋាន ៥៧
បញ្ជីឯកសារយោង ៥៩

គម្រោងសិក្សាស្រាវជ្រាវស្តីពី “**ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព**” ករណីសិក្សា “**មគ្គទេសក៍កំណែទម្រង់ គុណានុភាពនៃសាលាបឋមសិក្សាឥន្ទបូរិ**” ស្ថិតក្រោមការដឹកនាំនិងគ្រប់គ្រងផ្ទាល់របស់សាលាភូមិន្ទរដ្ឋបាល ដែលមានសមាសភាពក្រុមការងារ ដូចខាងក្រោម÷

ក. សមាសភាពថ្នាក់ដឹកនាំគ្រប់គ្រងគម្រោង÷

១. ឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនឆិន**	រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល
២. ឯកឧត្តម **យក់ ប៊ុនណា**	រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ និងជានាយកសាលាភូមិន្ទរដ្ឋបាល
៣. ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន**	អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល

ខ. សមាសភាពក្រុមការងារដឹកនាំនិងប្រតិបត្តិគម្រោង÷

១. ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន**	ប្រធាន
២. ឯកឧត្តម **សុខ សេងយ៉ង**	អនុប្រធាន
៣. ឯកឧត្តម **ស៊ាង ផល្លា**	អនុប្រធាន
៤. លោក **លី ឆុំង**	អនុប្រធាន
៥. លោក **រស់ សុខណារុណ**	អនុប្រធាន
៦. លោក **អ៊ុង សារ៉ាន់**	សមាជិក
៧. លោក **ញ៉ែម ឥច្ឆិកា**	សមាជិក
៨. លោកស្រី **យក់ សុគន្ធា**	សមាជិក
៩. លោក **ឡាយ រដ្ឋា**	សមាជិក
១០. លោក **សៅ សុតន្ត្រា**	សមាជិក

១១. លោក **អឹម ចំន្ទសុតា** សមាជិក

១២. លោក **ឈាន សាមឌី** សមាជិក

១៣. លោក **ហ៊ែល ប៊ុនថាន** សមាជិក

១៤. លោក **សុខ ចំន្ទភិតក្សា** សមាជិក

១៥. លោក **ជ្បៀប ពិសិដ្ឋ** សមាជិក

១៦. លោក **ហេង ឥសិបុល** សមាជិក

១៧. លោក **សូ សុតា** សមាជិក

១៨. លោក **ឆុទ្ធី សត្រា** សមាជិក

១៩. លោក **ឈិត សុចន្ទ្រា** សមាជិក

២០. លោក **ហួត ឆ៊ែងហួ** សមាជិក

២១. កញ្ញា **អេង សុជាត្តា** សមាជិក

២២. កញ្ញា **ឃ្លឹក ឈុនលីន** សមាជិក។

សមិទ្ធផលដែលសម្រេចបានដោយ **សាលាបណ្ឌិត្យសិក្សាភត្តបូពិ** ក្នុងរយៈពេលជាង ២ ទសវត្សរ៍កន្លងទៅនេះ អាចផ្តល់ជាគំរូនៃអភិបាលកិច្ចមួយក្នុងវិស័យអប់រំ សម្រាប់ទុកជាលំអាននៃការសិក្សា សាកល្បង និងដកពិសោធន៍ ជូនដល់សាលារៀនផ្សេងទៀត នៅព្រះរាជាណាចក្រកម្ពុជា។

ជាក់ស្តែង **សាលាបណ្ឌិត្យសិក្សា ប៊ុន ង៉ាន ហ៊ុន សែន ខ្តត្តបសហាគប** នៅខេត្តព្រៃវែង និង **អនុវិទ្យាល័យគោលាប់** នៅខេត្តក្រចេះ បាននិងកំពុងសាបព្រោះ បណ្តុះ និងស្រោចស្រពពន្លកនៃសម្មាភិបាលរបស់ **សាលាបណ្ឌិត្យសិក្សាភត្តបូពិ** ទៅតាមបរិការណ៍ និងលទ្ធភាពជាក់ស្តែងរបស់ខ្លួន រៀងៗខ្លួន។ ជាបន្តបន្ទាប់ សាលាទាំងពីរនេះ សម្រេចបានន្ធវិវឌ្ឍនភាពគួរឱ្យកត់សម្គាល់ លើការផ្លាស់ប្តូររបៀបដឹកនាំសាលា និងវិធីសាស្ត្រនៃការផ្តល់សេវាអប់រំរបស់ខ្លួន ក្នុងបុព្វហេតុនៃគុណភាពអប់រំ និងគុណធម៌របស់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។

ISBN-13: 978-9924-554-02-8